**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**

**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**


## របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា

# បរិបទនៃការប្រមូលពន្ធ
# របស់សាខាពន្ធដារខណ្ឌចំការមន

កម្មសិក្សាពីថ្ងៃទី ១៨ ខែមីនា ដល់ ថ្ងៃទី១៦ ខែ ឧសភា ឆ្នាំ២០១៩

ឈ្មោះស្ថាប័ន៖ **សាខាពន្ធដារខណ្ឌចំការមន**


តាក់តែងឡើងដោយ

និស្សិតឈ្មោះ៖ **ទិភសូ ជូលីដា**

សាស្ត្រាចារ្យណែនាំ

លោក **ឆាយ ជាហេង**


ថ្នាក់បរិញ្ញាបត្រ គណនេយ្យ

ជំនាន់ទី១៤

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេររបាយការណ៍ ២០១៩

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ វិកស្វ ជូលីដា ជានិស្សិតបរិញ្ញាបត្រគណនេយ្យ ជំនាញគណនេយ្យ ឆ្នាំទី៤ ជំនាន់ទី១៤ ក្រុម A4B1 នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច សូមថ្លែងអំណរគុណ និង ភាពកត្តញ្ញូយ៉ាងជ្រាលជ្រៅ ព្រមទាំងសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ជូនចំពោះ ៖

លោកឪពុក អ្នកម្តាយទាំងទ្វេ ដែលជាអ្នកមានគុណដ៏ធំធេងគ្មានអ្វីអាចប្រៀបផ្ទឹមបាន ដោយលោកបានផ្តល់កំណើតព្រមទាំងចិញ្ចឹមបីបាច់ថែរក្សា ប្រៀនប្រដៅ អប់រំ ផ្តល់ដំបូន្មាន ជួយឧបត្ថម្ភទំនុកបំរុងនូវសព្វគ្រប់បែបយ៉ាងទាំងអស់នូវសេចក្តីត្រូវការរបស់កូនទាំងពេលវេលា ប្រាក់កាក់ និងកម្លាំងកាយចិត្តដោយមិនខ្លាចនឿយហត់ដើម្បីផ្គត់ផ្គង់ឲ្យកូនបានទទួលនូវចំណេះដឹងបានខ្ពង់ខ្ពស់។

លោកឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការង លោកព្រឹទ្ធបុរស លោកព្រឹទ្ធបុរសរង សាស្រ្តាចារ្យ ព្រមទាំងបុគ្គលិក និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានខិតខំរិះរកគំនិត និងរបកគំហើញថ្មីៗ ព្រមទាំងខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តដែលមាន ដើម្បីយកមកបង្ហាត់បង្រៀន ព្រមទាំងផ្តល់ដំបូន្មានល្អៗ និងចំនេះដឹងដ៏ខ្ពង់ខ្ពស់ដល់នាងខ្ញុំ ព្រមទាំងនិស្សិតផ្សេងៗទៀត។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់លោកសាស្រ្តាចារ្យ ឆាយ ជាហេង ដែលបានចំណាយពេលវេលាដល់មានតម្លៃរបស់លោកគ្រូក្នុងការដឹកនាំការសរសេរសារណា ដោយលោកបានយកចិត្តទុកដាក់ជួយផ្តល់ជាយោបល់ បង្ហាត់បង្រៀន ណែនាំ និងចែករំលែកនូវអ្វីថ្មីៗ ដើម្បីជាចំណេះដឹងដល់នាងខ្ញុំ ព្រមទាំងកែតម្រូវរាល់កំហុសឆ្គង និងជំរុញលើកទឹកចិត្តដល់នាងខ្ញុំតាំងពីដើមរហូតដល់ចប់។

នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរដល់អគ្គនាយកដ្ឋានពន្ធដារដែលបានអនុញ្ញាតឲ្យនាងខ្ញុំបានចុះកម្មសិក្សានៅសាខាពន្ធដារខណ្ឌចំការមន។

នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងអនេកដល់ប្រធានសាខាពន្ធដារខណ្ឌចំការមន និងមន្ត្រីក្នុងសាខាខណ្ឌពន្ធដារចំការមនទាំងអស់ដែលបានអនុញ្ញាតឲ្យនាងខ្ញុំបានចុះកម្មសិក្សា និងលះបង់ពេលវេលាដល់មានតម្លៃក្នុងការចែករំលែកព័ត៌មានចំនេះដឹង ក៏ដូចជាឯកសារផ្សេងៗដើម្បីឲ្យនាងខ្ញុំបានសរសេររបាយការណ៍នេះឡើងយ៉ាងជោគជ័យ។

ជាចុងបញ្ចប់នាងខ្ញុំ សូមលំឱនកាយគោរព និងប្រសិទ្ធិពរជ័យដល់លោកអ្នកមានគុណទាំងពីរ លោកឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោកព្រឹទ្ធបុរស លោកព្រឹទ្ធបុរសរង សាស្ត្រាចារ្យ ព្រមទាំងបុគ្គលិក និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ អគ្គនាយកដ្ឋានពន្ធដារ លោកប្រធានសាខាពន្ធដារខណ្ឌចំការមន និងមន្ត្រីពន្ធដារសាខាពន្ធដារខណ្ឌចំការមនទាំងអស់ ព្រមទាំងមិត្តភក្តិរួមជំនាន់ សូមឲ្យជួបតែសេចក្តីសុខ សំណាងល្អ ទទួលជោគជ័យក្នុងការងារ ហើយសូមឲ្យជួបតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណះ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីបានសិក្សាអស់រយៈពេលបួនឆ្នាំនៃថ្នាក់បរិញ្ញាបត្រគណនេយ្យនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នាងខ្ញុំមានសេចក្តីសោមនស្សរីករាយជាខ្លាំង ដោយនាងខ្ញុំមានឱកាសក្នុងការសរសេររបាយការណ៍បញ្ចប់ការសិក្សា និងការចុះធ្វើកម្មសិក្សាផ្ទាល់នៅសាខាពន្ធដារខណ្ឌចំការមន ក្រោមប្រធានបទ " **បរិបទនៃការប្រមូលពន្ធរបស់សាខាពន្ធដារខណ្ឌចំការមន**" ។ ការចុះកម្មសិក្សានេះ ពិតជាបានផ្តល់នូវបទពិសោធន៍ដ៏មានសារៈសំខាន់បំផុត និងចំណេះដឹងបន្ថែមសំរាប់នាងខ្ញុំទៅលើ នីតិវិធីក៏ដូចជាដំណើរកានៃការប្រមូលពន្ធតាមការិយាល័យនីមួយៗ តួនាទីនិងភារកិច្ចរបស់ការរិយាល័យនីមួយៗ។ ហើយរាល់ព័ត៌មានដែលទទួលបានទាំងនេះគឺជាព័ត៌មានដែលចាំបាច់បំផុតសំរាប់យកមកធ្វើការសិក្សាស្រាវជ្រាវ។

ការស្រាវជ្រាវអំពីច្បាប់នានា ស្តីអំពីការប្រមូលពន្ធក្នុងប្រទេសកម្ពុជា ព្រមទាំងការចុះកម្មសិក្សាដោយផ្ទាល់នៅសាខាពន្ធដារខណ្ឌចំការមន ធ្វើអោយនាងខ្ញុំអាចពិនិត្យមើល និងយល់បានកាន់តែច្បាស់ អំពីច្បាប់ និងការអនុវត្តន៍ជាក់ស្តែង។ លើសពីនេះ ការសម្ភាសន៍ និងការពន្យល់ផ្ទាល់ដោយមន្ត្រីនៅក្នុងការិយាល័យនីមួយៗ របស់សាខាពន្ធដារចំការមន គឺជាគន្លឹះធ្វើអោយនាងខ្ញុំអាចវិភាគប្រៀបធៀបរវាងច្បាប់ និងការអនុវត្តន៍ជាក់ស្តែង។

ជាការពិតណាស់នាងខ្ញុំបានសម្រេចចិត្តជ្រើសរើសប្រធានបទនេះដើម្បីយកមកធ្វើការសិក្សាស្រាវជ្រាវគឺ ដោយសារតែនាងខ្ញុំយល់ថាប្រធានបទនេះពិតជាមានសារៈសំខាន់ណាស់សម្រាប់និស្សិតដែលចង់យល់ដឹងបន្ថែមពីច្បាប់ពន្ធ និង ដំណើរការនៃការប្រមូលពន្ធរបស់សាខាពន្ធដារចំការមន។ លើសអំពីនេះ ចំណេះដឹងអំពីកម្មសិក្សានេះ នឹងធ្វើអោយនាងខ្ញុំអាចយកទៅអនុវត្តការងារនាពេលអនាគត់បានយ៉ាងត្រឹមត្រូវទៅតាមច្បាប់។

ជាចុងបញ្ចប់នាងខ្ញុំជឿជាក់ថារបាយការណ៍កម្មសិក្សានេះប្រាកដជាមានកំហុស ឬចំណុចខ្វះខាត និងកំហុសឆ្គងលើអក្ខរាវិរុទ្ធ និងបច្ចេកទេស ប្រាកដជាកើតមានជាក់ជាមិនខាន។ ដូច្នេះនាងខ្ញុំសូមខន្តីអភ័យទោសទុកជាមុននូវរាល់កំហុសឆ្គងអចេតនាដែលកើតមាននៅក្នុងរបាយការកម្មសិក្សានេះ។ ហើយនាងខ្ញុំសង្ឃឹមថា របាយការណ៍កម្មសិក្សាមួយនេះ អាចចូលរួមចំណែកមួយផ្នែកសម្រាប់ការសិក្សាស្រាវជ្រាវដល់និស្សិតជំនាន់ក្រោយ ដែលចង់ស្វែងយល់អំពីប្រធានបទមួយនេះ។

# មាតិកា


តារាងសំគាល់អក្សរកាត់ ........ v
បញ្ជីតារាង ........ vi
បញ្ជីរូបភាព ........ vii
បញ្ជីឧបសម្ព័ន្ធ ........ viii


# សេចក្តីផ្តើម


១.លំនាំបញ្ហា ........ ១
២.ចំណោតបញ្ហា ........ ១
៣.គោលបំណងនៃការស្រាវជ្រាវ ........ ១
៤.តំរូវការពិតមាន ........ ២
៥.ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ២
៦.សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣
៧.វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ៣
៨.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៣


# ជំពូកទី១

# មូលដ្ឋានគ្រឹះនៃការប្រមូលពន្ធ និង ប្រព័ន្ធពន្ធដារកម្ពុជា


១.១.និយមន័យ ........ ៥
១.២.មូលហេតុនៃការប្រមូលពន្ធរបស់រាជរដ្ឋាភិបាល ........ ៥
១.៣.ប្រព័ន្ធពន្ធដារនៅកម្ពុជា ........ ៥
    ១.៣.១.ពន្ធផ្ទាល់ ........ ៥
    ១.៣.២.ពន្ធប្រយោល ........ ៦
១.៤.របបកំណត់ពន្ធនៅកម្ពុជា ........ ៦
    ១.៤.១.អ្នកជាប់ពន្ធតូច ........ ៦
    ១.៤.២.អ្នកជាប់ពន្ធមធ្យម ........ ៦
    ១.៤.៣.អ្នកជាប់ពន្ធធំ ........ ៧
១.៥.សិទ្ធនិងកាតព្វកិច្ច ........ ៧
    ១.៥.១.សិទ្ធ និង កាតព្វកិច្ចរបស់អ្នកជាប់ពន្ធ ........ ៧

១.៥.២.អំណាច និង កាតព្វកិច្ចរបស់រដ្ឋបាលសារពើពន្ធ ....................................................៨
១.៦.រយៈពេលកំណត់នៃការដាក់លិខិតប្រកាសពន្ធ..................................................................៩
១.៧.ទោសទណ្ឌសារពើពន្ធ ...........................................................................................១០
១.៧.១.បទល្មើសបទប្បញ្ញត្តិស្តីពីពន្ធដារ..................................................................១០
១.៧.២.ពន្ធបន្ថែម និងការប្រាក់ ..........................................................................១១
១.៨.ប្រភេទពន្ធសំខាន់ៗនៅកម្ពុជា...................................................................................១២
១.៨.១.ពន្ធលើដីធ្លីមិនបានប្រើប្រាស់.....................................................................១២
១.៨.២.ពន្ធលើឈ្នួលផ្ទះ និង ដី............................................................................ ១៣
១.៨.៣.ពន្ធប្រថាប់ត្រា ........................................................................................១៥
១.៨.៤.ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ................................ ១៧
១.៨.៥.ពន្ធតែមប្រ៊ី ............................................................................................២០
១.៨.៦.ពន្ធអចលនទ្រព្យ ................................................................................... ២២
១.៨.៧ពន្ធអប្បបរមា...........................................................................................២៤
១.៨.៨.ប្រាក់រំដោះពន្ធលើប្រាក់ចំណូល ...............................................................២៥
១.៨.៩.ពន្ធលើប្រាក់បៀវត្ស................................................................................២៥
១.៨.១០.ពន្ធកាត់ទុក ........................................................................................ ៣០
១.៨.១១.អាករលើការស្នាក់នៅ...........................................................................៣២
១.៨.១២អាករបំភ្លឺសាធារណៈ.............................................................................. ៣៣
១.៨.១៣.អាករពិសេសលើទំនិញ និង សេវា ........................................................... ៣៤
១.៨.១៤.អាករលើតម្លៃបន្ថែម. ............................................................................. ៣៥
១.៨.១៥.ពន្ធលើប្រាក់ចំណូល ............................................................................. ៣៩
១.៨.១៦.ពន្ធប៉ាតង់ .............................................................................................៤៥

## ជំពូកទី២

## ស្ថានភាពទូទៅរបស់សាខាពន្ធដារខណ្ឌចំការមន

២.១.សញ្ញាសម្គាល់ ................................................................................................ ៤៧
២.២.ប្រវត្តិ និង ទីតាំងភូមិសាស្ត្រ........................................................................................ ៤៧
២.៣.បេសកកម្ម.............................................................................................................៤៨
២.៤.ចក្ខុវិស័យ និងគោលដៅនាពេលអនាគត.........................................................................៤៩

២.៥.រចនាសម្ព័ន្ធ ........ ៥០
២.៦.តួនាទីនិងភារកិច្ចរួម ........ ៥១
២.៧.តួនាទី និងភារកិច្ចការិយាល័យនីមួយៗ ........ ៥១
២.៧.១.ការិយាល័យរដ្ឋបាល ........ ៥១
២.៧.២.ការិយាល័យសេវាអ្នកជាប់ពន្ធ........ ៥២
២.៧.៣.ការិយាល័យចាត់ចែងលិខិតប្រកាស........ ៥៣
២.៧.៤.ការិយាល័យសវនកម្មពន្ធ ........ ៥៤
២.៧.៥.ការិយាល័យបំណុល ........ ៥៥

## ជំពូកទី៣

## ដំណើរការនៃការប្រមូលពន្ធរបស់សាខាពន្ធជាខណ្ឌចំការមន

៣.១.ការិយាល័យសេវាអ្នកជាប់ពន្ធនិងចុះបញ្ជី........ ៥៧
៣.១.១.នីតិវិធីនៃការចុះបញ្ជី ........ ៥៧
៣.១.២.ការប្រមូលពន្ធការិយាល័យសេវាអ្នកជាប់ពន្ធនិងចុះបញ្ជី ........ ៥៩
៣.១.២.១.ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ ........ ៥៩
៣.១.២.២.ពន្ធលើអចលនទ្រព្យ........ ៦១
៣.១.២.៣.ពន្ធលើឈ្នួលផ្ទះ និង ដី ........ ៦២
៣.១.២.៤.ពន្ធប្រថាប់ត្រា ........ ៦៣
៣.២.ការិយាល័យចាត់ចែងលិខិតប្រកាស........ ៦៤
៣.២.១.ការប្រកាសពន្ធប្រចាំខែ........ ៦៤
៣.២.២.ការប្រកាសពន្ធប្រចាំឆ្នាំ........ ៦៥
៣.២.៣.ដំណើរការនៃការប្រកាសពន្ធ ........ ៦៥
៣.៣.ការិយាល័យសវនកម្ម........ ៦៦
៣.៣.១.សវនកម្មលើលិខិតស្នាម ........ ៦៦
៣.៣.២.សវនកម្មដល់ទីកន្លែង........ ៦៧
៣.៣.៣.ការជ្រើសរើសសហគ្រាសធ្វើសវនកម្ម ........ ៦៧
៣.៣.៤.ដំណើរការនៃការធ្វើសវនកម្ម. ........ ៦៨

៣.៤.ការិយាល័យបំណុល.......................................................................................................៦៩
    ៣.៤.១.នីតិវិធីនៃការប្រមូលបំណុល ..........................................................................................៦៩
៣.៥.របាយការណ៍ចំណូលរបស់សាខាពន្ធដារខណ្ឌចំការមន................................................. ៧០
    ៣.៥.១.ទិន្នន័យចំណូលសរុបប្រចាំឆ្នាំ....................................................................................... ៧០
    ៣.៥.២.ក្រាហ្វិកចំណូលសរុបប្រចាំឆ្នាំ....................................................................................... ៧០
    ៣.៥.៣.ក្រាហ្វិកចំណូលប្រចាំឆ្នាំរវាងផែនការកំណត់ និងការអនុវត្តក្នុងឆ្នាំ ...................... ៧១

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

១.សេចក្តីសន្និដ្ឋាន...................................................................................................................៧៣
២.ការផ្តល់អនុសាសន៍ .............................................................................................................៧៣
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# តារាងសំគាល់អក្សរកាត់

| អក្សរកាត់ | ពាក្យពេញ |
|---|---|
| ក.ស.ហ.វ | ក្រសួងសេដ្ឋកិច្ច និងហិរិញ្ញវត្ថុ |
| អពដ | អគ្គនាយកដ្ឋានពន្ធដារ |
| ប្រ.ក | ប្រកាស |
| អតប | អាករលើតម្លៃបន្ថែម |
| ពបវ | ពន្ធលើប្រាក់បៀវត្ស |
| ពបច | ពន្ធលើប្រាក់ចំណូល |

# បញ្ជីតារាង

តារាងទី១៖ ការកំណត់ប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូនទូទៅ............................................ ១៧
តារាងទី២៖ ការកំណត់ប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូនកែច្នៃផ្សេងទៀត ............................. ១៩
តារាងទី៣៖ ការកំណត់ប្រាក់ពន្ធតាមទំហំស៊ីឡាំងរបស់រថយន្តទេសចរណ៍ .............................២០
តារាងទី៤៖ អត្រាពន្ធ ប្រភេទ និងទំហំផ្ទៃក្រឡា ពន្ធតែមប្រ៍ ...................................................២១
តារាងទី៥៖ តារាងអត្រាពន្ធកំណើនតាមថ្នាក់........................................................................៤០
តារាងទី៦៖ តារាងឧទាហរណ៍ការកំណត់រយៈពេលលើកលែងពន្ធ .........................................៤៥
តារាងទី៧៖ រចនាសម្ព័ន្ធរបស់សាខាពន្ធដារខណ្ឌចំការមន .....................................................៥០
តារាងទី៨៖ ដំណើរការនៃការចុះបញ្ជីរបស់សហគ្រាស..........................................................៥៩
តារាងទី៩៖ ដំណើរការនៃការដាក់លិខិតប្រកាសពន្ធលើមធ្យោបាយដឹកជញ្ជូន
និងយានជំនិះគ្រប់ ប្រភេទ.....................................................................................៦០
តារាងទី១០៖ ដំណើរការនៃការដាក់លិខិតប្រកាសពន្ធលើអចលនទ្រព្យ..................................៦១
តារាងទី១១៖ ដំណើរការនៃការដាក់លិខិតប្រកាសពន្ធលើឈ្នួលផ្ទះ និងដី ...............................៦២
តារាងទី១២៖ ដំណើរការនៃការដាក់លិខិតប្រកាសពន្ធប្រថាប់ត្រា .......................................... ៦៣
តារាងទី១៣៖ នីតិវិធីនៃការប្រមូលពន្ធ...................................................................................៦៦
តារាងទី១៤៖ ទិន្នន័យចំណូលសរុប និងផែនការអនុវត្តក្នុងឆ្នាំនីមួយៗ..................................... ៧០

# បញ្ជីរូបភាព


រូបភាពទី១៖ សញ្ញាសម្គាល់ ........................................................................................ ៤៧
រូបភាពទី២៖ សាខាពន្ធដារខណ្ឌចំការមន ........................................................................ ៤៨
រូបភាពទី៣៖ ក្រាហ្វិកចំណូលប្រចាំឆ្នាំ ............................................................................ ៧០
រូបភាពទី៤៖ ក្រាបនៃចំណូលប្រចាំឆ្នាំរវាងផែនការកំណត់ និងការអនុវត្តក្នុងឆ្នាំ ...................... ៧១

## បញ្ជីឧបសម្ព័ន្ធ

១ . ប្រកាសស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ

២ . សារាចរស្តីពីការអនុវត្តកាតព្វកិច្ចកាត់ទុកពន្ធលើអត្ថប្រយោជន៍បន្ថែម

៣ . អនុក្រឹត្យស្តីពីការកែសម្រួលតារាងពន្ធតែមប្រើសារពើពន្ធ

៤ . ប្រកាសស្តីពីការកំណត់មូលដ្ឋានគិតអាករសម្រាប់បំភ្លឺសាធារណៈ

៥ . សេចក្តីប្រកាសព័ត៌មាន

៦ . លិខិតប្រកាសអាករលើតម្លៃបន្ថែម(បន្ទុករដ្ឋ)

៧ . លិខិតប្រកាសអាករលើតម្លៃបន្ថែម

៨ . លិខិតប្រកាសពន្ធកាត់ទុក

៩ . លិខិតប្រាកាសពន្ធលើប្រាក់បៀវត្ស

១០ . លិខិតប្រកាសប្រាក់រំដោះពន្ធលើប្រាក់ចំនេញ អាករពិសេសលើទំនិញ និងសេវា អាករលើការស្នាក់នៅ អាករបំភ្លឺសាធារណៈ និងពន្ធអាករដទៃទៀត

១១ . លិខិតប្រកាសពន្ធលើអចលនទ្រព្យប្រចាំឆ្នាំ

១២ . លិខិតប្រកាសពន្ធប៉ាតង់ប្រចាំឆ្នាំ

១៣ . លិខិតប្រកាសបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ

១៤ . លិខិតប្រកាសពន្ធលើឈ្នួលផ្ទះនិងដី

១៥ . លិខិតប្រកាសពន្ធលើដីធ្លីមិនបានប្រើប្រាស់

១៦ . ពាក្យស្នើសុំចុះបញ្ជីពន្ធដារ(របបស្វ័យប្រកាស)

១៧ . ពាក្យស្នើសុំចុះបញ្ជីពន្ធដារ (សម្រាប់អ្នកជាប់ពន្ធតូច)

១៨ . លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហា

នៅក្នុងប្រទេសអភិវឌ្ឍន៍ក្តី និងប្រទេសកំពុងអភិវឌ្ឍក្តី វិស័យពន្ធដារដើរតួយ៉ាងសំខាន់នៅក្នុងការរួមចំណែកអភិវឌ្ឍន៍ប្រទេសជាតិឲ្យមានការរីកចំរើន ការកាត់បន្ថយភាពក្រីក្រ និងពង្រឹងសេដ្ឋកិច្ចឲ្យកាន់តែមានការរីកចំរើន។ ជាការពិតណាស់បច្ចុប្បន្ននេះចំណូលមួយផ្នែកធំរបស់រាជរដ្ឋាភិបាលគឺ បានមកពីការប្រមូលពន្ធពីប្រជាពលរដ្ឋ ហើយចំណូលនេះគឺជាផ្នែកមួយដ៏សំខាន់នៅក្នុងការចូលរួមចំណែកអភិវឌ្ឍប្រទេសជាតិអោយរីកចំរើន ដូចជាការសាងសង់សាលារៀន មន្ទីរពេទ្យ ផ្លូវថ្នល់ និង ស្ពានជាដើម។ ហេតុដូចនេះហើយ ទើបបច្ចុប្បន្ននេះរដ្ឋាភិបាលបានយកចិត្តទុកដាក់យ៉ាងខ្លាំងនៅក្នុងការកែទម្រង់វិស័យពន្ធដារនៃប្រទេសកម្ពុជា អោយកាន់តែមានភាពប្រសើរឡើង។ សព្វថ្ងៃនេះរបបកំណត់ពន្ធនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានធ្វើការកែទម្រង់ពីរបបពន្ធបីយ៉ាង (របបពិត របបបំព្រួញ និងរបបមៅការ) ឲ្យនៅសល់តែមួយរបបប៉ុណ្ណោះ គឺរបបស្វ័យប្រកាស ដែលតម្រូវឲ្យអ្នកជាប់ពន្ធធ្វើការគណនាប្រាក់ពន្ធ និងដាក់លិខិតប្រកាសបង់ប្រាក់ពន្ធដោយខ្លួនឯង។ ដោយសារការប្រមូលពន្ធគឺជាផ្នែកមួយសំខាន់ ទើបនាងខ្ញុំសម្រេចចិត្តជ្រើសរើសប្រធានបទ "បរិបទនៃការប្រមូលពន្ធរបស់សាខាពន្ធដារខណ្ឌចំការមន" យកមកធ្វើការសិក្សាស្រាវជ្រាវដើម្បីយល់ដឹងឲ្យបានកាន់តែច្បាស់ពីដំណើរការនៃការប្រមូលពន្ធរបស់រាជរដ្ឋាភិបាល។

## ២.ចំណោទបញ្ហា

ការស្រាវជ្រាវនេះ ធ្វើឡើងនៅក្នុងគោលបំណងស្វែងយល់អោយកាន់តែច្បាស់អំពីនីតិវិធីនិងវិធីសាស្ត្រនៃការប្រមូលពន្ធរបស់សាខាពន្ធដារខណ្ឌចំការមន និងផ្តល់ជាគំនិតដល់និស្សិត ឬអ្នកសិក្សាស្រាវជ្រាវដែលចង់ដឹងបន្ថែមពីការប្រមូលពន្ធរបស់សាខាពន្ធដារខណ្ឌចំការមន។ ការស្រាវជ្រាវនេះនឹងធ្វើការឆ្លើយតបទៅនឹងសំណួរដូចខាងក្រោម៖

តើច្បាប់ស្តីពីការប្រមូលពន្ធក្នុងព្រះរាជាណាចក្រកម្ពុជា មានចែងយ៉ាងដូចម្តេច ស្តីអំពីការប្រមូលពន្ធ? តើសាខាពន្ធដារខណ្ឌចំការមនធ្វើការប្រមូលពន្ធយ៉ាងដូចម្តេច? តើសាខាពន្ធដារខណ្ឌចំការមនមាននីតិវិធីក្នុងការប្រមូលពន្ធដូចម្តេចខ្លះ? តើសាខាពន្ធដារខណ្ឌចំការមនមានយន្តការដូចម្តេចខ្លះ ដើម្បីធានាថាអ្នកជាប់ពន្ធបានបង់ពន្ធត្រឹមត្រូវ?

## ៣.គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវនេះ គឺផ្តោតសំខាន់ទៅលើបរិបទនៃការប្រមូលពន្ធរបស់សាខាពន្ធដារខណ្ឌចំការមន ដើម្បីធ្វើការឆ្លុះបញ្ចាំងពីការអនុវត្តជាក់ស្តែង ពីនីតិវិធីក៏ដូចជាវិធីសាស្ត្រ

នៅក្នុងការប្រមូលពន្ធរបស់សាខាពន្ធដារខណ្ឌចំការមន។ ដើម្បីឲ្យបានយល់កាន់តែច្បាស់អំពីបញ្ហានេះ នាងខ្ញុំកំណត់គោលបំណងនៃការស្រាវជ្រាវដូចខាងក្រោម៖

- ច្បាប់សារពើពន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ប្រព័ន្ធកំណត់ពន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- កាតព្វកិច្ច និងសិទ្ធរបស់អ្នកជាប់ពន្ធ
- អំណាច និងសិទ្ធរបស់រដ្ឋបាលសារពើពន្ធ
- របបកំណត់ពន្ធរបស់ព្រះរាជាណាចក្រកម្ពុជា
- ទោសទណ្ឌសារពើពន្ធ
- អត្រាពន្ធ មូលដ្ឋានគិតពន្ធ និង ការគណនាប្រាក់ពន្ធ
- មុខសញ្ញាជាប់ពន្ធ
- ការលើកលែងពន្ធ

## ៤.តំរូវការព័ត៌មាន

ដើម្បីឲ្យការងារនេះសម្រេចទៅបាន យើងត្រូវការព័ត៌មានសំខាន់ៗមួយចំនួនដូចជា៖

- ឯកសារស្តីអំពីច្បាប់ អនុក្រឹត្យ ប្រកាស សរាចរណែនាំ និងសេចក្តីជូនដំណឹងនានាទាក់ទងនិងការប្រមូលពន្ធនៅប្រទេសកម្ពុជា
- ការចុះសម្ភាសន៍ផ្ទាល់អំពីការប្រមូលពន្ធពីការិយាល័យនានារបស់សាខាពន្ធដារខណ្ឌចំការមន
- ព័ត៌មានដែលទទួលបានតាមរយៈការបង្ហាត់បង្រៀនពីលោកប្រធាន និងបុគ្គលិករបស់សាខាពន្ធដារខណ្ឌចំការមន
- ឯកសារទាក់ទិនអំពីការប្រមូលពន្ធ ទទួលបានពីសាខាពន្ធដារខណ្ឌចំការមន

## ៥.ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះ យោងតាមច្បាប់ស្តីពីសារពើពន្ធ បច្ចុប្បន្នព្រះរាជាណាចក្រកម្ពុជាមានប្រភេទពន្ធចំនួន ១៦ ប្រភេទពន្ធ។ ប៉ុន្តែដោយសារវិសាលលភាពនៃច្បាប់ពន្ធមានលក្ខណៈទូលំទូលាយ និងទាមទាររយៈពេលនៃការសិក្សាស្រាវជ្រាវច្រើន ដូច្នេះនាងខ្ញុំគ្រាន់តែលើកយកចំណុចសំខាន់នៃប្រភេទពន្ធនីមួយៗ និងនីតិវិធីនៃការប្រមូលពន្ធតាមការិយាល័យនីមួយៗ នៃសាខាពន្ធដារខណ្ឌចំការមនយកមកធ្វើការសិក្សាស្រាវជ្រាវ។

## ៦.សារៈសំខាន់នៃការស្រាវជ្រាវ

សារៈសំខាន់នៃការសិក្សាស្រាវជ្រាវនេះរួមមានដូចខាងក្រោម៖

- យល់ដឹងអំពីសិទ្ធិនិងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ
- យល់ដឹងឲ្យកាន់តែច្បាស់អំពីច្បាប់សារពើពន្ធនៃព្រះរាជាណាចក្រកម្ពុជា
- ស្គាល់អំពីនីតិវិធីនៅក្នុងការប្រមូលពន្ធ
- យល់ដឹងអំពីការធ្វើសវនកម្មរបស់ពន្ធដារ
- យល់ដឹងអំពីនីតិវិធីនៃការទូទាត់ និងទារបំណុល
- យល់ដឹងអំពីនីតិវិធីនៃការដាក់លិខិតប្រកាសពន្ធប្រចាំខែ និងឆ្នាំ
- ផ្តល់ជាឯកសារសម្រាប់និស្សិតជំនាន់ក្រោយ ក្នុងការសិក្សាស្រាវជ្រាវបន្ថែមទៅលើប្រធានបទដែលទាក់ទងទៅនឹងនីតិវិធីនៃការប្រមូលពន្ធ
- អាចទទួលបាននូវបទពិសោធន៍ជាក់ស្តែង ដើម្បីយកទៅអនុវត្តក្នុងសកម្មភាពការងារជាក់ស្តែង។

## ៧.វិធីសាស្ត្រនៃការស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវនេះ នាងខ្ញុំបានប្រើប្រាស់វិធីសាស្ត្រសិក្សាស្រាវជ្រាវតាមបែបវិធីសាស្ត្រគុណវិស័យ សំរាប់ធ្វើការបកស្រាយទៅលើប្រធានបទមួយនេះ។ ការប្រមូលទិន្នន័យត្រូវការទិន្នន័យពីរយ៉ាងគឺ ទិន្នន័យបឋម និងទិន្នន័យបន្ទាប់។ ដោយទិន្នន័យបឋមគឺ នាងខ្ញុំបានធ្វើការប្រមូលទិន្នន័យតាមរយៈការចុះធ្វើកម្មសិក្សាដល់ទីកន្លែងនៅសាខាពន្ធដារខណ្ឌចំការមនដោយការធ្វើសម្ភាសន៍ និង ការអានឯកសារទាក់ទិន ដើម្បីទទួលបានព័ត៌មាន។ ទិន្នន័យបន្ទាប់គឺការសិក្សាស្រាវជ្រាវឯកសារដូចជា ច្បាប់ អនុក្រឹត្យ ក្រម ប្រកាស សេចក្តីជូនដំណឹង សារាចរណ៍ឯកសារចងក្រងដោយសាស្ត្រាចារ្យ និងអគ្គនាយកដ្ឋានពន្ធដារ។

## ៨.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវនេះ ត្រូវបានបែងចែកជា ៥ ផ្នែកដូចខាងក្រោម៖

- **សេចក្តីផ្តើម** ៖ សិក្សាអំពីមូលដ្ឋាននៃការសិក្សាស្រាវជ្រាវ។ ចំណុចនេះបកស្រាយអំពីមូលហេតុនៃការសិក្សាស្រាវជ្រាវ គោលបំណងនៃការសិក្សាស្រាវជ្រាវ ដែនកំណត់នៃការសិក្សាស្រាវជ្រាវ និងវិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវតាំងពីដើមរហូតដល់បានចងក្រងជាសៀវភៅនេះ។

- **ជំពូកទី១** ៖ បង្ហាញអំពីមូលដ្ឋានគ្រឹះនៃពន្ធដារនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ជំពូកនេះបានបង្ហាញអំពីប្រព័ន្ធពន្ធដារនៅព្រះរាជាណាចក្រកម្ពុជា សិទ្ធិនិងកាតួកិច្ចរបស់អ្នកជាប់ពន្ធ ការបង្ហាញអំពីចំនុចសំខាន់ៗរបស់ច្បាប់ពន្ធដោយសង្ខេបទៅលើ មុខសញ្ញានៃការជាប់ពន្ធ ការលើកលែងពន្ធ អត្រាពន្ធ មូលដ្ឋានគិតពន្ធ និងការគណនាប្រាក់ពន្ធ។
- **ជំពូកទី២** ៖ បង្ហាញអំពីស្ថានភាពទូទៅរបស់សាខាពន្ធដារខណ្ឌចំការមន។ ជំពូកនេះនឹងបកស្រាយអំពី សញ្ញាសម្គាល់ ទីតាំងភូមិសាស្រ្ត ចក្ខុវិស័យ បេសកកម្ម តួនាទី ភារកិច្ច និង រចនាសម្ព័ន្ធរបស់សាខាពន្ធដារខណ្ឌចំការមន។
- **ជំពូកទី៣** ៖ បង្ហាញអំពីដំណើរការនៃការប្រមូលពន្ធរបស់សាខាពន្ធដារខណ្ឌចំការមន។ បង្ហាញអំពីនីតិវិធីនៃកាប្រមូលពន្ធរបស់ការិយាល័យនីមួយៗ។
- **សេចក្តីសន្និដ្ឋាន និង ការផ្តល់អនុសាស្រ្ត** ៖ ធ្វើការវាយតម្លៃទៅលើភាពវិជ្ជមាន និងភាពអវិជ្ជមានមួយចំនួនតាមរយៈការសិក្សាស្រាវជ្រាវកន្លងមក។ បន្ទាប់មកទៀតនាងខ្ញុំនឹងធ្វើការផ្តល់យោបលផ្ទាល់ខ្លួន ក្នុងគោលបំណងរិះគន់ដើម្បីស្ថាបនា។

# ជំពូកទី១

# មូលដ្ឋានគ្រឹះនៃការប្រមូលពន្ធ និងប្រព័ន្ធពន្ធដារកម្ពុជា

# ជំពូកទី១
# មូលដ្ឋានគ្រឹះនៃការប្រមូលពន្ធ និងប្រព័ន្ធពន្ធដារកម្ពុជា

## ១.១. និយមន័យ

ពន្ធត្រូវបានគេឲ្យនិយមន័យថា ជាការបង់ដោយបង្ខំ ដែលបានកំណត់ដោយរដ្ឋាភិបាលទៅលើរូបវន្តបុគ្គល សាជីវកម្ម សហគ្រាស ហើយគ្មានផ្ដល់សេវាកម្មទៅឲ្យអ្នកបង់ពន្ធដោយផ្ទាល់នោះឡើយ។ ពលរដ្ឋគ្រប់រូបត្រូវបង់ពន្ធ ដោយផ្អែកទៅលើចំណូលដែលគេរកបាន (ឧទាហរណ៍ ពន្ធលើប្រាក់ចំណូល) ឬដោយផ្អែកលើចំណាយដែលគេបានចាយ។ ឧទាហរណ៍ អាករលើតម្លៃបន្ថែម ឬដោយផ្អែកលើទ្រព្យសម្បត្តិដែលគេមានជាកម្មសិទ្ធ ។

## ១.២.មូលហេតុនៃការប្រមូលពន្ធរបស់រាជរដ្ឋាភិបាល

រាជរដ្ឋាភិបាលធ្វើការប្រមូលពន្ធ៖

- ដើម្បីបង្កើនចំណូលហិរញ្ញវត្ថុសម្រាប់ចំណាយរបស់រាជរដ្ឋាភិបាល
- ដើម្បីទិសដៅសុខុមាលភាពសង្គមនិងសេដ្ឋកិច្ច
- ជាមធ្យោបាយដើម្បីកាត់បន្ថយការចំណាយខ្ជះខ្ជាយរបស់ប្រជាពលរដ្ឋ
- ដើម្បីបែងចែកទៅអោយអ្នកក្រវិញតាមរយៈសេវាកម្មរបស់រាជរដ្ឋាភិបាលដូចជាសុខុមាលភាពសង្គម និងតាមរយៈការផ្ដល់ជាអំណោយ និងការឧបត្ថម្ភបធន
- ដើម្បីជំរុញអោយមានការលូតលាស់សេដ្ឋកិច្ច និងឧស្សាហកម្មក្នុងស្រុក
- ដើម្បីការពារសុខភាពរបស់ប្រជាជន ពន្ធប្រយោលលើបារី ស្រាជាដើម
- កាត់បន្ថយការស្ទះចរាចរណ៍ក្នុងស្រុកតាមរយៈការបង្កើនពន្ធលើរថយន្តនាំចូល កាត់បន្ថយកម្មសិទ្ធិលើរថយន្ត
- ដើម្បីការពារឧស្សាហកម្មក្នុងស្រុក។

## ១.៣. ប្រព័ន្ធពន្ធដារនៅកម្ពុជា

ប្រព័ន្ធពន្ធដារនៅប្រទេសកម្ពុជាបានអនុវត្តការយកពន្ធតាមវិធីសាស្ត្រពីរគឺ វិធីសាស្ត្រផ្ទាល់ (ពន្ធផ្ទាល់) និងវិធីសាស្ត្រប្រយោល (ពន្ធប្រយោល)។

### ១.៣.១.ពន្ធផ្ទាល់

ពន្ធផ្ទាល់ គឺជាពន្ធដែលត្រូវបានកំណត់ទៅលើរូបវន្តបុគ្គល សាជីវកម្ម ឬសហគ្រាសដែលជាអ្នករងពន្ធផង និងជាប់ពន្ធផ្ទាល់។ ពន្ធផ្ទាល់ត្រូវបានប្រមូលដោយផ្ទាល់ពីបុគ្គលដែលបង់ពន្ធ។

ឧទាហរណ៍ ពន្ធលលើប្រាក់ចំណូល។

**១.៣.២.ពន្ធប្រយោល**

ពន្ធប្រយោល គឺជាពន្ធដែលអនុវត្តទៅលើទំនិញ ឬសេវា ហើយត្រូវបង់ដោយអ្នកប្រើប្រាស់ទំនិញ ឬសេវាទាំងនោះ។ មានន័យថាអ្នកជាប់ពន្ធគឺជាអ្នក ប្រើប្រាស់ទំនិញ ឬសេវា ហើយជាអ្នកបង់ពន្ធទៅឲ្យរដ្ឋាភិបាលតាមរយៈអ្នកជាប់ពន្ធ។ ឧទាហរណ៍ អាករលើតម្លៃបន្ថែម អាករពិសេស អាករបំភ្លឺសាធារណៈ។

## ១.៤. របបកំណត់ពន្ធនៅកម្ពុជា

នៅមុនឆ្នាំ២០១៦ យោងតាមមាត្រា ៤ នៃច្បាប់ស្តីពីសារពើពន្ធ បានចែងរបបកំណត់ពន្ធជា ៣ គឺ របបពិត របបបំព្រួញ និង របបមៅការ។ ប៉ុន្តែចាប់ពីឆ្នាំ ២០១៦មក របបកំណត់ពន្ធទាំងបីត្រូវបានលុបចោល មកនៅសល់តែមួយរបបប៉ុណ្ណោះ គឺរបបស្វ័យប្រកាស។ អ្នកជាប់ពន្ធតម្រូវឲ្យកំណត់ពន្ធ និងប្រកាសពន្ធដោយខ្លួនឯង។ របបស្វ័យប្រកាសបែងចែកអ្នកជាប់ពន្ធជាបីប្រភេទ៖

**១.៤.១.អ្នកជាប់ពន្ធតូច**

អ្នកជាប់ពន្ធតូចត្រូវកាន់បញ្ជីការគណនេយ្យតាមប្រព័ន្ធគណនេយ្យសាម័ញ្ញ(SAF)ដែលមានភាពងាយស្រួល។ អ្នកជាប់ពន្ធតូច គឺសហគ្រាសឯកបុគ្គល ឬសហគ្រាសសហកម្មសិទ្ធ ដែល ៖

- មានផលរបរប្រចាំឆ្នាំចាប់ពី ២៥០លានរៀល ដល់ ៧០០លានរៀលឬ
- មានផលរបរក្នុងរយៈពេល បីខែ ជាប់គ្នាណាមួយដែលបញ្ចប់ក្នុងឆ្នាំប្រតិទិនចរន្ត ចាប់ពី ៦០ លានរៀលឡើងទៅ ឬ
- រំពឹងថាមានផលរបរក្នុងរយៈពេលបីខែ ជាប់គ្នាខាងមុខ ចាប់ពី ៦០លានរៀលឡើងទៅ ឬ
- ចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ក្នុងការផ្គត់ផ្គង់ទំនិញ ឬសេវា រួមទាំងភាស៊ី

**១.៤.២.អ្នកជាប់ពន្ធមធ្យម**

អ្នកជាប់ពន្ធមធ្យមគឺជា ៖

- សហគ្រាសដែលមានផលរបរប្រចាំឆ្នាំលើសពី ៧០០លានរៀលដល់ ៤០០០ លានរៀលឬ
- សហគ្រាសដែលបានចុះបញ្ជីជានីតិបុគ្គល ការិយាល័យតំណាង ឬ
- ស្ថាប័នរដ្ឋថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អង្គការឬសមាគមគ្រប់ប្រភេទរួមទាំងអង្គការមិនមែនរដ្ឋាភិបាល ឬ
- បេសកកម្មទូត និងកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា។

### **១.៤.៣.អ្នកជាប់ពន្ធធំ**

អ្នកជាប់ពន្ធធំគឺជា ៖

- សហគ្រាសដែលមានផលរបរប្រចាំឆ្នាំលើសពី ៤០០០ លានរៀល
- បុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនពហុជាតិ សាខាក្រុមហ៊ុនបរទេស ឬ
- សហគ្រាសដែលបានចុះបញ្ជីជាគម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។[1]

## **១.៥.សិទ្ធិ និងភាតព្វកិច្ច**

### **១.៥.១.សិទ្ធិ និងភាតព្វកិច្ចរបស់អ្នកជាប់ពន្ធ**

ប្រជាពលរដ្ឋគ្រប់រូបនៃបណ្ដាប្រទេសនានាទូទាំងពិភពលោក តែងតែមានសិទ្ធនិងកាតព្វកិច្ច ដែលត្រូវអនុវត្ត ហើយប្រជាពលរដ្ឋម្នាក់ៗត្រូវយល់ដឹងអំពីសិទ្ធ និងកាតព្វកិច្ចដែលមាន។ ដូច្នេះ ហើយបានជារដ្ឋបាលសារពើពន្ធបានកំណត់អំពីសិទ្ធ និងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ៖

- អ្នកជាប់ពន្ធមានកាតព្វកិច្ច៖
  - -ចុះឈ្មោះក្នុងបញ្ជីរបស់រដ្ឋបាលសារពើពន្ធ
  - -ដាក់លិខិតប្រកាសសារពើពន្ធ និងផ្ដល់ព័ត៌មានតាមការតម្រូវ
  - -បង់ប្រាក់ពន្ធតាមកាលបរិច្ឆេទកំណត់
  - -កាន់កាប់ ថែរក្សា និងត្រូវបង្ហាញ បញ្ជី លិខិតយុត្តិការ និងឯកសារផ្សេងៗ
  - -បង្ហាញខ្លួនចំពោះរដ្ឋបាលសារពើពន្ធ
  - -បង់ប្រាក់ពន្ធ ពន្ធបន្ថែម និងការប្រាក់ផ្សេងៗតាមការកំណត់ពន្ធ
  - -ត្រូវមានភាពស្មោះត្រង់ក្នុងការបំពេញកាតួកិច្ចសារពើពន្ធ
  - -ត្រូវមានកិច្ចសហប្រតិបត្តិការជាមួយរដ្ឋបាលសារពើពន្ធ
- អ្នកជាប់ពន្ធមានសិទ្ធិ៖
  - -ទទួលបានការរក្សាទុកជាសម្ងាត់
  - -ទទួលបានការផ្ដល់សេវាប្រកបដោយវិជ្ជាជីវៈ និងមានការជួយពន្យល់ណែនាំ
  - -ទទួលបានការពន្យល់រាល់សេចក្ដីសម្រេចរបស់រដ្ឋបាលសារពើពន្ធ
  - -ប្ដឹងតវ៉ាចំពោះរាល់សេចក្ដីសម្រេចរបស់រដ្ឋបាលសារពើពន្ធ

[1] ប្រកាសស្ដីពីការកែសម្រួលចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស,លេខ ០២៥ សហប្រ.កអពដ ចុះថ្ងៃទី ២៥ ខែមីនា ឆ្នាំ ២០១៨ ។

-បង់ពន្ធមិនឲ្យលើសពីបទប្បញ្ញត្តិស្តីពីពន្ធដារកំណត់

-មានការទទួលស្គាល់តំណាងស្របច្បាប់របស់អ្នកជាប់ពន្ធ

-ទទួលបានការអនុវត្តដោយតម្លាភាព និង មិនលម្អៀង

-ទទួលបានការទទួលស្គាល់អំពីភាពស្មោះត្រង់។

### ១.៥.២.អំណាច និងភារកិច្ចរបស់រដ្ឋបាលសារពើពន្ធ

➢ អំណាចរបស់រដ្ឋបាលសារពើពន្ធ៖

- កំណត់មូលដ្ឋានគិតពន្ធលើអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក
- តម្រូវអោយអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកបង្ហាញខ្លួន
- កំណត់បញ្ជី ឯកសារចាំបាច់នានា និងលិខិតយុត្តិការ ដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកត្រូវកាន់កាប់រក្សាទុក និងផ្តល់ជូនរដ្ឋបាលសារពើពន្ធ
- ទាមទារអោយអ្នកជាប់ពន្ធ ឬតតិយជនផ្តល់ព័ត៌មានដែលទាក់ទិននឹងអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក
- ចូលលំនៅស្ថាន ឬគ្រឹះស្ថានអាជីវកម្មរបស់អ្នកជាប់ពន្ធ ភ្នាក់ងារកាត់ទុក ឬតតិយជនដើម្បីទទួលបាននូវព័ត៌មានទាក់ទិននិងអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក
- ទទួលពីស្ថាប័នរដ្ឋទាំងឡាយនូវព័ត៌មានស្តីពី ឬដែលទាក់ទិននឹងអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក
- អនុវត្តវិធានការតឹងទារចំពោះអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកនៅពេលដែលបុគ្គលនោះមិនបានបង់ប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងការប្រាក់ផ្សេងៗតាមការតម្រូវ
- កំណត់ឡើងវិញនូវកិច្ចការអាជីវកម្មរវាងអ្នកជាប់ពន្ធទាំងឡាយដែលមានជាប់ទាក់ទង ដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ។

➢ ភារកិច្ចរបស់រដ្ឋបាលសារពើពន្ធ៖

- ប្រមូលពន្ធ ប្រាក់ពន្ធបន្ថែម និងការប្រាក់ផ្សេងៗ
- រក្សាការសម្ងាត់នូវព័ត៌មាន ដែលអ្នកជាប់ពន្ធ ឬតតិយជនបានផ្តល់អោយ ហើយផ្តល់នូវព័ត៌មានអោយដល់តែបុគ្គលណាដែលបទប្បញ្ញត្តិស្តីពីពន្ធដារបានកំណត់ប៉ុណ្ណោះ
- ផ្តល់ព័ត៌មានដល់អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក សំដៅធានាអោយការអនុវត្តន៍បានសមស្របទៅតាមបទប្បញ្ញត្តិស្តីពីពន្ធដារ

- បង្វិលសងវិញ ឬចាត់ជាឥណទានពន្ធ នូវប្រាក់ពន្ធដែលបង់លើស ដូចដែលមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ
- ផ្តល់លិខិតជូនដំណឹងស្តីពីការកំណត់ពន្ធ អោយអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក។[2]

## ១.៦.រយៈពេលកំណត់នៃការដាក់លិខិតប្រកាសពន្ធ

អ្នកជាប់ពន្ធទាំងអស់មានកាតព្វកិច្ចបង់ប្រាក់ពន្ធ និងដាក់លិខិតប្រកាសពន្ធទៅតាមកាលកំណត់របស់រដ្ឋបាលសារពើពន្ធ៖

➢ កាលបរិច្ឆេទកំណត់នៃការដាក់លិខិតប្រកាសពន្ធប្រចាំខែ

អ្នកជាប់ពន្ធត្រូវដាក់លិខិតប្រកាសពន្ធ និងបង់ប្រាក់ពន្ធយ៉ាងយឺតបំផុតត្រឹម ថ្ងៃទី២០ នៃខែបន្ទាប់ពីខែត្រូវបង់។ កាលបរិច្ឆេទកំណត់នៃការបង់ប្រាក់ពន្ធ និង ដាក់លិខិតប្រកាសពន្ធប្រចាំខែសំរាប់ប្រភេទពន្ធមួយចំនួនមានដូចជា ៖

១- ប្រាក់រំដោះពន្ធលើប្រាក់ចំណូល

២- ពន្ធលើប្រាក់បៀវត្ស

៣- ពន្ធកាត់ទុកគ្រប់ប្រភេទ

៤- អាករលើតម្លៃបន្ថែម

៥- អាករពិសេសលើទំនិញ និងសេវាមួយចំនួន

៦- អាករលើការស្នាក់នៅ

៧- អាករសម្រាប់បំភ្លឺសាធារណៈ។[3]

➢ កាលបរិច្ឆេទកំណត់ដាក់លិខិតប្រកាសពន្ធប្រចាំឆ្នាំ

អ្នកជាប់ពន្ធត្រូវដាក់លិខិតប្រកាសពន្ធប្រចាំឆ្នាំ និងបង់ប្រាក់ពន្ធឲ្យបានយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ៣១ ខែមីនា នៃឆ្នាំបន្ទាប់ ចំពោះ៖

– ពន្ធលើប្រាក់ចំណូល ត្រូវដាក់លិខិតប្រកាសពន្ធ និងបង់ប្រាក់ពន្ធឲ្យបានយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ៣១ ខែមីនា នៃឆ្នាំបន្ទាប់ពីឆ្នាំដែលជាប់ពន្ធ។
– ពន្ធប៉ាតង់ត្រូវដាក់លិខិតប្រកាសពន្ធ និងបង់ប្រាក់ពន្ធឲ្យបានយ៉ាងយឺតបំផុតត្រឹម ថ្ងៃទី ៣១ ខែមីនា នៃឆ្នាំនីមួយៗ។

[2] ព្រះរាជក្រម នស/រកម/០២៩៧/០៣, ប្រកាសស្តីពី សារពើពន្ធ, ៨ មករា ១៩៩៧,មាត្រា៣២

[3] ប្រកាសស្តីពីការកែសម្រួលកាលបរិច្ឆេទដាក់លិខិតប្រកាសពន្ធប្រចាំខែ, លេខ១៥៣៩សហវ/ប្រ.ក, ២៣ ធ្នូ ២០១៦

- ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទត្រូវប្រមូលចាប់ពី ថ្ងៃទី០១ ខែមិថុនា រហូតដល់ថ្ងៃទី ៣០ ខែវិច្ឆិកា នៃឆ្នាំនីមួយៗ។
- ពន្ធលើដីធ្លីមិនបានប្រើប្រាស់ត្រូវបង់យ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣០ ខែកញ្ញានៃឆ្នាំប្រមូលពន្ធនីមួយៗ។
- ពន្ធលើអចលនទ្រព្យត្រូវដាក់លិខិតប្រកាសពន្ធ និងបង់ពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣០ ខែកញ្ញា នៃឆ្នាំជាប់ពន្ធនីមួយៗ។
- រយៈពេលនៃការបង់ពន្ធតែមប្រ៍
  - ប័ណ្ណប្រកាសធ្វើពីក្រដាស ក្រណាត់ ឬវត្ថុផ្សេងៗ ត្រូវដាក់លិខិតប្រកាសបង់ពន្ធ ១៥ថ្ងៃ ក្រោយពីធ្វើការផ្សព្វផ្សាយ
  - ស្លាកអាជីវកម្ម ផ្ទាំងអក្សរ ផ្ទាំងរូបភាព ត្រូវប្រកាសបង់ពន្ធ ចាប់ពីថ្ងៃទី០១ មករា ដល់ ថ្ងៃទី ៣១មីនា នៃឆ្នាំសារពើពន្ធ
  - ចំពោះស្លាកយីហោដែលផលិតថ្មី ក្រោយថ្ងៃទី ៣១ មីនា ត្រូវដាក់លិខិតប្រកាសបង់ពន្ធ ១៥ថ្ងៃ ក្រោយពីធ្វើការផ្សព្វផ្សាយ
  - ចំពោះស្លាកអាជីវកម្ម និងផ្ទាំងអក្សរ ឬរូបភាព ក្នុងគោលបំណងផ្សាយពាណិជ្ជកម្ម ដែលផលិតថ្មីត្រូវដាក់លិខិតប្រកាសបង់ពន្ធ ១៥ថ្ងៃ ក្រោយពីធ្វើការផ្សព្វផ្សាយ
    - ៦ខែដើមឆ្នាំ ត្រូវបង់ពន្ធ ១០០%
    - ៦ខែចុងឆ្នាំ ត្រូវបង់ពន្ធ ៥០%

## ១.៧.ទោសទណ្ឌសារពើពន្ធ

### ១.៧.១.បទល្មើសបទប្បញ្ញត្តិស្តីពីពន្ធដារ

អំពើរាំងស្ទះការអនុវត្តន៍បទប្បញ្ញត្តិស្តីពីពន្ធដាររួមមានៈ

- មិនបានរក្សាបញ្ជីកាគណនេយ្យ និងឯកសារផ្សេងទៀត ឬមិនបានចេញវិក្កយបត្រលើកិច្ចការជំនួញ
- មិនអនុញ្ញាតឲ្យរដ្ឋបាលសារពើពន្ធធ្វើការពិនិត្យបញ្ជីកាគណនេយ្យ ឬឯកសារផ្សេងៗ
- មិនបានចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ
- មិនបានជូនដំណឹងដល់រដ្ឋបាលសារពើពន្ធអំពីការផ្លាស់ប្តូរក្នុងការចុះបញ្ជី
- កសាង ឬផ្តល់កំណត់ត្រា ឯកសារ របាយការណ៍ ឬព័ត៌មានក្លែងបន្លំផ្សេងៗ

- លាក់ទុក ឬបំផ្លាញដោយចេតនានូវបញ្ជីគណនេយ្យ កំណត់ត្រាឯកសាររបាយការណ៍ ឬព័ត៌មានផ្សេងៗទៀត
- ព្យាយាមធ្វើឲ្យរាំងស្ទះដល់ការកំណត់ពន្ធ និងការប្រមូលពន្ធ
- មិនបានដាក់លិខិតប្រកាសសារពើពន្ធ ដែលគ្មានប្រាក់ពន្ធត្រូវបង់ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយកាលបរិច្ឆេទច្បាប់បានកំណត់
- ជួយជ្រោមជ្រែងដោយចេតនាដល់អំពើទាំងឡាយខាងលើ។[4]

## ១.៧.២.ពន្ធបន្ថែម និងការប្រាក់

- ត្រូវបានចាត់ទុកជាការធ្វេសប្រហែស ប្រសិនបើប្រាក់ពន្ធដែលបានបង់មានចំនួនតិចជាងប្រាក់ពន្ធដែលត្រូវបង់ មិនលើសពី ១០% ឬមិនបានដាក់លិខិតប្រកាសពន្ធ ឬមិនបានបង់ពន្ធតាមកាលបរិច្ឆេទដែលច្បាប់បានកំណត់ ត្រូវទទួលរងពិន័យ៖
  - ប្រាក់ពន្ធបន្ថែម តាមអត្រា ១០%
  - ការប្រាក់បន្ថែម ១.៥% ចាប់គិតពីថ្ងៃទី០១ នៃខែបន្ទាប់ពីខែដែលបានបង់ពន្ធខ្វះ
- ត្រូវបានចាត់ទុកជាការធ្វេសប្រហែសធ្ងន់ធ្ងរ ប្រសិនបើប្រាក់ពន្ធដែលបានបង់មានចំនួនតិចជាងប្រាក់ពន្ធដែលត្រូវបង់ លើសពី ១០% ត្រូវទទួលរងពិន័យ៖
  - ប្រាក់ពន្ធបន្ថែម តាមអត្រា ២៥%
  - ការប្រាក់បន្ថែម ១.៥% ចាប់គិតពីថ្ងៃទី០១ នៃខែបន្ទាប់ពីខែដែលបានបង់ពន្ធខ្វះ
- ត្រូវបានកំណត់ពន្ធជាឯកតោភាគី ក្នុងករណីដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកមិនបានដាក់លិខិតប្រកាសសារពើពន្ធតាមការតម្រូវនៃច្បាប់ មិនបានធ្វើការចុះបញ្ជី មិនបានកាន់កាប់ កត់ត្រារក្សាទុកបានត្រឹមត្រូវនូវបញ្ជីគណនេយ្យ ឬឯកសារផ្សេងៗទៀតតាមការតម្រូវ មិនបានផ្តល់ព័ត៌មានចាំបាច់ជូនរដ្ឋបាលសារពើពន្ធ ដើម្បីកំណត់ពន្ធឲ្យបានត្រឹមត្រូវក្នុងរយៈពេល៣០ថ្ងៃ ក្រោយកាលបរិច្ឆេទប្រគល់លិខិតរបស់រដ្ឋបាលសារពើពន្ធស្នើសុំឲ្យអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកឆ្លើយតប ឬផ្តល់លិខិតគតិយុត្តិការបញ្ជាក់លើចំណុចណាមួយនៃលិខិតប្រកាសសារពើពន្ធ។បានប្រព្រឹត្តអំពើណាមួយផ្សេងទៀតដែលត្រូវបានចាត់ទុកថាជាការាំងស្ទះដល់ការអនុវត្តន៍បទប្បញ្ញត្តិស្តីពីសារពើពន្ធ។ល។ ត្រូវទទួលរងពិន័យ៖

[4] ច្បាប់ស្តីពីសារពើពន្ធឆ្នាំ១៩៩៧, មាត្រា១២៨

- ប្រាក់ពន្ធបន្ថែម តាមអត្រា ៥០%
- ការប្រាក់ តាមអត្រា ១.៥% គិតពីថ្ងៃទី ០១ នៃខែបន្ទាប់ពីខែដែលបានបង់ពន្ធខ្វះ។

## ១.៨.ប្រភេទពន្ធសំខាន់ៗនៅកម្ពុជា

### ១.៨.១.ពន្ធលើដីធ្លីមិនបានប្រើប្រាស់

**ក.គោលបំណង**

- ទប់ស្កាត់រាល់រូបភាពទិញទុកមិនប្រើប្រាស់ រងចាំពេលឡើងថ្លៃលក់កំរៃលើស
- ជំរុញការប្រើប្រាស់ដីធ្លីឲ្យបានសមរម្យ
- រួមចំណែកដើម្បីជាផលប្រយោជន៍ដល់ថវិកាជាតិ

**ខ.មូលដ្ឋានកំណត់ពន្ធ**

មូលដ្ឋានកំណត់ពន្ធគឺ ជាថ្លៃដីគិតតាមថ្លៃទីផ្សារតាមទីក្រុងនិងតាមតំបន់នីមួយៗ ដែលវាយតម្លៃទៅតាមតម្លៃគិតក្នុងមួយម៉ែត្រក្រឡា កំណត់ដោយគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់។[5]

**គ.អត្រាពន្ធ**

ពន្ធនេះត្រូវបានកំណត់តាមអត្រា ២% នៃមូលដ្ឋានកំណត់ពន្ធ[6]

**ឃ.ការគណនាប្រាក់ពន្ធ**

ប្រាក់ពន្ធត្រូវបង់ = ផ្ទៃដីសរុបxមូលដ្ឋានកំណត់ពន្ធ (តម្លៃដី/ម$^{២}$)x២%

**ង.ការលើកលែងពន្ធ**

ដីទាំងឡាយណាដែលមានលក្ខណៈណាមួយនៃលក្ខណៈខាងក្រោមនេះ មិនត្រូវបានជាប់ពន្ធលើដីធ្លីមិនបានប្រប្រាស់នោះទេ៖

- ដីមានសំណង់ស្ថិតក្នុងតំបន់លំនៅដ្ឋាន ដែលកម្មសិទ្ធិករប្រើប្រាស់ជាកន្លែងស្នាក់នៅជាសំខាន់របស់ខ្លួន និងបានស្នាក់នៅកន្លែងនេះចំនួន ១៨៣ថ្ងៃ ឬច្រើនជាង គិតចាប់ពីថ្ងៃទី ០១ តុលានៃឆ្នាំកន្លងទៅរហូតដល់ថ្ងៃទី៣០កញ្ញា នៃឆ្នាំប្រមូលពន្ធ។
- ដីជួលដែលមានសំណង់មានការកាន់កាប់ ដែលផ្តល់លាភការប្រចាំខែលើសពី ៨០% នៃចំនួនមួយភាគដប់ពីរ នៃតម្លៃដីនៅក្នុងឆ្នាំប្រមូលពន្ធ គុណនឹងមេគុណដែលកំណត់ដោយប្រកាសរបស់ ក.ស.ហ.វ។
- ដីដែលមានសកម្មភាពសេដ្ឋកិច្ចស្របតាមការកំណត់តំបន់របស់រដ្ឋហើយដែលបានប្រាក់

[5] ច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ១៩៩៥, មាត្រា ៣០ ថ្មី

[6] មាត្រា ៣១ ,ច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ១៩៩៥

ចំណូលប្រចាំខែពីសកម្មភាពនោះលើសពីចំនួន៨០% នៃចំនួនមួយភាគដប់ពីរ នៃតម្លៃដីនៅក្នុងឆ្នាំប្រមូលពន្ធ គុណនឹងមេគុណដែលកំណត់ដោយប្រកាសរបស់ ក.ស.ហ.វ។

- ដីជាកម្មសិទ្ធិរបស់រដ្ឋដែលបានជួលទៅឲ្យនីតិបុគ្គល ឬរូបវន្តបុគ្គលណាមួយ ហើយដីនោះមានលក្ខណៈណាមួយនៃចំណុចទាំង ៣ខាងលើ។
- ដីដែលស្ថិតក្រោមកិច្ចព្រមព្រៀងវិនិយោគ ហើយសកម្មភាពមិនទាន់បានចាប់ផ្តើមដោយប្រធានសក្តិ ឬដោយមូលហេតុការរងគ្រោះដោយប្រការអ្វីមួយ ដូចជាអសន្តិសុខ ហើយការពន្យាពេលនោះ ត្រូវបានទទួលការយល់ព្រមពីស្ថាប័នជំនាញមាន សមត្ថកិច្ច និង ក.ស.ហ.វ។[7]

### ១.៨.២.ពន្ធលើឈ្នួលផ្ទះ និងដី

#### ក.និយមន័យ

- ពន្ធលើឈ្នួលផ្ទះ និងដីត្រូវបានកំណត់យកលើប្រាក់ឈ្នួលដែលបានមកពីការជួល
- អគារដែលសង់លើដី ដូចជា ផ្ទះ រោងចក្រ សណ្ឋាគារ ការិយាល័យ ។ល។
- ហត្ថបបករណ៍ដែលជាប់ជាមួយគ្រឹះស្ថានឧស្សាហកម្ម
- ឋាបនភ័ណ្ឌពាណិជកម្ម ឧស្សាហកម្ម ដែលនៅនឹងមួយកន្លែង អគារធំៗដែលទុកដាក់ធាតុរាវឬផលិតផលផ្សេងៗដូចជាប្រេងឥន្ធនៈ កៅស៊ូចាក់ថ្នល់ គ្រាប់ធញ្ញជាតិ
- ផ្ទះអណ្តែតទឹក កប៉ាល់សំរាប់ធ្វើជាលំនៅដ្ឋាន ឬ ដើម្បីប្រកបអាជីវកម្មផ្សេងៗ
- ដីធ្លី ដែលគ្មានសំណង់ ដោយរាប់បញ្ចូលទាំងកន្លែង យកថ្ម យករ៉ែ ធ្យូងថ្ម បឹងបួរ ស្រែអំបិល។[8]

#### ខ.បុគ្គលជាប់ពន្ធ

ពន្ធលើឈ្នួលផ្ទះ និង ដីត្រូវប្រមូលពីកម្មសិទ្ធករ ឬ សិទ្ធិវន្តរបស់កម្មសិទ្ធិករ។[9]

#### គ.មូលដ្ឋានគិតពន្ធ

- មូលដ្ឋានគិតពន្ធនេះ ផ្អែកលើថ្លៃជួលដុលសរុបប្រចាំខែ
- ថ្លៃជួលដុល សំដៅលើតម្លៃដែលបានកំណត់ក្នុងកិច្ចសន្យា ឬតម្លៃដែលបានឯកភាពគ្នា

[7] ប្រកាសលេខ ២២៤ ប្រក.សហវ.ពដ ចុះថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ១៩៩៦ ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់

[8] ច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ១៩៩៤ មាត្រា២៦ ទំព័រ៦

[9] ច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ១៩៩៤ មាត្រា២៨ ទំព័រ៦

រវាងអ្នកជួល និងម្ចាស់កម្មសិទ្ធិ

- ប្រាក់កក់ធានា មិនត្រូវបានរាប់បញ្ចូលក្នុងថ្លៃជួលដុលទេ

**ឃ.អត្រាពន្ធ**

អត្រាពន្ធលើឈ្នួលផ្ទះ និង ដី ត្រូវបានកំណត់ស្មើនឹង ១០ភាគរយនៃប្រាក់ឈ្នួលដុល។[10]

**ខ.ការគណនាពន្ធ**

ប្រាក់ពន្ធត្រូវបង់ = មូលដ្ឋានគិតពន្ធ x ១០%

**ច.ការលើកលែងពន្ធ**

- ប្រាក់ឈ្នួលផ្ទះ និង ដី ដែលបានគិតបញ្ចូលក្នុងប្រាក់ចំនេញ នៃសហគ្រាស ឧស្សាហាកម្ម សិប្បកម្ម កសិកម្ម ពាណិជ្ជកម្ម ឬ មុខរបរអពាណិជ្ជកម្មណាមួយ ដែលស្ថិតក្នុងក្របខ័ណ្ឌត្រូវយកពន្ធលើប្រាក់ចំនេញតាមរបបស្វ័យប្រកាស
- ប្រាក់ដែលអ្នកជួលបានតំកល់ទុកធ្វើប្រាក់ធានា ហើយនៅពេលចប់កិច្ចសន្យា កម្មសិទ្ធិករត្រូវប្រគល់ឲ្យអ្នកជួលវិញ។[11]
- ត្រូវបានលើកលែងមិនប្រមូលពន្ធ លើឈ្នួលផ្ទះ និងដី ចំពោះគ្រប់ករណីជួលទាំងឡាយដែលសរុបប្រាក់ឈ្នួលប្រចាំខែ ក្រោម ៥០០ ០០០រ។[12]

**១.៨.៣.ពន្ធប្រថាប់ត្រា**

**ក.និយមន័យ**

ពន្ធប្រថាប់ត្រាត្រូវបានប្រមូលចំពោះ៖

- ការផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់អចលនទ្រព្យ ឬការដាក់ភាគហ៊ុនជាអចលនទ្រព្យក្នុងក្រុមហ៊ុន និងការផ្ទេរកម្មសិទ្ធិ ឬសិទ្ធកាន់កាប់មធ្យោបាយដឹកជញ្ជូន ឬយានយន្តគ្រប់ប្រភេទ
- ការផ្ទេរចំណែកណាមួយ ឬទាំងស្រុងនៃភាគហ៊ុនរបស់ក្រុមហ៊ុន
- កិច្ចសន្យាផ្គត់ផ្គង់ទំនិញឬសេវាដែលប្រើប្រាស់ថវិការដ្ឋ
- លិខិតមានលក្ខណៈគតិយុត្តជាអាទ៍ លិខិតស្តីពីការបង្កើតក្រុមហ៊ុន លិខិតស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងលិខិតស្តីពីការបិទក្រុមហ៊ុន។

[10] ច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ១៩៩៤ មាត្រា២៩ ទំព័រ៦

[11] ច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ១៩៩៤ មាត្រា២៧ ទំព័រ៦

[12] ដកស្រង់ចេញពីប្រកាសលេខ ០២១ប្រក.សហវ ចុះ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៩៤

**ខ.អត្រាពន្ធ**

អត្រាពន្ធ និងការកំណត់ពន្ធប្រថាប់ត្រា មានដូចខាងក្រោម៖

- ៤% នៃតម្លៃអចលនទ្រព្យចំពោះការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យជា សំណង់ ឬនិងដី ឬការដាក់ភាគហ៊ុនជាអចលនទ្រព្យក្នុងក្រុមហ៊ុន។
- ៤% នៃតម្លៃមធ្យោបាយដឹកជញ្ជូន ឬយានយន្ត ចំពោះការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់មធ្យោបាយដឹកជញ្ជូន ឬយានយន្តគ្រប់ប្រភេទ។
- ០.១% នៃតម្លៃភាគហ៊ុន ចំពោះការផ្ទេរចំណែកណាមួយ ឬទាំងស្រុងនៃភាគហ៊ុន ឬការរំលាយក្រុមហ៊ុនបញ្ចូលគ្នា។
- ០.១% នៃតម្លៃចុះកិច្ចសន្យាចំពោះកិច្ចសន្យាផ្គត់ផ្គង់ទំនិញ ឬសេវា ដែលប្រើប្រាស់ថវិការដ្ឋ។
- ១ ០០០ ០០០ (មួយលាន) រៀល ចំពោះលិខិតមានលក្ខណៈគតិយុត្ត ៣ប្រភេទគឺ លិខិតស្តីពីកាបង្កើតក្រុមហ៊ុន លិខិតស្តីពីការបិទក្រុមហ៊ុន លិខិតស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា រួមទាំងលិខិតស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នារបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រសាធារណៈ។

**គ.មូលដ្ឋានគិតពន្ធ**

តម្លៃជាមូលដ្ឋានសម្រាប់គិតពន្ធប្រថាប់ត្រាត្រូវបានកំណត់ ដូចខាងក្រោម៖

- អចលនទ្រព្យ និងមធ្យោបាយដឹកជញ្ជូនឬយានយន្ត ត្រូវគិតតាមតម្លៃទីផ្សារនាពេលផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងកំណត់តម្លៃអចលនទ្រព្យ និងតម្លៃមធ្យោបាយដឹកជញ្ជូនឬយានយន្ត សម្រាប់ធ្វើជាមូលដ្ឋានគិតពន្ធនេះ។
- ភាគហ៊ុនត្រូវគិតតាមតម្លៃទីផ្សារនាពេលប្រតិបត្តិការផ្ទេរភាគហ៊ុននោះកើតឡើង។
- កិច្ចសន្យាត្រូវគិតតាមតម្លៃក្នុងកិច្ចសន្យាផ្គត់ផ្គង់ទំនិញឬសេវា
- លិខិតមានលក្ខណៈគតិយុត្តត្រូវកំណត់ ១ ០០០ ០០០ (មួយលាន) រៀល ចំពោះលិខិតមានលក្ខណៈគតិយុត្តនីមួយៗ។

**ឃ.ការលើកលែង និង ការអនុគ្រោះពន្ធប្រថាប់ត្រា**

ពន្ធប្រថាប់ត្រាត្រូវបានលើកលែងចំពោះ៖

- ការទទួលកម្មសិទ្ធិ ឬ សិទ្ធកាន់កាប់អចលនទ្រព្យ ជាសំណង់ ឬ/និង ដី ដែរ៖
    - ការធ្វើសន្តតិកម្ម រវាងឪពុក-ម្តាយបង្កើត និងកូនបង្កើតនិងកូនប្រសារ រវាងប្តីនិងប្រពន្ធ រវាងយាយ-តាបង្កើតនិងចៅបង្កើតនិងចៅប្រសារ

  - ការធ្វើប្រទានកម្មលើកទី១ រវាងឪពុក-ម្ដាយ និងកូនបង្កើតនិងកូនប្រសារ រវាងប្ដីនិងប្រពន្ធ រវាងយាយ-តាបង្កើតនិងចៅបង្កើតនិងចៅប្រសារ
- ការផ្ទេរកម្មសិទ្ធិទោចក្រយានយន្ត ត្រីចក្រយានយន្តគ្រប់ប្រភេទ ត្រាក់ទ័រ និងជលយានគ្រប់ប្រភេទដែលមានកម្លាំងដល់ ១៥០ សេះ
- ការទទួលកម្មសិទ្ធ ឬសិទ្ធកាន់កាប់
  - ដីសម្បទានសេដ្ឋកិច្ច ឬសង្គមកិច្ច ដល់ជនក្រីក្រសង់លំនៅដ្ឋានឬ/និងធ្វើកសិ-ឧស្សាហកម្ម ឬកសិកម្មលក្ខណ:គ្រួសារ
  - អចលនទ្រព្យ និង ម.ធ.ប ឬយានយន្ត ដែលចុះបញ្ជីសារពើភ័ណ្ឌរបស់ស្ថាប័នរដ្ឋបេសកកម្មការទូត ឬកុងស៊ុលបរទេស ឬអង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេស របស់រដ្ឋាភិបាលនានា
- ការទិញ ម.ធ.ប ឬយានយន្ត របស់សហគ្រាស ដើម្បីធ្វើជាទំនិញសម្រាប់លក់វិញ
- អ្នកវិនិយោគលើវិស័យមូលបត្រដែលទទួលសិទ្ធិកាន់កាប់ភាគហ៊ុនតាមរយ:ការជួញដូរមូលបត្រក្នុងទីផ្សារដំបូង ឬក្នុងទីផ្សារបន្ទាប់

**ការអនុគ្រោះពន្ធប្រថាប់ត្រា**

ពន្ធប្រថាប់ត្រាធ្វើការអនុគ្រោះចំពោះ៖

- ការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់រវាងបងបង្អូនបង្កើត
  - ចំពោះសន្តិកម្ម អនុញ្ញាតឲ្យដកចេញពីតម្លៃមូលដ្ឋានគិតពន្ធចំនួន ២០០ ០០០ ០០០ រៀល (ពីររយលានរៀល)
  - ចំពោះប្រទានកម្ម អនុញ្ញាតឲ្យដកចេញពីតម្លៃមូលដ្ឋានគិតពន្ធចំនួន ១០០ ០០០ ០០០ រៀល (មួយរយលានរៀល)
- ការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ អចលនទ្រព្យដដែល ជាប្រទានកម្មក្នុងរង្វង់ញាតិ រវាងឪពុកម្ដាយបង្កើត និងកូនបង្កើត រវាងប្ដីនិងប្រពន្ធ រវាងយាយតាបង្កើត និងចៅបង្កើត (ចាប់ពីលើកទី២តទៅ) ត្រូវបានអនុញ្ញាតឲ្យដកចេញពីតម្លៃមូលដ្ឋានគិតពន្ធចំនួន ១០០ ០០០ ០០០ រៀល (មួយរយលានរៀល)
- ការអនុញ្ញាតនេះត្រូវមានឯកសារភស្តុតាងបញ្ជាក់។

**ខ.អ្នកទទួលបន្ទុកបង់ពន្ធ**

ពន្ធប្រថាប់ត្រាត្រូវប្រមូលពីៈ

- អ្នកទទួលកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ
- អ្នកទទួលសិទ្ធិកាន់កាប់មធ្យោបាយដឹកជញ្ជូន ឬយានយន្តគ្រប់ប្រភេទ
- អ្នកទទួលសិទ្ធិកាន់កាប់ភាគហ៊ុន
- អ្នកទទួលចុះកិច្ចសន្យាផ្គត់ផ្គង់ទំនិញ ឬសេវា ដែលប្រើប្រាស់ថវិការរដ្ឋ
- អ្នកទទួលសិទ្ធិលើលិខិតមានលក្ខណៈគតិយុត្តិ។[13]

**១.៨.៤.ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ**

ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ ត្រូវប្រមូល ក្នុងមួយឆ្នាំមួយដង។

**ខ.ការកំណត់ប្រាក់ពន្ធ**

យោងតាមប្រកាសលេខ ៥៣១សហវ ប្រក ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទប្រចាំឆ្នាំ។

- **ការកំណត់ប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូនទូទៅ**

**តារាងទី១៖ ការកំណត់ប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូនទូទៅ**

| ប្រភេទមធ្យោបាយដឹកជញ្ជូន និងយានជំនិះ | អត្រាប្រាក់ពន្ធ សម្រាប់១/ឆ្នាំ/គ្រឿង |
|---|---|
| ១. រថយន្តដឹកទំនិញមានទម្ងន់សរុប [ទម្ងន់រថយន្ត និងទម្ងន់ផ្ទុក (ទំនិញ និងមនុស្ស)] ៖ | |
| - ដល់ ៣តោន | ២០០ ០០០ |
| - លើសពី ៣តោន ដល់ ១០តោន | ៥០០ ០០០ |
| - លើសពី ១០តោន ដល់ ២០តោន | ១ ០០០ ០០០ |
| - លើសពី ២០តោន | ២ ០០០ ០០០ |
| ២. រ៉ឺម៉កសណ្តោងដែលមានទម្ងន់សរុប (ទម្ងន់រ៉ឺម៉ក់ និងទម្ងន់ផ្ទុក) ៖ | |
| - ចាប់ពី ៣តោន ដល់ ១០តោន | ៥០០ ០០០ |

[13] ប្រកាសស្តីពីការប្រមូលពន្ធប្រថាប់ត្រា,លេខ ៥០៧ សហវ.ប្រក ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ២០១៧ និង ប្រកាសស្តីពីការកំណត់មូលដ្ឋានគិតពន្ធប្រថាប់ត្រាចំពោះការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ,លេខ ៣៤៣ សហវ.ប្រក ចុះថ្ងៃទី ២២ ខែមីនា ឆ្នាំ២០១៩

| | |
|---|---|
| - លើសពី ១០តោន ដល់ ២០តោន | ១ ០០០ ០០០ |
| - លើសពី ២០តោន | ២ ០០០ ០០០ |
| **៣. រថយន្តដឹកអ្នកដំណើរ ៖** | |
| - រថយន្តដឹកអ្នកដំណើរមានកៅអីដល់ ១៥កៅអី | ១៥០ ០០០ |
| - រថយន្តដឹកអ្នកដំណើរធុនមធ្យម មានកៅអីពី ១៦កៅអី ដល់ ២៥កៅអី | ២០០ ០០០ |
| - រថយន្តដឹកអ្នកដំណើរធុនធំ មានកៅអីលើសពី ២៥កៅអី | ២៥០ ០០០ |
| **៤. ជលយាន ឬជលយានយន្ត ផ្លូវទន្លេ ៖** | |
| - **ជលយាន ឬជលយានយន្តដឹកទំនិញ ៖** | |
| + ដល់ ៣តោន | ៥០ ០០០ |
| + លើសពី ៣តោន ដល់ ១០តោន | ១០០ ០០០ |
| + លើសពី ១០តោន ដល់ ២០តោន | ២០០ ០០០ |
| + លើសពី ២០តោន | ៣០០ ០០០ |
| – **ជលយាន ឬជលយានដឹកអ្នកដំណើរ ៖** | |
| + កប៉ាល់មានបណ្ដោយដល់ ២០ម៉ែត្រ | ១០០ ០០០ |
| + កប៉ាល់មានបណ្ដោយលើសពី ២០ម៉ែត្រ | ២០០ ០០០ |
| + កប៉ាល់មានបណ្ដោយលើសពី ៣០ម៉ែត្រ ឡើងទៅ | ៣០០ ០០០ |
| - **ជលយាន ឬជលយានយន្តសណ្ដោង ៖** | |
| + កប៉ាល់មានកម្លាំងលើសពី ១៥០សេះ ដល់ ២០០សេះ | ៦០ ០០០ |
| + កប៉ាល់មានកម្លាំងលើសពី ២០០សេះ ដល់ ២៥០សេះ | ១៨០ ០០០ |
| + កប៉ាល់មានកម្លាំងលើសពី ២៥០សេះ ឡើងទៅ | ៣០០ ០០០ |
| - **ជលយាន ឬជលយានយន្តនេសាទ ៖** | |
| + កាណូតមានកម្លាំងលើសពី ១៥០សេះ ដល់ ២០០សេះ | ៦០ ០០០ |
| + កាណូតមានកម្លាំងលើសពី ២០០សេះ ដល់ ២៥០សេះ | ១៨០ ០០០ |
| + កាណូតមានកម្លាំងលើសពី ២៥០សេះ ឡើងទៅ | ៣០០ ០០០ |
| **៥. ជលយាន ឬជលយានយន្តសមុទ្រ ៖** | |
| - **ជលយាន ឬជលយានយន្តដឹកអ្នកដំណើរ ៖** | |
| + ទូកមានបណ្ដោយដល់ ២០ម៉ែត្រ | ១០០ ០០០ |
| + ទូកមានបណ្ដោយពី ២១ម៉ែត្រ ដល់ ៣០ម៉ែត្រ | ១៥០ ០០០ |

| | |
|---|---|
| - **ជលយាន ឬជលយានយន្តដឹកទំនិញ ៖** | |
| +ទូកផ្ទុកទំនិញដល់ ១០០តោន | ២០០ ០០០ |
| + កប៉ាល់ផ្ទុកទំនិញលើសពី ១០០តោន ដល់ ១ ០០០តោន | ៣០០ ០០០ |
| + កប៉ាល់ផ្ទុកទំនិញលើសពី ១ ០០០តោន ដល់ ២ ០០០តោន | ៧៥០ ០០០ |
| + កប៉ាល់ផ្ទុកទំនិញលើសពី ២ ០០០តោន ឡើងទៅ | ១ ២០០ ០០០ |
| - **ជលយាន ឬជលយានយន្តនេសាទ ៖** | |
| + ទូកមានកម្លាំងលើសពី ១៥០សេះ ឡើងទៅ | ១០០ ០០០ |
| + កប៉ាល់មានកម្លាំងលើសពី ១៥០សេះ ដល់ ២៥០សេះ | ៤០០ ០០០ |
| + កប៉ាល់មានកម្លាំងលើសពី ២៥០សេះ ដល់ ៥០០សេះ | ៦០០ ០០០ |
| + កប៉ាល់មានកម្លាំងលើសពី ៥០០សេះឡើងទៅ | ១ ២០០ ០០០ |
| - **ជលយាន ឬជលយានយន្តសណ្តោង ៖** | |
| + កប៉ាល់មានកម្លាំងដល់ ២៥០សេះ | ២០០ ០០០ |
| + កប៉ាល់មានកម្លាំងលើសពី ២៥០សេះ ដល់ ៥០០សេះ | ៤០០ ០០០ |
| + កប៉ាល់មានកម្លាំងលើសពី ៥០០សេះ ឡើងទៅ | ៦០០ ០០០ |
| **៦. អូប័រផ្លូវទន្លេ/សមុទ្រ ៖** | |
| - មានកម្លាំងលើសពី ១៥០សេះ ដល់ ២០០សេះ | ៤០០ ០០០ |
| - មានកម្លាំងលើសពី ២០០សេះ ឡើងទៅ | ៥០០ ០០០ |

- **ការកំណត់ប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូនកែច្នៃផ្សេងទៀត ៖**

**តារាងទី២៖ ការកំណត់ប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូនកែច្នៃផ្សេងទៀត**

| **ប្រភេទមធ្យោបាយដឹកជញ្ជូន និងយានជំនិះ** | **កម្រិតប្រាក់ពន្ធ សម្រាប់១ឆ្នាំ/គ្រឿង** |
|---|---|
| ១. រថយន្តដែលបំប្លែងមកពីគោយន្ត និងរថយន្តកែច្នៃកង់បី (បំពាក់ដោយម៉ាស៊ីនរថយន្ត)ត្រូវកំណត់ជារថយន្តដឹកទំនិញដល់ ៣តោន | ២០០ ០០០ |
| ២. រ៉ឺម៉ក់សណ្តោងដែលមានភ្លៅកង់៤( ចាត់ទុកដូចរថយន្តកែច្នៃខាងលើ) | ២០០ ០០០ |
| ៣. រ៉ឺម៉ក់សណ្តោងដែលមានភ្លៅ២ កង់៨ | ៥០០ ០០០ |
| ៤. រថយន្តដឹកទំនិញដែលមានភ្លៅ៣ កង់៦ | ១ ០០០ ០០០ |
| ៥. រថយន្តដែលដឹកទំនិញធុនធ្ងន់ដែលមានភ្លៅ៣ កង់១០ | ២ ០០០ ០០០ |

– **ការកំណត់ប្រាក់ពន្ធតាមទំហំស៊ីឡាំងរបស់រថយន្តទេសចរណ៍**

**តារាងទី៣៖ ការកំណត់ប្រាក់ពន្ធតាមទំហំស៊ីឡាំងរបស់រថយន្តទេសចរណ៍**

| ល.រ | ទំហំស៊ីឡាំងគិតជា ស.ម³ "CC" | គិតពីឆ្នាំផលិត | | |
|---|---|---|---|---|
| | | ដល់ ៥ឆ្នាំ | លើសពី៥ឆ្នាំ ដល់ ១០ឆ្នាំ | លើសពី ១០ ឆ្នាំ |
| ១ | ដល់ ១ ៥០០ ស.ម³ | ១៥០ ០០០ | ១០០ ០០០ | ៨០ ០០០ |
| ២ | លើសពី ១ ៥០០ស.ម³ ដល់ ២ ០០០ស.ម³ | ២០០ ០០០ | ១៥០ ០០០ | ១០០ ០០០ |
| ៣ | លើសពី ២ ០០០ស.ម³ ដល់ ២ ៩០០ស.ម³ | ៦០០ ០០០ | ៤០០ ០០០ | ២៥០ ០០០ |
| ៤ | លើសពី ២ ៩០០ស.ម³ ដល់ ៤ ០០០ស.ម³ | ១ ៦០០ ០០០ | ១ ០០០ ០០០ | ៦០០ ០០០ |
| ៥ | លើសពី ៤ ០០០ស.ម³ ឡើងទៅ | ២ ០០០០០០ | ១ ២០០ ០០០ | ៨០០ ០០០ |

**គ.ការលើកលែងពន្ធ**

ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ ត្រូវបានលើកលែងចំពោះ ៖

– រថយន្តគិលានសង្គ្រោះ រថយន្តពន្លត់អគ្គីភ័យជាកម្មសិទ្ធិរបស់រដ្ឋ

– យានយន្តដែលជាកម្មសិទ្ធិរបស់អង្គភាពកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ នគរបាលជាតិ ដែលបម្រើការងារសម្រាប់កិច្ចការពារជាតិ ជាមធ្យោបាយប្រើប្រាស់ដឹកជញ្ជូនសម្ភារៈទ័ព ឬដឹកជញ្ជូនកងទ័ព ក៏ដូចជាសម្រាប់កិច្ចការសន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ។

– យានយន្តដែលជាកម្មសិទ្ធិរបស់ស្ថានទូត ឬកុងស៊ុលបរទេស អង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាល។

ក្រសួង-ស្ថាប័ន ឬអង្គភាព ដែលជាអណាព្យាបាល ឬជាម្ចាស់កម្មសិទ្ធិនៃយានយន្ត ត្រូវស្នើសុំមកអគ្គនាយកដ្ឋានពន្ធដារ ដើម្បីទទួលបាននូវលតាបត្របង់ពន្ធ (ពន្ធជាបន្ទុករបស់រដ្ឋ) ដោយភ្ជាប់មកជាមួយនូវបញ្ជីសារពើភណ្ឌយានយន្តរបស់ក្រសួង-ស្ថាប័នឬអង្គភាពដែលបានស្នើសុំ។[14]

## ១.៨.៥.ពន្ធតែមប្រ៊ី

**ក.និយមន័យ**

ពន្ធតែមប្រ៊ី (ស្លាកយីហោ និងផ្ទាំងផ្សាយពាណិជ្ជកម្ម) អនុវត្តលើប័ណ្ណប្រកាសពាណិជ្ជកម្ម ផ្លាកអាជីវកម្ម (យីហោ) ផ្ទាំងអក្សរ ផ្ទាំងរូបភាព ក្នុងគោលបំណងផ្សាយពាណិជ្ជកម្ម ឬគូសភ្ជាប់

[14] ប្រកាសស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទប្រចាំឆ្នាំ, លេខ៥៣២សហវ/ប្រក, ៣០ ឧសភា ២០១៨

និងមធ្យោបាយដឹកជញ្ជូននានា។

**ខ.អត្រាពន្ធ និង មូលដ្ឋានគិតពន្ធ**

ពន្ធតែមប្រិ៍ ត្រូវអនុវត្តចំពោះប័ណ្ណប្រកាស តាមអត្រា ប្រភេទ និងទំហំផ្ទៃក្រឡាដូចខាងក្រោមៈ

**តារាងទី៤ៈ អត្រាពន្ធ ប្រភេទ និងទំហំផ្ទៃក្រឡា ពន្ធតែមប្រិ៍**

<table>
<tr><th>លេខរៀង</th><th>ប្រភេទប័ណ្ណប្រកាស</th><th>អត្រាពន្ធ</th><th colspan="2">លក្ខខណ្ឌបន្ថែម</th></tr>
<tr><td colspan="5">ខ.១. ប័ណ្ណប្រកាសផ្សាយពាណិជ្ជកម្មធ្វើដោយក្រដាសធម្មតា</td></tr>
<tr><td>១</td><td>មានផ្ទៃមិនលើសពី ៤០ ដេស៊ីម៉ែត្រក្រឡា</td><td>៥០០/ទំព័រ</td><td colspan="2">បើមានអក្សរបរទេស ១៥០០/ទំព័រ</td></tr>
<tr><td>២</td><td>មានផ្ទៃលើសពី ៤០ ដេស៊ីម៉ែត្រក្រឡា</td><td>៧០០/ទំព័រ</td><td colspan="2">បើមានអក្សរបរទេស ២ ១០០/ទំព័រ</td></tr>
<tr><td colspan="5">ខ.២. ប័ណ្ណប្រកាសផ្សាយពាណិជ្ជកម្មធ្វើដោយក្រណាត់ ឬវត្ថុ ផ្សេងៗ</td></tr>
<tr><td>៣</td><td>មានផ្ទៃមិនលើសពី ៤០ ដេស៊ីម៉ែត្រក្រឡា</td><td>៧០០/ផ្ទាំង</td><td colspan="2">បើមានអក្សរបរទេស ២ ១០០/ផ្ទាំង</td></tr>
<tr><td>៤</td><td>មានផ្ទៃលើសពី ៤០ ដល់ ១០០ ដេស៊ីម៉ែត្រក្រឡា "បើលើសពី ១០០ដេស៊ីម៉ែត្រក្រឡាត្រូវ គិតជាផ្ទាំងអក្សរ"</td><td>១ ០០០/ផ្ទាំង</td><td colspan="2">បើមានអក្សរបរទេស ៣ ០០០/ផ្ទាំង</td></tr>
<tr><td colspan="5">ខ៣ ស្លាកយីហោអាជីវកម្មដ្ឋាននានា</td></tr>
<tr><td>៥</td><td>គ្មានពន្លឺលើកស្របដងផ្លូវសាធារណៈ</td><td>១០០/ដម$^{២}$/ឆ្នាំ</td><td>២០០</td><td rowspan="4">បើមានអក្សរបរទេសត្រូវគិតបន្ថែម ក្នុងអក្សរមួយតួ និងកម្ពស់មួយដេស៊ីម៉ែត្រឬប្រភាគ</td></tr>
<tr><td>៦</td><td>គ្មានពន្លឺកែងដងផ្លូងសាធារណៈ</td><td>១៥០/ដម$^{២}$/ឆ្នាំ</td><td>៣០០</td></tr>
<tr><td>៧</td><td>មានពន្លឺលើកស្របដងផ្លូវសាធារណៈ</td><td>២០០/ដម$^{២}$/ឆ្នាំ</td><td>៤០០</td></tr>
<tr><td>៨</td><td>មានពន្លឺកែងដងផ្លូវសាធារណៈ</td><td>២៥០/ដម$^{២}$/ឆ្នាំ</td><td>៥០០</td></tr>
<tr><td colspan="5">ខ.៤. ផ្ទាំងអក្សរ ឬ ផ្ទាំងរូបភាព សម្រាប់គោលបំណងពាណិជ្ជកម្ម</td></tr>
<tr><td>៩</td><td>គ្មានពន្លឺលើកស្របដងផ្លូវសាធារណៈ</td><td>៥០០/ដម$^{២}$/ឆ្នាំ</td><td>១ ០០០</td><td rowspan="5">បើមានអក្សរបរទេសត្រូវគិតបន្ថែមក្នុងអក្សរមួយតួ និងក្នុងកម្ពស់មួយដេស៊ីម៉ែត្រ ឬប្រភាគ</td></tr>
<tr><td>១០</td><td>គ្មានពន្លឺកែងដងផ្លូងសាធារណៈ</td><td>១ ៤០០/ដម$^{២}$/ឆ្នាំ</td><td>១ ៤០០</td></tr>
<tr><td>១១</td><td>មានពន្លឺលើកស្របដងផ្លូវសាធារណៈ</td><td>១ ៤០០/ដម$^{២}$/ឆ្នាំ</td><td>១ ៤០០</td></tr>
<tr><td>១២</td><td>មានពន្លឺកែងដងផ្លូវសាធារណៈ</td><td>២ ០០០/ដម$^{២}$/ឆ្នាំ</td><td>២ ០០០</td></tr>
<tr><td>១៣</td><td>ដាក់ភ្ជាប់ឬតភ្ជាប់និងមធ្យោបាយដឹកជញ្ជូននានា</td><td>១ ៥០០/ដម$^{២}$/ឆ្នាំ</td><td>៣ ០០០</td></tr>
</table>

**គ.ការលើកលែងពន្ធ**

ពន្ធតែមប្រិ៍សារពើពន្ធ មិនអនុវត្តចំពោះប័ណ្ណប្រកាស ដែលត្រូវបានផ្សព្វផ្សាយក្នុងគោលបំណង មិនស្វែងរកប្រាក់ចំនេញ ដែលមានជាអាទិ៍ ដូចខាងក្រោម៖

- ស្លាកយីហោក្នុងគោលដៅអប់រំ សង្គម ការពារបរិស្ថាន ការបញ្ឈប់អំពើហឹង្សាក្នុងគ្រួសារ ការពារព្រៃឈើនិងសត្វព្រៃ ការអប់រំស្តីពីច្បាប់ចរាចរណ៍
- ស្លាកយីហោរបស់អង្គការជាតិ និងអន្តរជាតិ
- ស្លាកយីហោរបស់ស្ថាប័នរដ្ឋ។[15]

**១.៧.៦.ពន្ធអចលនទ្រព្យ**

**ក.និយមន័យ**

ពាក្យ "អចលនទ្រព្យ" សំដៅដល់ ដី ផ្ទះ អគារ និង សំណង់ផ្សេងៗដែលសង់ភ្ជាប់នឹងដីនោះ។

១. ដី សំដៅដល់ដី គ្មានសំណង់ និង/ឬ ដីមានសំណង់

២. ផ្ទះ សំដៅដល់ ទីកន្លែងសម្រាប់ស្នាក់នៅ

៣. អគារ និងសំណង់ផ្សេងៗ សំដៅដល់ អគារ និងសំណង់ផ្សេងៗដែលសង់ភ្ជាប់នឹងដី។ ទោះមានឬគ្មានជញ្ជាំង ឬដំបូលក៏ដោយ មានជាអាទិ៍ សណ្ឋាគារ អផាតមែន ខុនដូ ការិយាល័យ រោងចក្រ ឃ្លាំង ផ្សារទំនើប សំណង់អគារឧស្សាហកម្ម ផ្លូវ ស្ពាន ប្រព័ន្ធផលិតទឹកស្អាត ឬផលិតអគ្គិសនី ព្រលានយន្តហោះ កំពង់ផែ ចំណតរថយន្ត។

**ខ.ការលើកលែងពន្ធ**

អចលនទ្រព្យដែលត្រូវលើកលែងពន្ធ មានដូចខាងក្រោម ៖

១. អចលនទ្រព្យដែលជាដីធ្លីកសិកម្ម ។ ក្នុងករណីចំណែកណាមួយនៃដីធ្លីកសិកម្មត្រូវបានយកមកសាងសង់ផ្ទះ អគារ ឬសំណង់ផ្សេងៗ ដែលមិនបម្រើផ្ទាល់និងជាអចិន្ត្រៃយ៍ដល់សកម្មភាពកសិកម្ម ចំណែកដីនោះមិនត្រូវបានលើកលែងពន្ធនេះទេ។

២. អចលនទ្រព្យដែលជាកម្មសិទ្ធិរបស់រាជរដ្ឋាភិបាល ឬស្ថាប័នរាជរដ្ឋាភិបាល។ ក្នុងករណីអចលទ្រព្យដែលកត់ត្រាជាទ្រព្យសកម្មរបស់សហគ្រាសសាធារណៈឬក្រុមហ៊ុនចម្រុះរដ្ឋ អចលនទ្រព្យនោះមិនត្រូវបានលើកលែងពន្ធនេះទេ។

៣. អចលនទ្រព្យដែលជាកម្មសិទ្ធរបស់សហគមន៍ ឬបុគ្គលណាមួយដែល ៖

---

[15] អនុក្រឹត្យស្តីពីការកែសម្រួលតារាងពន្ធតែមប្រិ៍សារពើពន្ធ, លេខ៤០អនក្រ/បក, ៣១ មីនា ២០១៥

- ត្រូវរៀបចំឡើង និងដំណើរការសម្រាប់គោលដៅសុទ្ធសាធខាងសាសនា និង សប្បុរសធម៌
- គ្មានចំណែកណាមួយនៃអចលនទ្រព្យ ឬប្រាក់ចំណូលត្រូវបានប្រើប្រាស់ជាប្រយោជន៍ ឯកជន
- ការលើកលែងពន្ធនេះ មិនរាប់បញ្ចូលទេ ចំពោះ៖
  - អចលនទ្រព្យដែលត្រូវបានជួល ឬផ្តល់ឲ្យបណ្តោះអាសន្ន សម្រាប់គោលដៅ សុទ្ធសាធខាងសាសនា និងសប្បុរសធម៌
  - អចលនទ្រព្យជាកម្មសិទ្ធរបស់អង្គការសាសនា ឬអង្គការសប្បុរសធម៌ ដែល បានជួល ឬផ្តល់ជាបណ្តោះសន្ទឲ្យទៅសហគមន៍ ឬបុគ្គលណាមួយ ដែលប្រើ ប្រាស់អចលនទ្រព្យនោះក្រៅពីគោលដៅសាសនា និងសប្បុរសធម៌។

៤. អចលនទ្រព្យជាកម្មសិទ្ធិរបស់៖
- បេសកកម្មការទូត ឬកុងស៊ុលបរទេស
- អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបរទេសរបស់រដ្ឋាភិបាលនានា ដែលទទួលស្គាល់ដោយរាជរដ្ឋាភិបាល

៥. អចលនទ្រព្យដែលជាហេដ្ឋារចនាសម្ព័ន្ធ រួមមាន ផ្លូវ ស្ពាន ប្រព័ន្ធផលិតទឹកស្អាត ឬផលិតផល អគ្គិសនី ព្រលានយន្តហោះ កំពង់ផែ ស្ថានីយអយស្ម័យយាន រួមបញ្ចូលទាំងអគារ និង ការិយាល័យ ដែលបម្រើផ្ទាល់ដល់សកម្មភាពនៃហេដ្ឋារចនាសម្ព័ន្ធទាំងនេះ។

៦. ផ្ទះ អគារ និងសំណង់ផ្សេងៗដែលសាងសង់លើដីធ្លីកសិកម្ម ដែលបម្រើផ្ទាល់និងជា អចន្ត្រៃយ៍ដល់សកម្មភាពកសិកម្ម។

៧. អចលនទ្រព្យដែលទទួលរងនូវការខូចខាតធ្ងន់ធ្ងរដោយករណីប្រធានសក្តិ ដែលជាបាតុភូត ឬជា ព្រឹត្តិការណ៍កើតឡើងដោយមិនដឹងជាមុន មិនអាចប៉ាន់ស្មានជាមុនបាន និងមិនអាចជំនះ បានដូចជា គ្រោះធម្មជាតិ ( ទឹកជំនន់ ខ្យល់ព្យុះ រញ្ជួយដី ) សង្គ្រាម កុប្បកម្ម អគ្គិភ័យ ឬ គ្រោះមហន្តរាយជាយរថាហេតុ។

៨. ផ្ទះ អគារ និងសំណង់ដែលកំពុងត្រូវបានសាងសង់តិចជាង ៨០% (ប៉ែត្រសិបភាគរយ) និងមិនទាន់បានប្រើប្រាស់។

៩. អចលនទ្រព្យដែលស្ថិតក្នុងតំបន់សេដ្ឋកិច្ចពិសេស ដែលបម្រើផ្ទាល់ដល់សកម្មភាពផលិតកម្ម។

**គ.អត្រាពន្ធ**

ពន្ធលើអសលនទ្រព្យ ត្រូវប្រមូលប្រចាំឆ្នាំតាមអត្រា ០.១% ( សូន្យក្បៀសមួយភាគរយ) លើមូលដ្ឋានគិតពន្ធ។[16]

**ឃ.មូលដ្ឋានគិតពន្ធ**

មូលដ្ឋានគិតពន្ធលើអចលនទ្រព្យ គឺ ៨០ (ប៉ែតសិប) ភាគរយ នៃតម្លៃអចលនទ្រព្យសរុប (ទាំងតម្លៃដី និងតម្លៃសំណង់) ដោយកាត់បន្ថយនូវទឹកប្រាក់ចំនួន ១០០ ០០០ ០០០រៀល (មួយរយលានរៀ)។

តម្លៃអចលនទ្រព្យត្រូវកំណត់ដោយគណៈកម្មការវាយតម្លៃអចលនទ្រព្យ ដោយយោងតាមតម្លៃទីផ្សារ។[17]

**ខ.ការគណនាប្រាក់ពន្ធ**

ប្រាក់ពន្ធត្រូវគណនាតាមរូបមន្តដូចខាងក្រោមៈ

- មូលដ្ឋានគិតពន្ធ = (តម្លៃអចលនទ្រព្យx៨0%) - ១០០ ០០០ ០០០រៀល
- ប្រាក់ពន្ធ = មូលដ្ឋានគិតពន្ធ x 0.១%

**១.៨.៧.ពន្ធអប្បបរមា**

ពន្ធអប្បបរមាជាពន្ធមួយដាច់ដោយឡែក និងផ្សេងពីពន្ធលើប្រាក់ចំណេញ។ ពន្ធនេះត្រូវបង់ដោយអ្នកជាប់ពន្ធ តាមរបបស្វ័យប្រកាសលើកលែងតែគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។ ពន្ធអប្បបរមាត្រូវបង់តាមអត្រា ១ ភាគរយលើផលរបរ ប្រចាំឆ្នាំរួមបញ្ចូលទាំងអាករនានា វៀរលែងតែអាករលើតម្លៃបន្ថែម។ ពន្ធនេះត្រូវបង់នៅពេលទូទាត់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ហើយអាចត្រូវបានកាត់បន្ថយដោយពន្ធលើប្រាក់ចំនេញប្រចាំឆ្នាំ។

រាជរដ្ឋាភិបាលបានសម្រេចចិត្តលើកលែងពន្ធអប្បបរមា ១% ចំពោះគ្រប់សហគ្រាសដែលជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ដែលបានបំពេញកាតព្វកិច្ចសារពើពន្ធត្រឹមត្រូវ ក្នុងគោលបំណងទាក់ទាញ និងលើកទឹកចិត្តដល់វិនិយោគគិនដែលប្រកបអាជីវកម្មនៅព្រះរាជាណាចក្រកម្ពុជា។[18]

---

[16] ប្រកាសស្តីពីការប្រមូលពន្ធអចលនទ្រព្យ, លេខ៩៩៣សហវ/ប្រក, ១៩ កក្កដា ២០១០។

[17] ប្រកាសស្តីពីតម្លៃគិតពន្ធអចលនទ្រព្យ, លេខ៣៧១សហវ/ប្រក, ០៥ ឧសភា ២០១១។

[18] សេចក្តីប្រកាសព័ត៌មាន, ២៩ ឧសភា ឆ្នាំ២០១៩

### ១.៨.៨.ប្រាក់រំដោះពន្ធលើប្រាក់ចំណូល

**ក.និយមន័យ**

សហគ្រាសដែលជាប់ពន្ធលើប្រាកចំណូលតាមរបបរបបស្វ័យប្រកាស រួមទាំងសហគ្រាសវិនិយោគមានលក្ខណ:សម្បត្តិគ្រប់គ្រាន់ មានកាតព្វកិច្ចបង់ប្រាក់រំដោះប្រចាំខែ សម្រាប់ពន្ធលើប្រាក់ចំណូលតាម អត្រា ១% នៃផលរបរគិតរួមបញ្ចូលទាំងពន្ធអាករទាំងអស់ វៀរលែងតែអាករលើតម្លៃបន្ថែមដែលសម្រេចបានក្នុងខែមុន។ ប្រាក់រំដោះពន្ធលើប្រាក់ចំណូលត្រូវបានយកមកកាត់កងពីពន្ធលើប្រាក់ចំណូលនៅពេលធ្វើការទូទាត់ប្រចាំឆ្នាំ។

**ខ.អត្រាពន្ធ**

ប្រាក់រំដោះពន្ធលើប្រាក់ចំណូលត្រូវគិតតាមអត្រា ១%។

**គ.មូលដ្ឋានគិតពន្ធ**

មូលដ្ឋានគិតពន្ធ = (ផលរបរសម្រេចបានក្នុងខែមុន-អតប)x ១%

**ឃ.ការព្យួរទុកប្រាក់រំដោះពន្ធលើប្រាក់ចំណូល**

សហគ្រាសដាំដុះ ផលិត និងផ្គត់ផ្គង់ក្នុងស្រុក ឬនាំចេញផលិតផលកសិកម្មមួយចំនួន ដូចជា ស្រូវ អង្ករ ពោត សណ្តែក ម្រេច គ្រាប់ស្វាយចន្ទី ដំឡូងមី និងកៅស៊ូ ត្រូវបានអនុគ្រោះព្យួរទុកជាបណ្តោះអាសន្ននូវការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូលប្រចាំខែ រយ:ពេល៥ឆ្នាំ គិតចាប់ពីខែមករា ឆ្នាំ២០១៩ តរៀងទៅ។[19]

### ១.៨.៩.ពន្ធលើប្រាក់បៀវត្ស

**ក.និយមន័យ**

ពន្ធលើប្រាក់បៀវត្ស គឺជាពន្ធប្រាចាំខែកំណត់លើប្រាក់បៀវត្សដែលទទួលបានក្នុងក្របខណ្ឌនៃការបំពេញសកម្មភាពបម្រើការងារ។ ប្រាក់ចំណូលបៀវត្សទាំងអស់រួមមាន បៀវត្ស ប្រាក់បំណាច់ ប្រាក់ម៉ោងបន្ថែម លាភការ បុព្វលាភ ប្រាក់ប៉ះប៉ូវនានា និងអត្ថប្រយោជន៍បន្ថែម ដែលទទួលបានពីសកម្មភាពការងារនានា ត្រូវជាប់ពន្ធលើប្រាក់បៀវត្ស។ ប្រាក់នេះត្រូវប្រមូលតាមរបៀបកាត់ទុកដោយនិយោជកនៅពេលបើកប្រាក់បៀវត្ស។ ត្រូវចាត់ទុកថាជានិយោជិត ហើយជាប់ ពបវ បើសិនជារូបវន្តបុគ្គលណាម្នាក់នោះមានស្ថានភាពបំរើការងារស្របតាមល័ក្ខខ័ណ្ឌចំនួនពីរក្នុងចំនោមល័ក្ខខ័ណ្ឌទាំងឡាយខាងក្រោមនេះ៖

[19] ប្រកាសស្តីពីការព្យួរទុកការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូលរបស់សហគ្រាសប្រកបអាជីវកម្មក្នុងវិស័យកសិកម្ម, លេខ១០០/សហវ/ប្រក, ២៩ មករា ២០១៩

- គ្មានហានិភ័យនៃការមិនបានទទួលប្រាក់ទូទាត់ចំពោះសកម្មភាពបំរើការងាររបស់ខ្លួនឡើយ កាលបើរូបវន្តបុគ្គលនោះបានមកធ្វើការតាមទីកន្លែងដែលបានកំណត់ ហើយបានបំពេញការងារដូចមានចែងក្នុងកិច្ចព្រមព្រៀងបំរើការងារជាទូទៅមួយ ទោះធ្វើដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរក្តី
- រូបវន្តបុគ្គលមិនអាចកំណត់ពេលវាលា និងទីកន្លែងសម្រាប់បំពេញសកម្មភាពបំរើការងារដោយខ្លួនឯងទេ
- រូបវន្តបុគ្គលពុំចាំបាច់ចំណាយដើមទុនច្រើន ដើម្បីទិញឧបករណ៍ដែលត្រូវប្រើប្រាស់សម្រាប់បំពេញសកម្មភាពបំរើការងារ
- រូបវន្តបុគ្គលមិនបំពេញសកម្មភាពបម្រើការងារឲ្យបុគ្គលច្រើននាក់ទេក្នុងពេលតែមួយ។

រូបវន្តបុគ្គលនិវាសនជននៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវជាប់ពន្ធពន្ធលើប្រាក់បៀវត្សចំពោះប្រាក់បៀវត្សប្រភពកម្ពុជា និងប្រាកបៀវត្សប្រភពបរទេស។ រូបវន្តបុគ្គលអនិវាសនជន ត្រូវជាប់ពន្ធលើប្រាក់បៀវត្ស ចំពោះប្រាក់បៀវត្សប្រភពកម្ពុជា។

សម្រាប់គោលដៅនៃបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់បៀវត្ស៖

- **និវាសនជន៖** ត្រូវបានចាត់ទុកថាជានិវាសនជនលុះត្រាតែ និយោជិត អ្នកជាប់ពន្ធ ឬរូបវន្តបុគ្គល ដែលមានល័ក្ខខ័ណ្ឌវិនិច្ឆ័យចាប់ពីមួយឡើងទៅនៅក្នុសចំណោមល័ក្ខខ័ណ្ឌទាំងបីខាងក្រោមនេះ៖
    - មាននិវាសនដ្ឋាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា
    - មានកន្លែងស្នាក់នៅជាគោលដើមនៅក្នុងព្រះរាជាណាចក្រកម្ពុជា
    - មានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាលើសពី ១៨២ថ្ងៃ នៅក្នុងរយៈពេល ១២ ខែណាមួយដែលបានបញ្ចប់ក្នុងឆ្នាំសារពើពន្ធចរន្ត។
- **អនិវាសនជន៖** មានន័យថា បុគ្គលណាមួយដែលមិនមែនជានិវាសនជន និងទទួលប្រាក់បៀវត្សប្រភពកម្ពុជា។

**ខ.ប្រាក់បៀវត្សលើកលែងពន្ធ**

ត្រូវបានលើកលែងពន្ធលើប្រាក់បៀវត្សចំពោះ៖

- ការលើកលែងពន្ធលើប្រាក់បៀវត្សរបស់មន្ត្រីការទូត និងមន្ត្រីបរទេសដទៃទៀត ៖
    - ប្រាក់បៀវត្ស ដែលមន្ត្រីនិងនិយោជិតបរទេស ឬកុងសុលរបស់រដ្ឋាភិបាលបរទេសណាមួយដែលកាន់លិខិតឆ្លងដែនការទូត ឬផ្លូវការរបស់ប្រទេសនោះ

បេសកកម្មទូត បានទទួលក្នុងក្របខ័ណ្ឌនៃការបំពេញមុខងារជាផ្លូវការនៅក្នុងព្រះរាជាណាចក្រកម្ពុជ

- ប្រាក់បៀវត្ស ដែលតំណាងមន្ត្រី និងនិយោជិតបរទេសរបស់អង្គការអន្តរជាតិ និងរបស់ទីភ្នាក់ងារខាងសហប្រតិបត្តិការបច្ចេកទេស នៃរដ្ឋាភិបាលដទៃទៀត បានទទួលក្នុងក្របខ័ណ្ឌនៃការបំពេញមុខងារជាផ្លូវការនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ការលើកលែងពន្ធនៅក្នុងចំនុចនេះ ត្រូវឈរលើគោលការណ៍បដិការរវាងរដ្ឋាភិបាលដែលពាក់ពន្ធ។

- ប្រាក់សំណង់ដោយពិតប្រាកដនូវចំណាយខាងវិជ្ជាជីវៈ ដែលបានចាយដោយនិយោជិតតាមសេចក្តីបង្គាប់ និងសម្រាប់ជាប្រយោជន៍នៃនិយោជក ហើយដែលបានបំពេញល័ក្ខខណ្ឌបីដូចតទៅៈ
  - បានចាយក្នុងផលប្រយោជន៍ផ្ទាល់ និងដាច់ខាតរបស់សហគ្រាស
  - មិនបង្ហាញលក្ខណៈហួសប្រមាណ ឬស្តុកស្តម្ភហួសហេតុ
  - បានបង្ហាញជាភស្តុតាង ដោយវិក័យបត្ររាយលម្អិត និងបានទូទាត់ស្រេចបាច់ ហើយដែលបានធ្វើក្នុងនាមអ្នកទទួលបានប្រាក់សំណាង នូវចំណាយពិតប្រាកដ
- ប្រាក់បំណាច់នៃការបឈ្សប់លែងឲ្យធ្វើការ ក្នុងកម្រិតដែលមានចែងក្នុងបទប្បញ្ញត្តិក្នុងច្បាប់ការងារ
- លាភការបន្ថែមមានលក្ខណៈខាងសង្គមកិច្ច ក្នុងករណីដែលមានចែងក្នុងបទប្បញ្ញត្តិក្នុងច្បាប់ការងារ
- ការផ្គត់ផ្គង់ឲ្យដោយឥតយកថ្លៃ ឬយកថ្លៃទាបជាងថ្លៃដើមនូវឯកសណ្ឋាន ឬបរិក្ខារសម្រាប់វិជ្ជាជីវៈពិសេស
- ប្រាក់បំណាច់មៅការសម្រាប់ចំណាយបេសកកម្ម និងការធ្វើដំណើរ។ ប្រាក់បំណាច់នេះមិនត្រូវគ្រួតគ្នាជាមួយប្រាក់សំណង់ពិតប្រាក់កដនូវចំណាយដូចមានចែងខាងលើឡើយ។

**គ.ការគណនាប្រាក់ពន្ធ និងអត្រាពន្ធ**

➢ សម្រាប់និវាសនជន

សម្រាប់និយោជិតនិវាសនជន ប្រាក់ពន្ធត្រូវបង់ ត្រូវកំណត់លើប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ

និងត្រូវកាត់ទុកដោយនិយោជក តាមអត្រាកំណើនតាមថ្នាក់ដូចខាងក្រោម៖

| **ភាគបៀវត្សប្រចាំខែត្រូវជាប់ពន្ធ** | | | | **អត្រាពន្ធ** | **លម្អៀងលើសប្រាក់ពន្ធតាមថ្នាក់** |
|---|---|---|---|---|---|
| ពី | ០ រៀល | ដល់ | ១ ២០០ ០០០ រៀល | ០% | ០ រៀល |
| ពី | ១ ២០០ ០០១ រៀល | ដល់ | ២ ០០០ ០០០ រៀល | ៥% | ៦០ ០០០ រៀល |
| ពី | ២ ០០០ ០០១ រៀល | ដល់ | ៨ ០០០ ០០០ រៀល | ១០% | ១៦០ ០០០ រៀល |
| ពី | ៨ ៥០០ ០០១ រៀល | ដល់ | ១២ ៥០០ ០០០ រៀល | ១៥% | ៥៨៥ ០០០ រៀល |
| លើសពី ១២ ៥០០ ០០១ រៀល | | | | ២០% | ១ ២១០ ០០០ រៀល |

មូលដ្ឋានគិតពន្ធ = (ប្រាក់បៀវត្សត្រូវបើក-ទាយជ្ជទាន)

ប្រាក់ពន្ធត្រូវបង់ = (មូលដ្ឋានគិតពន្ធ x អត្រាពន្ធ) - លម្អៀងលើសប្រាក់ពន្ធតាមថ្នាក់

➢ អត្ថប្រយោជន៍បន្ថែម

ចំពោះអ្នកជាប់ពន្ធនិវាសនជន ជារៀងរាល់ខែនិយោជកត្រូវកាត់ទុក និងបង់ប្រាក់ពន្ធតាមកាលកំណត់តាមអត្រា ២០ភាគរយ នៃតម្លៃសរុបរបស់អត្ថប្រយោជន៍បន្ថែមដែលបានផ្តល់ឲ្យនិយោជិតទាំងអស់។តម្លៃនៃអត្ថប្រយោជន៍បន្ថែមគឺជាតម្លៃទីផ្សារួមទាំងពន្ធអាករទាំងអស់។

➢ សម្រាប់អនិវាសនជន

សម្រាប់អ្នកជាប់ពន្ធអនិវាសនជន ប្រាក់ពន្ធត្រូវកាត់ទុកដោយអ្នកបើកប្រាក់ឲ្យតាមអត្រា ២០ភាគរយ លើរាល់ការទូទាត់ប្រាក់បៀវត្សជាប់ពន្ធ។ ពន្ធកាត់ទុកនេះគឺជាពន្ធចុងក្រោយនៃពន្ធលើប្រាក់បៀវត្ស។

**ឃ.អត្ថប្រយោជន៍បន្ថែមត្រូវជាប់ពន្ធ**

អត្ថប្រយោជន៍ដែលនិយោជកផ្តល់ឲ្យដោយផ្ទាល់ ឬតាមរយៈតតិយជនដល់រូបវន្តបុគ្គលត្រូវជាប់ពន្ធលើអត្ថប្រយោជន៍បន្ថែម។ អត្ថប្រយោជន៍បន្ថែមទាំងនោះមានជាអាទិ៍៖

ក. យានជំនិះគ្រប់ប្រភេទ

ខ. ម្ហូបអាហារ

គ. លំនៅដ្ឋាន ការស្នាក់នៅ

ឃ. ទឹក ភ្លើង ទូរស័ព្ទ

ង. អ្នកបំរើការងារក្នុងលំនៅដ្ឋាន

ច. ប្រាក់ឲ្យខ្ចីដោយគិតការប្រាក់ទាបជាងការប្រាក់ទីផ្សារ។ អត្រាការប្រាក់ទីផ្សារដែល

ត្រូវយកមកអនុវត្តត្រូវកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ឆ. ការលក់ទំនិញចុះថ្លៃ

ជ. ជំនួយផ្នែកអប់រំសម្រាប់និយោជិតដែលមិនមែនជាចំណែកណាមួយនៃកម្មវិធីបណ្តុះបណ្តាលទាក់ទិនផ្ទាល់ទៅនឹងការបំពេញការងាររបស់និយោជិត

ឈ. ជំនួយផ្នែកអប់រំសម្រាប់កូនរបស់និយោជិត

ញ.បុព្វលាភធានារ៉ាប់រងអាយុជីវិត ឬសុខភាព លើកលែងតែមានផ្តល់អត្ថប្រយោជន៍បន្ថែមដូចគ្នាឲ្យដល់និយោជិតគ្រប់គ្នាដោយគ្មានការបែងចែកតាមតួនាទិ ឬមុខងារ

ដ. ចំណែកនៃការឧបត្ថមលើចំណាយដែលមិនសមហេតុផល មិងមិនចាំបាច់សម្រាប់អាជីវកម្មរបស់និយោជក

ឋ. ចំនួនប្រាក់បង់ចូលមូលនិធិសុខមាលភាពសង្គមដែលលើសពីកំរិតដែលច្បាប់បានអនុញ្ញាត

ឌ. ចំនួនប្រាក់បង់ចូលបេឡាសោធនដែលលើសពី ១០ភាគរយ នៃប្រាក់បៀវត្សប្រចាំខែគ្មានបូកអត្ថប្រយោជន៍បន្ថែមរបស់និយោជិត

ឍ. ចំណាយសម្រាប់ការទទួលភ្ញៀវ ការកំសាន្ត ការសំរាកលំហែ ឬការប្រើប្រាស់មធ្យោបាយណាមួយដែលទាក់ទិននិងសកម្មភាពទាំងនេះ ដែលមិនមែនជាចំនែកណាមួយនៃទំនាក់ទំនងបំរើការងារ។[20]

**ខ.ប្រាក់ឧបត្ថម្ភដែលមិនជាប់ពន្ធបៀវត្ស និងអត្ថប្រយោជន៍បន្ថែម**

ប្រាក់ឧបត្ថម្ភដែលនិយោជិត កម្មករ កម្មការនី ទាំងអស់ នៃរោងចក្រនានាទទួលបានពីការបំពេញការងារ មិនត្រូវបានគិតបញ្ចូលក្នុងមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស និងមិនមែនជាកម្មវត្ថុនៃពន្ធលើអត្ថប្រយោជន៍បន្ថែមទេ។ ប្រាក់ឧបត្ថម្ភទាំងនេះរួមមាន៖

- សោហ៊ុយធ្វើដំណើរពីទីកន្លែងស្នាក់នៅទៅទីកន្លែងធ្វើការ និងពីទីកន្លែងធ្វើការទៅកន្លែងស្នាក់នៅ ព្រមទាំងការឧបត្ថម្ភថ្លៃស្នាក់នៅឬការផ្តល់កន្លែងស្នាក់នៅក្នុងបរិវេណទីកន្លែងធ្វើការ ស្របតាមបទប្បញ្ញត្តិនៃច្បាប់ការងារ។
- ប្រាក់ថ្លៃបាយដែលផ្តល់ឲ្យកម្មករនិយោជិតទាំងអស់ដោយគ្មានបែងចែកតួនាទី ឬមុខងារ។
- មូលនិធិបេឡាសន្តិសុខសង្គមឬមូលនិធិសុខមាលភាពសង្គមក្នុងកម្រិតដែលបានប្បញ្ញត្តិ

[20] ប្រកាសស្តីពីពន្ធលើប្រាក់បៀវត្ស, លេខ១១៧៣សហវ/ពដ/ប្រក, ៣១ ធ្នូ ២០០៣។

ក្នុងច្បាប់។

- ប្រាក់ធានារ៉ាប់រងសុខភាពឬបុព្វលាភធានារ៉ាប់រងអាយុជីវិតសុខភាពដែលផ្តល់ឲ្យកម្មករនិយោជិតគ្រប់គ្នាដោយគ្មានការបែងចែកតួនាទី ឬមុខងារ។
- ប្រាក់ឧបត្ថម្ភទារក ឬចំណាយទារកដ្ឋាន ដែលមានចែងក្នុងបទប្បញ្ញត្តិនៃច្បាប់ការងារ។
- ប្រាក់បំណាចបញ្ចប់កិច្ចសន្យា ឬប្រាក់បំណាច់នៃការបញ្ឈប់លែងឲ្យធ្វើការ ក្នុងកម្រិតដែលបានបញ្ញត្តិក្នុងច្បាប់ការងារ។[21]

### ១.៨.១០.ពន្ធកាត់ទុក

#### ក.និយមន័យ

អ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្ម ដែលបានធ្វើការទូទាត់ជាសាច់ប្រាក់ ឬជាវត្ថុអោយដល់អ្នកជាប់ពន្ធនិវាសនជន និងអនិវាសជន ត្រូវកាត់ទុកនិងបង់ប្រាក់ពន្ធទៅតាមអត្រាកំណត់។ ចំណាយណាមួយដែលជាកម្មវត្ថុនៃពន្ធកាត់ទុកដែលបានកត់ត្រាជាចំណាយក្នុងបញ្ជីគណនេយ្យ ត្រូវចាត់ទុកថាបានទូទាត់។

#### ខ.ពន្ធកាត់ទុកទៅលើការទូទាត់ទៅអោយនិវាសនជន

អ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្ម ដែលបើក ឬទូទាត់ជាសាច់ប្រាក់ ឬជាវត្ថុ អោយដល់បុគ្គលនិវាសនជនត្រូវកាត់ទុក និង បង់ប្រាក់ពន្ធទៅតាមអត្រាកំណត់ដូចខាងក្រោម៖

- ❖ អត្រា ១៥% ៖
  - ចំពោះប្រាក់ចំណូលដែលរូបវន្តបុគ្គលបានទទួលពីការបំពេញសេវានានា រួមទាំងការគ្រប់គ្រង ឬពិគ្រោះយោបល់ ឬសេវាប្រហាក់ប្រហែល។
  - ចំពោះសួយសារពីទ្រព្យសកម្មអរូបី និងសួយសារពីភាគកម្ម ក្នុងធនធានរ៉ែ។
  - ចំពោះការប្រាក់ដែលអ្នកជាប់ពន្ធនិវាសនជនប្រកបអាជីវកម្មដែលមិនមែនជាធនាគារ ឬស្ថាប័នសញ្ជ័យធនក្នុងស្រុក បង់ទៅអោយអ្នកជាប់ពន្ធនិវាសនជន។
- ❖ អត្រា ១០% ៖ ចំពោះចំណូលពីការជួលចលនទ្រព្យ ឬអចលនទ្រព្យ
- ❖ អត្រា ៦% ៖ ចំពោះការប្រាក់ដែលធនាគារ ឬស្ថាប័នសញ្ជ័យធនក្នុងស្រុកបង់ឲ្យទៅអ្នកជាប់ពន្ធនិវាសនជន ដែលមានគណនីសន្សំមានកាលកំណត់។

[21]សារាចរស្តីពីការអនុវត្តកាតព្វកិច្ចកាត់ទុកពន្ធលើអត្ថប្រយោជន៍បន្ថែម, លេខ០១១សហវ, ០៦ តុលា ២០១៦។

❖ អត្រា ៥% ៖ ចំពោះការប្រាក់ដែលធនាគារ ឬស្ថាប័នសញ្ជ័យធនក្នុងស្រុកបង់ឲ្យទៅអ្នកជាប់ពន្ធនិវាសនជន ដែលមាន គណនីសន្សំគ្មានកាលកំណត់។

**គ.ពន្ធកាត់ទុកចំពោះអនិវាសនជន**

អ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្ម ដែលបានទូទាត់ប្រាក់ចំណូលទៅឲ្យអ្នកជាប់ពន្ធអនិវាសជន ត្រូវកាត់ទុកនិងបង់ប្រាក់ពន្ធចំនួន ១៤% នៃទឹកប្រាក់ត្រូវបើក។[22]

**ឃ.ការលើកលែងពន្ធកាត់ទុក**

ពន្ធកាត់ទុកត្រូវបានលើកលែងចំពោះ៖

- ការប្រាក់ដែលបានបង់ឲ្យធនាគារ ឬស្ថាប័នសញ្ជ័យធនក្នុងស្រុក
- ការបើក ឬទូទាត់ទៅឲ្យរាជរដ្ឋាភិបាល ឬស្ថាប័ននរដ្ឋាភិបាលនូវ សួយសារ ឬប្រាក់ឈ្នួលលើចលនទ្រព្យ ដែលបំពេញបានលក្ខខណ្ឌទាំងពីរដូចតទៅ ៖
  ១. ការបើកឬទូទាត់ប្រាក់នេះ ត្រូវទាក់ទិននឹងចលនទ្រព្យ ឬអចលនទ្រព្យបានកត់ត្រាជាទ្រព្យសម្បត្តិរដ្ឋ
  ២. ប្រាក់បើក ឬទូទាត់ត្រូវបានបញ្ជាក់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ការបើក ឬទូទាត់ប្រាក់ចំណូលដែលជាប់ពន្ធបៀវត្ស ឬអត្ថប្រយោជន៍បន្ថែម
- ការបើក ឬទូទាត់ប្រាក់ដោយរាជរដ្ឋាភិបាល ឬស្ថាប័នរាជរដ្ឋាភិបាល ឲ្យបុគ្គលអនិវាសនជន
- ប្រាក់ចំណូលរបស់អង្គការណាមួយដែល
  ១. ត្រូវបានរៀបចំឡើង និងដំណើរការសម្រាប់គោលដៅសុទ្ធសាធខាងសាសនា សប្បុរសធម៌ វិទ្យាសាស្ត្រ អក្សរសាស្ត្រ ឬអប់រំ
  ២. គ្មានចំណែកណាមួយនៃទ្រព្យ ឬប្រាក់ចំណូល ត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ឯកជន
- ប្រាក់ចំណូលរបស់អង្គការពលករ ឬសភាពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម ក្នុងករណីដែលប្រាក់ចំណូលរបស់អង្គការទាំងនេះ មិនត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ឯកជនរបស់អ្នកចូលហ៊ុន ឬបវន្តបុគ្គល

[22] ប្រកាសស្តីពីការកែសម្រួលការណែនាំអនុវត្តពន្ធកាត់ទុកលើការបែងចែកភាគលាភ, លេខ៣៧២សហវ/ប្រក, ០៥ មេសា ២០១៩។

- ភាគលាភដែលបានទទួលមកពីសហគ្រាសនិវាសនជន ក្នុងករណីដែលប្រាក់ពន្ធ ត្រូវបង់តាមមាត្រា ២០ ថ្មី ២៣ ថ្មី និងមាត្រា ២៦ ថ្មី នៃច្បាប់នេះត្រូវបានបង់រួចរាល់
- ការលើកលែងពន្ធកាត់ទុកចំពោះប្រាក់ចំណូលរបស់សហគ្រាស នីតិបុគ្គលជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវបំពេញបាននូវលក្ខខណ្ឌទាំងពីរដូចតទៅៈ
  ១. ចំពោះប្រាក់ចំណូលបានពីការបំពេញសេវានានា រួមទាំងការគ្រប់គ្រង ឬការពិគ្រោះយោបល់ ឬសេវាប្រហាក់ប្រហែល របស់សហគ្រាសនីតិបុគ្គលជាប់ពន្ធតាមរបបស្វ័យប្រកាស
  ២. លុះត្រាតែទឹកប្រាក់នោះត្រូវបានកត់ត្រាក្នុងវិក័យបត្រ ដែលចេញដោយអ្នកទទួលប្រាក់ និងបានសរសេរបំពេញគ្រប់និទ្ទេសបានត្រឹមត្រូវ និងច្បាស់លាស់។

**ខ.ការគណនាប្រាក់ពន្ធ**

ចំនួនប្រាក់ពន្ធកាត់ទុក គឺត្រូវគណនាលើចំនួនទឹកប្រាក់ដែលត្រូវទូទាត់អោយបុគ្គលណាមួយមិនទាន់កាត់ទុកប្រាក់ពន្ធ។

**១.៨.១១.អាករលើការស្នាក់នៅ**

ដែនអនុវត្តន៍ ចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ ២០០៧ ត្រូវបានអនុវត្តលើការស្នាក់នៅរបស់ភ្ញៀវនៅក្នុងសណ្ឋាគារ

**ក.និយមន័យ**

សណ្ឋាគារ សំដៅដល់ មូលដ្ឋានផ្គត់ផ្គង់សេវាស្នាក់នៅមានលក្ខណៈជាបន្ទប់ គ្រែ និងមានផ្តល់នូវសម្បទា និងសេវាផ្សេងៗទៀតទៅតាមប្រភេទនៃមូលដ្ឋានសេវាស្នាក់នៅនីមួយៗដូចជា ៖ សណ្ឋាគារ សណ្ឋាគារអាផាតម៉ិន សណ្ឋាគារស្វីត សណ្ឋាគាររីសត ម៉ូតែល ឡូត បឹងកាឡូ ផ្ទះសំណាក់ឬផ្ទះភ្ញៀវ កន្លែងបោះជំរុំទេសចរណ៍ និងទីកន្លែងផ្តល់សេវាស្នាក់នៅផ្សេងទៀតដែលមានលក្ខណៈប្រហាក់ប្រហែល ទោះជាឲ្យ ឬដាក់ឈ្មោះថាជាអ្វីក៏ដោយ។

ពាក្យ "សណ្ឋាគារ" នេះមិនរួមបញ្ចូលផ្ទះជួល ឬផ្ទះល្វែងជួលរយៈពេលខ្លី និងរយៈពេលវែង។

**ខ.អត្រាអាករ**

អាករលើការស្នាក់នៅ ត្រូវកំណត់តាមអត្រា ២ភាគរយ លើបន្ទប់ស្នាក់នៅក្នុងសណ្ឋាគារ ដោយរួមបញ្ចូលទាំងពន្ធ-អាករ និងបន្ទុកសេវាផ្សេងៗលើកលែងតែអាករលើការស្នាក់នៅខ្លួនឯង និងអាករលើតម្លៃបន្ថែម។[23]

[23] ប្រកាសស្តីពីការអនុវត្តអាករលើការស្នាក់នៅ, លេខ៣៨០សហវ/ពដ, ១៤ កក្កដា ២០០៥។

**គ.មូលដ្ឋានគិតអាករ**

មូលដ្ឋានគិតអាករ = ថ្លៃបន្ទប់ + ពន្ធអាករ + បន្ទុកផ្សេងៗ (service charge)

អាករស្នាក់នៅ = មូលដ្ឋានអាករ x ២%

**១.៨.១២.អាករបំភ្លឺសាធារណៈ**

ប្រាក់ចំណូលបានមកពីការប្រមូលអាករនេះ ត្រូវបានជាប្រយោជន៍ថវិការខេត្តក្រុង ទុកសម្រាប់ជាចំណាយឲ្យការបំភ្លឺសាធារណៈ។

**ក.មុខសញ្ញាជាប់អាករ**

អាករបំភ្លឺសាធារណៈត្រូវបានអនុវត្តទៅលើ ការដកយកមកប្រើប្រាស់ផ្ទាល់ខ្លួនរបស់បុគ្គលជាប់អាករ របស់បុគ្គលិក ឬសម្រាប់តតិយជន ឬការផ្គត់ផ្គង់ទៅលើ ស្រាបៀរ ស្រា(ស្រា ស្រាទំពាំងបាយជូរស្រស់ ស្រាវ៉ែនុត ភេសជ្ជៈមេរ័យ អាល់កុលអេទីលិកសុទ្ធ) និង បារី។

**ខ.ការលើកលែងមុខសញ្ញាជាប់ពន្ធ**

មុខសញ្ញាលើកលែងអាករបំភ្លឺសាធារណៈមានដូចជា ស្រាស ទឹកត្នោតជូរ ថ្នាំជក់ (ជាវត្ថុធាតុដើម)។[24]

**គ.អត្រាអាករ**

អត្រាអាករបំភ្លឺសាធារណៈគឺ ៣%។

**ឃ.មូលដ្ឋានគិតអាករ**

មូលដ្ឋានអាករបំភ្លឺសាធារណៈត្រូវបានកំណត់ដូចខាងក្រោម៖

- ចំពោះអ្នកផលិត និង អ្នកនាំចូល មូលដ្ឋានគិតអាករគឺជាថ្លៃផ្គត់ផ្គង់ដែលត្រូវបានកត់ត្រាលើវិក័យបត្ររួមបញ្ចូលទាំងពន្ធអាករនានា វៀរលែងតែអាករលើតម្លៃបន្ថែម និងអាករសម្រាប់បំភ្លឺសាធារណៈខ្លួនឯង។
    - មូលដ្ឋានគិតអាករ = ថ្លៃផ្គត់ផ្គង់ជាប់អាករ + អាករផ្សេងៗ
    - អាករបំភ្លឺសាធារណៈ = មូលដ្ឋានគិតអាករ x ៣%
- ចំពោះអ្នកផ្គត់ផ្គង់បន្ត មូលដ្ឋានគិតអាករស្មើនឹង ២០ ភាគរយ នៃថ្លៃផ្គត់ផ្គង់ដែលត្រូវបានកត់ត្រាលើវិក័យបត្រ រួមបញ្ចូលទាំងពន្ធអាករនានា វៀរលែងតែអាករលើតម្លៃបន្ថែម និងអាករសម្រាប់បំភ្លឺសាធារណៈខ្លួនឯង។[25]

[24] ប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងនិងប្រមូលអាករសម្រាប់បំភ្លឺសាធារណៈ, លេខ១៧៥សហវ/ពដ/ប្រក, ២២ មករា ២០០២។

- មូលដ្ឋានគិតអាករ = (ថ្លៃផ្គត់ផ្គង់ជាប់អាករ + អាករផ្សេងៗ) x ២០%
- អាករបំភ្លឺសាធារណៈ = មូលដ្ឋានគិតអាករ x ៣%

### ១.៨.១៣.អាករពិសេសលើទំនេញ និងសេវា

អាករពិសេសទៅលើទំនិញ និង សេវា ត្រូវបានប្រមូលទៅលើ៖

- ទំនិញដែលធ្វើឲ្យប៉ះពាល់ទៅលើសុខភាព ដែលរដ្ឋាភិបាលមិនលើកទឹកចិត្តក្នុងការប្រើប្រាស់
- ទំនិញ ឬសេវា ដែលមិនចាំបាច់ក្នុងជីវភាពរស់នៅរបស់ប្រជាជនសាមញ្ញ
- ជាប្រភេទទំនិញ ឬសេវាមានលក្ខណៈប្រណិត

**ក.មុខសញ្ញាជាប់អាករ**

១. អាករពិសេសលើទំនិញផលិតក្នុងស្រុក

- ស្រា និង ភេសជ្ជៈគ្រប់ប្រភេទ
- ស្រាបៀរគ្រប់ប្រភេទ
- បារី បារីស៊ីហ្គាគ្រប់ប្រភេទ

២. អាករពិសេសលើសេវា

- សេវាដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាសក្នុង និងក្រៅស្រុក
- សេវាទូរគមនាគមន៍ក្នុង និង ក្រៅប្រទេស
- សេវាលំហែកំសាន្ត

**ខ.អត្រាពន្ធ**

១. អាករពិសេសលើទំនិញផលិតក្នុងស្រុក

- ៣៥% លើស្រា
- ៣០% លើស្រាបៀរគ្រប់ប្រភេទ
- ២០% លើបារី បារីស៊ីហ្គាគ្រប់ប្រភេទ
- ១០% លើភេសជ្ជៈគ្រប់ប្រភេទ[26]

២. អាករពិសេសលើសេវា

[25] ប្រកាសស្តីពីការកំណត់មូលដ្ឋានគិតអាករសម្រាប់បំភ្លឺសាធារណៈ, លេខ៩៧៦សហវ/ប្រក, ០៩ តុលា ២០១៧។

[26] សេចក្តីជូនដំណឹងស្តីពីការអនុវត្តការកែសម្រួលអត្រាអាករពិសេសលើមុចទំនិញមួយចំនួនដែលផលិតក្នុងស្រុក, លេខ២២២៧អពដ, ២២ មីនា ២០១៦។

- ១០% សម្រាប់ថ្លៃលក់សំបុត្រលើសេវាដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាសក្នុង និង ក្រៅស្រុក
- ១០% សម្រាប់សេវាលំហែកំសាន្ត
- ៣% សម្រាប់សេវាទូរគមនាគមន៍ក្នុង និង ក្រៅប្រទេស

**គ.មូលដ្ឋានគិតអាករ**

១. អាករពិសេសលើទំនិញផលិតក្នុងស្រុក[27]

- មូលដ្ឋានសម្រាប់គិតអាករពិសេសលើទំនិញផលិតក្នុងស្រុក =(ថ្លៃកត់ត្រាក្នុងវិក័យបត្រឲ្យទៅអតិថិជន - អាករលើតម្លៃបន្ថែម - អាករពិសេសខ្លួនឯង) x ៩០%
- អាករពិសេសលើទំនេញ= មូលដ្ឋានគិតអាករពិសេសលើទំនិញ x អត្រាអាករ

២. អាករពិសេសលើសេវា

- មូលដ្ឋានគិតអាករពិសេសលើសេវា = ថ្លៃផ្គត់ផ្គង់របស់អ្នកជាប់ពន្ធកត់ត្រាក្នុងវិក្កយបត្រឲ្យទៅអតិថិជន - អាករលើតម្លៃបន្ថែម- អាករបំភ្លឺសាធារណៈ - អាករពិសេសខ្លួនឯង
- អាករពិសេសលើសេវា= មូលដ្ឋានគិតអាករពិសេសលើសេវា x អត្រាអាករ

**ឃ.ការលើកលែងអាករ**

អាករពិសេសលើទំនិញត្រូវបានលើកលែងទៅលើ ស្រាស ទឹកត្នោតជូរ ទឹក ទឹកមីណេរ៉ាល ទឹកដមផ្លែឈើ ទឹកដមបន្លែ។

**១.៨.១៤.អាករលើតម្លៃបន្ថែម**

**ក.និយមន័យ**

អាករលើតម្លៃបន្ថែម ឬ អតប ជាប្រភេទពន្ធលើការប្រើប្រាស់ ដែលយកលើទំនិញ និងសេវាគ្រប់ដំណាក់ការនៃការផ្គត់ផ្គង់ទំនិញ និងសេវាដែលជាបន្ទុករបស់អ្នកប្រើប្រាស់ចុងក្រោយ។

**ខ.ការផ្គត់ផ្គង់ជាប់អាករ**

ការផ្គត់ផ្គង់ជាប់អតបគឺជា៖

- ការផ្គត់ផ្គង់ទំនិញ ឬសេវា ដោយបុគ្គលជាប់អតប នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ការដកទំនិញមកប្រើប្រាស់ផ្ទាល់ខ្លួនដោយបុគ្គលជាប់អតប
- ការផ្តល់ជាអំណោយ ឬផ្គត់ផ្គង់ក្រោមតម្លៃពិតនូវទំនិញ និងសេវាដោយបុគ្គលជាប់អតប

[27] សេចក្តីជូនដំណឹងស្តីពីការកែសម្រួលមូលដ្ឋានគិតអាករពិសេសលើមុខទំនិញមួយចំនួនដែលផលិតក្នុងស្រុកក្រៅពីបារីនិងស្រា, លេខ០០៥សហវ, ១៩ មករា ២០១៥។

- ការនាំចូលទំនិញចូលមកក្នុងតំបន់ត្រួតពិនិត្យគយនៃព្រះរាជាណាចក្រកម្ពុជា

**គ. ការផ្គត់ផ្គង់មិនជាប់អាករ**

- សេវាប្រៃសនីយ៍សាធារណៈ
- សេវាមន្ទីរពេទ្យ និងគ្លីនិក សេវាខាងវេជ្ជសាស្ត្រ និងទន្តសាស្ត្រ និងការលក់ទំនិញបន្ទាប់បន្សំខាងវេជ្ជសាស្ត្រ និងទន្តសាស្ត្រ ដែលទាក់ទិននិងការបំពេញសេវាកម្មទាំងនេះ។
- សេវាដឹកជញ្ជូនអ្នកដំណើរដោយប្រព័ន្ធដឹកជញ្ជូនសាធារណៈដែលជាកម្មសិទ្ធទាំងស្រុងរបស់រដ្ឋ។
- សេវាធានារ៉ាប់រង
- សេវាជាមូលដ្ឋានខាងហិរញ្ញវត្ថុ
- សេវាសិក្សាអប់រំ
- ថាមពលអគ្គិសនី
- ទឹកស្អាត
- ផលិតផលកសិកម្មមិនទាន់កែច្នៃ(ជាបន្ទុករបស់រដ្ឋ)
- សេវាប្រមូល ឬសម្អាតកាកសំណល់រឹង-រាវ[28]
- ការនាំចូលសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនដែលរួចពន្ធគយស្របតាមបទប្បញ្ញត្តិស្តីពីគយ
- សកម្មភាពមិនស្វែងរកប្រាក់ចំណេញដើម្បីបំរើផលប្រយោជន៍សាធារណៈ
- ការនាំចូល ឬទិញទំនិញសម្រាប់ យកមកបំពេញមុខងារជាផ្លូវការរបស់បេសកកម្មការទូត និងកុងស៊ុលបរទេស អង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា
- ការផ្គត់ផ្គង់ដីកសិកម្ម ពូជដំណាំ បសុឧសថ ចំណីសត្វ ពូជសត្វ គ្រឿងយន្ត និងឧបករណ៍កសិកម្ម (ជាបន្ទុករបស់រដ្ឋ)។[29]

**ឃ.ពេលផ្គត់ផ្គង់**

- ពេលផ្គត់ផ្គង់ទំនិញ ឬសេវាត្រូវបានកំណត់ដូចខាងក្រោមៈ

[28] ប្រកាសស្តីពីការណែនាំអនុវត្តអាករលើតម្លៃបន្ថែមចំពោះការផ្គត់ផ្គង់មិនជាប់អាករ, លេខ៥៥៩ សហវ/ប្រក, ២៥ ឧសភា ២០១៧

[29] មាត្រា៥៣ នៃអនុក្រឹត្យស្តីពីអាករលើតម្លៃបន្ថែម,លេខ១១៤ អនក្រ/បក, ២៤ ធ្នូ ១៩៩៩

- ពេលផ្គត់ផ្គង់ទំនិញ ឬសេវាគឺជាពេលដែលអ្នកផ្គត់ផ្គង់ត្រូវចេញវិក័យបត្រ ឬជាពេលដែលអ្នកផ្គត់ផ្គង់បានចេញវិក័យបត្រ ប្រសិនបើវិក័យបត្រនោះ ត្រូវបានចេញមុនពេលដែលអ្នកផ្គត់ផ្គង់ត្រូវចេញវិក័យបត្រ។ អ្នកផ្គត់ផ្គង់ត្រូវចេញវិក័យបត្រអតបយ៉ាងយឺតបំផុត ៧ថ្ងៃក្រោយការបញ្ជូនទំនិញឬសេវា ឬក្រោយការទូទាត់ ក្នុងករណីដែលការទូទាត់ត្រូវបានធ្វើឡើងមុនការបញ្ជូនទំនិញ ឬសេវា។
- ក្នុងករណីដែលទំនិញត្រូវបានយកទៅប្រើប្រាស់ផ្ទាល់ខ្លួន ពេលផ្គត់ផ្គង់គឺជាពេលដែលទំនិញនោះត្រូវបានយកទៅប្រើប្រាស់ដំបូង។
- ក្នុងករណីទំនិញ ឬសេវាត្រូវបានផ្គត់ផ្គង់ក្នុងលក្ខណៈជាអំណោយ ពេលផ្គត់ផ្គង់គឺជាពេលដែលទំនិញត្រូវបានប្រគល់ឲ្យ ទោះមានលក្ខណៈជាការផ្ទេរសិទ្ធិចាត់ចែងក្តី ឬពេលដែលសេវាផ្គត់ផ្គង់ឲ្យត្រូវបានបំពេញរួចរាល់

- ពេលផ្គត់ផ្គង់ទំនិញក្រោមកិច្ចសន្យាជួលដោយមានល័ក្ខខណ្ឌទិញផ្តាច់ ឬភតិសន្យាហិរញ្ញវត្ថុ គឺជាពេលដែលទំនិញត្រូវបានប្រគល់ឲ្យ ទោះមានលក្ខណៈជាការផ្ទេរសិទ្ធិប្រើប្រាស់ ឬសិទ្ធិចាត់ចែងក្តី។
- ក្នុងករណីដែល៖
    - ទំនិញត្រូវបានផ្គត់ផ្គង់ក្រោមកិច្ចសន្យាជួល ឬ
    - ទំនិញឬសេវាត្រូវបានផ្គត់ផ្គង់ក្រោមកិច្ចសន្យាឬច្បាប់ដែលចែងអំពីការទូទាត់ច្រើនលើក ឬ
    - សេវាត្រូវបានផ្គត់ផ្គង់ជាប់បន្ត
    - ទំនិញឬសេវានោះ ត្រូវចាត់ទុកថាបានផ្គត់ផ្គង់រួចរាល់ចំពោះចំណែកដែលបានផ្គត់ផ្គង់រួចរាល់ក្នុងរយៈពេលនៃកិច្ចសន្យាឬរយៈពេលដែលច្បាប់បានកំណត់ ហើយពេលផ្គត់ផ្គង់នៃចំណែកដែលបានផ្គត់ផ្គង់រួចរាល់នីមួយៗ គឺជាកាលបរិច្ឆេទមុនគេក្នុងចំណោមកាលបរិច្ឆេទដែលការទូទាត់ត្រូវដល់កំណត់ និងកាលបរិច្ឆេទដែលបានទទួលការទូទាត់។
- ចំពោះការនាំចូលទំនិញ ពេលផ្គត់ផ្គង់គឺជាពេលដែលអ្នកនាំចូលដាក់លិខិតប្រកាសជូនអាជ្ញាធរគយ និងរដ្ឋាករ ទៅតាមគោលការណ៍ជាធរមាន ហើយពន្ធគយនិងអាករនានាត្រូវបង់។

**ខ.អត្រាពន្ធ និងមូលដ្ឋានគណនាប្រាក់ពន្ធ**

- អត្រាពន្ធ៖
  - ១០% សម្រាប់ទំនិញនាំចូលនិងការផ្គត់ផ្គង់ក្នុងស្រុក
  - 0% សម្រាប់ការនាំចេញ
- មូលដ្ឋានគណនាពន្ធ ឬតម្លៃជាប់ពន្ធ៖
  - ទំនិញនាំចូល = CIF + ពន្ធគយ + អាករពិសេស (ប្រសិនបើមាន)
  - ការផ្គត់ផ្គង់ទំនិញឬសេវា = ថ្លៃទំនិញ ឬសេវា ដែលអ្នកផ្គត់ផ្គង់គិតពីអតិថិជន
  - ការផ្តល់ជាអំណោយ ឬលក់ក្រោមថ្លៃពិត = តម្លៃទីផ្សារ
  - ក្នុងករណីតម្លៃជាប់អាកររបស់ទំនិញ ឬសេវាមិនអាចកំណត់បាន រដ្ឋបាលសារពើពន្ធ អាចធ្វើការកំណត់តម្លៃបាន (ដោយផ្អែកលើគោលការណ៍តម្លៃទីផ្សារ)

**ច.អាករលើធាតុចូល និងអាករលើធាតុចេញ**

- ទំនិញ ឬសេវា ទិញសម្រាប់អាជីវកម្មហៅថាធាតុចូល ហើយអាករបង់លើការទិញទំនិញ និងសេវា ហៅថា **អាករលើធាតុចូល**។
- ទំនិញ ឬសេវាផ្គត់ផ្គង់ឲ្យអតិថិជន ហៅថាធាតុចេញ ហើយអាករដែលប្រមូលលើការផ្គត់ផ្គង់ទំនិញ ឬសេវា ហៅថា **អាករលើធាតុចេញ។**

**ឆ.អាករលើធាតុចូលដែលអាចស្នើសុំឥណទាន**

លក្ខខណ្ឌក្នុងការស្នើសុំឥណទានអតបៈ

- ទំនិញ និងសេវា ត្រូវទិញដើម្បីធ្វើការលក់ ឬផ្គត់ផ្គង់ជាប់អាករ ឬសម្រាប់ប្រើប្រាស់ដើម្បីធ្វើការផ្គត់ផ្គង់ជាប់អតបរបស់បុគ្គលជាប់អតប
- ប្រតិវេទន៍គយបញ្ជាក់ត្រឹមត្រូវ អំពីអាករលើធាតុចូលរបស់ទំនិញនាំចូល
- វិក្កយបត្រអាករសម្រាប់អាករលើធាតុចូលនៃការទិញក្នុងស្រុកពីអ្នកផ្គត់ផ្គង់ចុះបញ្ជីអតប
- ពាក្យស្នើសុំត្រូវធ្វើឡើងតាមទម្រង់កំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ
- ត្រូវមានឯកសារភស្តុតាងត្រឹមត្រូវច្បាស់លាស់ជូនអគ្គនាយកដ្ឋានពន្ធដារបញ្ជាក់ថាបុគ្គលបានបង់អតប ពិតមែន ដែលអាចអនុញ្ញាតជាឥណទាន
- ឥណទានអាករ ត្រូវបានអនុញ្ញាតជាឥណទានអាករលើធាតុចូលសម្រាប់អតបបង់លើ៖
  - រាល់ការទិញទាំងអស់ដែលធ្វើឡើងក្នុងខែ
  - រាល់ការនាំចូលទំនិញទាំងអស់ក្នុងខែ

- ឥណទានអតប អនុញ្ញាតបានលុះត្រាតែការផ្គត់ផ្គង់ទំនិញនាំចូលជាប់អតបនោះ ទាក់ទិននឹងសកម្មភាពអាជីវកម្មជាប់អតប។

**ជ.អាករលើធាតុចូលដែលមិនអាចស្នើសុំឥណទាន**

មិនត្រូវបានអនុញ្ញាតឲ្យជាឥណទានអតបលើធាតុចូល ចំពោះប្រាក់អតបដែលបានបង់លើ៖

- ចំណាយទទួលភ្ញៀវ ការកំសាន្ត ឬការសម្រាកលំហែ លើកលែងតែបុគ្គលជាប់អតប មានអាជីវកម្មជាអ្នកផ្គត់ផ្គង់ការទទួលភ្ញៀវ ការកំសាន្ត ឬការសម្រាកលំហែ
- ការទិញឬការនាំចូល រថយន្តលើកលែងតែបុគ្គលជាប់អតបប្រកបអាជីវកម្មជាអ្នកលក់ ឬជួលរថយន្ត
- ការទិញ ឬការនាំចូលផលិតផលតេលសិលាមួយចំនួន លើកលែងតែបុគ្គលជាប់អតបប្រកបអាជីវកម្មជាអ្នកផ្គត់ផ្គង់ផលិតផលតេលសិលាទាំងនេះ
- អាករលើទំនិញ ឬសេវាផ្គត់ផ្គង់ដោយបុគ្គលមិនមែនចុះបញ្ជីអតប
- អតបបង់លើសេវាទូរស័ព្ទចល័ត

## ១.៨.១៥.ពន្ធលើប្រាក់ចំណូល

**ក.និយមន័យ**

ពន្ធលើប្រាក់ចំណូល គឺជាបំណុលពន្ធរបស់បុគ្គលនិវាសនជនចំពោះប្រាក់ចំណូលប្រភពកម្ពុជា និងប្រាក់ចំណូលប្រភពបរទេស និងជាបំណុលរបស់បុគ្គលអនិវាសនជន ចំពោះប្រាក់ចំណូលប្រភពកម្ពុជា។

**ខ.អត្រាពន្ធ**

អត្រាពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំមានដូចតទៅ៖

- ២០ ភាគរយ ចំពោះប្រាក់ចំណូលដែលសម្រេចបានដោយនីតិបុគ្គល
- ៣០ ភាគរយ ចំពោះប្រាក់ចំណូលដែលសម្រេចបានក្រោមកិច្ចសន្យាបែងចែកផលិតផលប្រេងកាត និង ឧស្ម័នធម្មជាតិ ឬសម្រេចបានពីការធ្វើអាជីវកម្មលើធនធានធម្មជាតិ រួមទាំងព្រៃឈើ រ៉ែ មាស ឬត្បូងថ្មមានតម្លៃនានា
- ០ ភាគរយ ចំពោះប្រាក់ចំណូលរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលស្ថិតនៅក្នុងរយៈពេលលើកលែងពន្ធ ដែលកំណត់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- តាមតារាងអត្រាពន្ធកំណើនតាមថ្នាក់ខាងក្រោម ចំពោះប្រាក់ចំណូលជាប់ពន្ធដែលសម្រេចបានដោយរូបវន្តបុគ្គល សហគ្រាសឯកបុគ្គល និងចំណែកដែលត្រូវបែងចែកឲ្យសមាជិកក្រុមម្នាក់ៗរបស់ក្រុមហ៊ុនសហកម្មសិទ្ធមិនត្រូវបានចាត់ទុកជានីតិបុគ្គល ៖

## តារាងទី៥៖ តារាងអត្រាពន្ធកំណើនតាមថ្នាក់

| ភាគនៃប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ | | អត្រាពន្ធ |
|---|---|---|
| ពី | ០៛ ដល់ ១២ ០០០ ០០០៛ | ០% |
| ពី | ១២ ០០០ ០០១៛ ដល់ ១៨ ០០០ ០០០៛ | ៥% |
| ពី | ១៨ ០០០ ០០១៛ ដល់ ១០២ ០០០ ០០០៛ | ១០% |
| ពី | ១០២ ០០០ ០០១៛ ដល់ ១៥០ ០០០ ០០០៛ | ១៥% |
| លើសពី ១៥០ ០០០ ០០០ | | ២០% |

- សម្រាប់សហគ្រាសធានារ៉ាប់រង អត្រាពន្ធលើប្រាក់ចំណូលគិតតាមអត្រាដូចខាងក្រោម៖
  - ៥% នៃបុព្វលាភធានារ៉ាបរងដុលដែលទទួលបានក្នុងឆ្នាំជាប់ពន្ធ ចំពោះសកម្មភាពធានារ៉ាប់រង ឬធានារ៉ាប់រងបន្តលើទ្រព្យសម្បត្តិ ឬហានិភ័យផ្សេងៗនៅព្រះរាជាណាចក្រកម្ពុជា
  - ២០% ចំពោះសកម្មភាពធានារ៉ាប់រង ឬធានារ៉ាប់រងបន្តលើជីវិតដែលមានលក្ខណៈសន្សំ និងសកម្មភាពដទៃទៀតក្រៅពីធានារ៉ាបរង ឬធានារ៉ាប់រងបន្តលើទ្រព្យសម្បត្តិ ឬហានិភ័យផ្សេងៗនៅកម្ពុជា។

**គ.ប្រាក់ចំណូលជាប់ពន្ធ**

ប្រាក់ចំណូលជាប់ពន្ធគឺជាប្រាក់ចំណូលសុទ្ធបានមកពីលទ្ធផលទាំងអស់នៃប្រតិបត្តិការគ្រប់ប្រភេទដែលសហគ្រាសសំរេចបាន រួមបញ្ចូលទាំងតំលៃលើសបានមកពីការលក់ចំណែកនានានៃទ្រព្យសកម្មក្នុងពេលកំពុងប្រកបអាជីវកម្មឬនៅពេលបញ្ចប់អាជីវកម្ម ព្រមទាំងប្រាក់ចំណូលអំពីកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ ឬវិនិយោគ ការប្រាក់ ថ្លៃឈ្នួល និងសួយសារផងដែរ។ ប្រាក់ចំណូលជាប់ពន្ធគឺជាចំនួនលម្អៀងរវាងតំលៃនៃទ្រព្យសកម្មសុទ្ធ នាពេលបិទ និង នាពេលបើក នៃរយៈកាលមួយ ដោយត្រូវដកចេញនូវឧបហារិតបន្ថែម និងបូកចូលនូវរាល់ការដកយកមកប្រើប្រាស់ផ្ទាល់ខ្លួន ឬការកាត់យកមុន ដែលម្ចាស់សហគ្រាសឯកបុគ្គលបានធ្វើនៅក្នុងគ្រា។

$$P = I + D - Ci$$

Capital = Total Assets-Total liabilities = (net assets)

Closing capital – Opening capital = (I) increase in net assets

Capital Introduced = (Ci)

តាមវិធានគណនេយ្យ ប្រាក់ចំណូលពិតគឺជាសមតុល្យនៃគណនី"លទ្ធផលនៃការិយបរិច្ឆេទ" ប៉ុន្តែដោយហេតុមានបទប្បញ្ញត្តិសារពើពន្ធដោយឡែក នោះលទ្ធផលពិតគណនេយ្យត្រូវតែជាកម្មវត្ថុនៃការកែតម្រូវក្រោគណនេយ្យដែលមានការបញ្ចូលមកវិញ និងការកាត់ចេញផ្សេងៗ។ ដោយហេតុថាមានបទប្បញ្ញត្តិដោយឡែកខាងពន្ធដារ ប្រាក់ចំណូលជាប់ពន្ធតាមធម្មតា មិនស្មើគ្នា នឹងប្រាក់ចំណូលគណនេយ្យទេ។

**ឃ.ការគណនាពន្ធលើប្រាក់ចំណូល**

ត្រូវយកលទ្ធផលគណនេយ្យនៃឆ្នាំជាប់ពន្ធនោះមកកែតម្រូវផ្សេងៗដូចខាងក្រោម៖

- បូក ចំណាយមិនអាចកាត់កងបាន(ក)
- បូក ចំណូលជាប់ពន្ធតែមិនបានកត់ត្រាក្នុងបញ្ជីគណនេយ្យ(ខ)
- ដក ចំណាយមិនបានកត់ត្រាក្នុងបញ្ជីគណនេយ្យ តែជាចំណាយកាត់កងបានក្នុងឆ្នាំ(គ)
- ដក ចំណូលបានកត់ត្រាក្នុងបញ្ជីគណនេយ្យ តែជាចំណូលមិនត្រូវជាប់ពន្ធក្នុងឆ្នាំ(ឃ)
- **ប្រាក់ចំនេញឬ(ខាត)ក្រោយនិយ័តកម្ម**

  បូក ចំណាយសប្បុរសធម៌ដែលមិនឲ្យកាត់កង(ង)
- **ប្រាក់ចំនេញឬ(ខាត) មុននិយ័តកម្មការប្រាក់**

  បូក(ដក) និយ័តកម្មលើការប្រាក់(ច)
- **ប្រាក់ចំនេញឬ(ខាត) ក្នុងការិយបរិច្ឆេទ**

  (ដក)ខាតយោងពីឆ្នាំមុនអនុញ្ញាត(ឆ)
- **ប្រាក់ចំនេញ ឬ (ខាត) ជាប់ពន្ធ សំរាប់គណនាពន្ធលើប្រាក់ចំណូលគុណនឹងអត្រាពន្ធលើប្រាក់ចំណូល**

  (ដក)ឥណទានពន្ធបរទេស(ជ)

  (ដក)ឥណទានពន្ធបន្ថែមលើការបែងចែកភាគលាភក្នុងឆ្នាំ
- **បំណុលពន្ធលើប្រាក់ចំណូល/ពន្ធអប្បបរមា (ណាមួយខ្ពស់ជាងគេ)**

  (ដក)ឥណទានពន្ធកាត់ទុក

  (ដក)ប្រាក់រំដោះពន្ធលើប្រាក់ចំណូល
- **ពន្ធលើប្រាក់ចំណូល/ពន្ធអប្បបរមា ត្រូវបង់ ឬ យោងទៅឆ្នាំបន្ទាប់**

**(ក)ចំណាយមិនអាចកាត់កងបាន**

ចំណាយដែលមិនអនុញ្ញាតឲ្យដាត់ចេញមាន៖

- ចំណាយរំលស់គណនេយ្យ
- ចំណាយលើការដើរកំសាន្តសប្បាយ ការលំហែកំសាន្ត និងទទួលភ្ញៀវ
- ការកើនឡើងនូវសំវិធានធន
- អំណោយ និងឧបត្ថម្ភធនផ្សេងៗ
- ខាតពីការលក់ទ្រព្យសកម្មរយៈពេលវែង
- ចំណាយមានលក្ខណៈស្តុកស្តម្ភហួសហេតុមិនអនុញ្ញាត
- ចំណាយមិនបម្រើឲ្យសកម្មភាពអាជីវកម្ម
- ខាតទៅលើប្រតិបត្តិការជាមួយបុគ្គលជាប់ទាក់ទិន
- ចំណាយទៅលើការផាកពិន័យ និងទោសទណ្ឌផ្សេងៗ
- ចំណាយនៃការិយបរិច្ឆេទមុន
- ចំណាយពន្ធ និងអាករផ្សេងៗមិនអាចកាត់កងបាន
- លាភការជីវករ និងគ្រួសារ
- ផលប្រយោជន៍ជាវត្ថុជីវករ និងគ្រួសារ
- ចំណាយប្រាក់បៀវត្សមិនបានបើកក្នុងអំឡុងពេល៦០ថ្ងៃនៃឆ្នាំសារពើពន្ធបន្ទាប់
- ចំណាយផ្សេងៗមិនអាចកាត់កងបាន

**(ខ)ចំណូលជាប់ពន្ធតែមិនបានកត់ត្រាក្នុងបញ្ជីគណនេយ្យ**

- ការផ្គត់ផ្គង់ទំនិញ និងសេវាដោយឥតគិតថ្លៃ
- ការដាក់ទ្រព្យសកម្មរយៈពេលវែងដាក់ឲ្យប្រើប្រាស់ដោយឥតគិតថ្លៃ
- ការកែលំអរទ្រព្យសកម្មរយៈពេលវែងដោយជួសជុលមិនគិតយកពីម្ចាស់
- អំណោយ និងឧបត្ថម្ភធនផ្សេងៗមិនទទួលស្គាល់ក្នុងគណនេយ្យ
- ផលចំណេញ តំលៃលើសពីការលក់ទ្រព្យសកម្មរយៈពេលវែងតាមច្បាប់ពន្ធដារ
- ចំណូលផ្សេងៗទៀតដែលមិនបានកត់ត្រាក្នុងបញ្ជីគណនេយ្យ

**(គ)ចំណាយមិនបានកត់ត្រាក្នុងបញ្ជីគណនេយ្យតែជាចំណាយកាត់កងបានក្នុងឆ្នាំ**

- រំលស់អនុញ្ញាតតាមច្បាប់សារពើពន្ធ
- រំលស់ពិសេសអនុញ្ញាតតាមច្បាប់សារពើពន្ធ
- ការថយចុះនូវសំវិធានធន
- ខាតពីការលក់ទ្រព្យសកម្មរយៈពេលវែងតាមច្បាប់ពន្ធដារ

- ចំណាយផ្សេងៗដែលអនុញ្ញាតឲ្យកាត់កងតាមច្បាប់ស្តីពីសារពើពន្ធ តែមិនបានកត់ត្រាក្នុងបញ្ជីគណនេយ្យ

**(ឃ)ចំណូលបានកត់ត្រាក្នុងបញ្ជីគណនេយ្យតែជាចំណូលមិនត្រូវជាប់ពន្ធក្នុងឆ្នាំ**

- ចំណូលពីភាគលាភទទួលបានពីអ្នកជាប់ពន្ធនិវាសនជន
- ចំណូលពីការលក់ទ្រព្យសកម្មរយៈពេលវែង(ចំណេញតាមបញ្ជីគណនេយ្យ)
- ចំណូលផ្សេងៗបានកត់ត្រាក្នុងបញ្ជីគណនេយ្យតែជាចំណូលមិនត្រូវជាប់ពន្ធ

**(ង)ចំណាយសប្បុរសធម៌ដែលមិនអាចកាត់កងបាន**

- បរិច្ចាគឲ្យដល់ស្ថាប័នរដ្ឋាភិបាល និងអង្គការនានាដែលធ្វើសកម្មភាពមិនស្វែងរកចំណេញ
- មិនត្រូវឲ្យលើសពី៥ភាគរយនៃប្រាក់ចំណេញជាប់ពន្ធមុនពេលកាត់កងវិភាគទានសប្បុរសធម៌
- មិនអាចយោងជាចំណាយសំរាប់ឆ្នាំបន្តបន្ទាប់ទៀតបាន

**(ច)កំហិតលើការកាត់កងការប្រាក់**

កំហិតលើការកាត់កងការប្រាក់សំរាប់ឆ្នាំជាប់ពន្ធណាមួយ គឺជាចំនួនទឹកប្រាក់ការប្រាក់អតិបរមា ដែលត្រូវបានអនុញ្ញាតឲ្យកាត់កងនៅក្នុងឆ្នាំជាប់ពន្ធនោះ និងដែលត្រូវគណនាតាមរូបមន្តដូចខាងក្រោម៖

កំហិតលើការប្រាក់= ក + ខ

ក= ៥០%នៃប្រាក់ចំនេញសុទ្ធដែលត្រូវគណនា ដោយគ្មានចំណូលការប្រាក់ ឬចំណាយការប្រាក់

ខ= ចំណូលការប្រាក់ដែលទទួលបាន ឬត្រូវ បានទទួលនៅក្នុងឆ្នាំជាប់ពន្ធ

កំហិតលើការប្រាក់អាចយោងជាចំណាយការប្រាក់សំរាប់ឆ្នាំបន្តបន្ទាប់ទៀតបាន។

**(ឆ)ខាតយោងពីឆ្នាំមុនអាចអនុញ្ញាតឲ្យកាត់កង**

អាចយោងទៅឆ្នាំជាប់ពន្ធបន្តបន្ទាប់រហូតដល់ ឆ្នាំជាប់ពន្ធទី៥

លក្ខខណ្ឌនៃការយោងការខាតបង់មកកាត់ចេញ៖

ក. ភស្តុតាងនៃការយោងខាត៖

- ការខាតបង់ត្រូវមានចុះក្នុងលិខិតប្រកាស
- មានការបញ្ជាក់អះអាងដោយបញ្ជីឯកសារគណនេយ្យដែលត្រូវបានកាន់កាប់ថែរក្សាយ៉ាងល្អ

ខ. អត្តសញ្ញាណសហគ្រាសៈ

- គ្មានការផ្លាស់ប្តូរម្ចាស់សហគ្រាស
- គ្មានការផ្លាស់ប្តូរសកម្មភាពអាជីវកម្ម

គ. រយៈពេលត្រូវយោងមកកាត់ចេញ

- ការខាតបង់ត្រូវយោងមកកាត់ចេញជាដាច់ខាតពីលទ្ធផលនៃការិយបរិច្ឆេទ (ក្រោយ)ទី១ ដែលមានចំណេញ។

**(ជ)ឥណទានពន្ធបរទេស**

ឥណទានពន្ធដែលអនុញ្ញាតឲ្យកាត់កងសំរាប់ឆ្នាំជាប់ពន្ធ និងសំរាប់ប្រាក់ពន្ធដែលបានបង់នៅប្រទេសក្រៅណាមួយ គឺជាចំនួនដែលទាបជាងគេក្នុងចំណោមៈ

- ប្រាក់ពន្ធដែលបានបង់ជាក់ស្តែងនៅប្រទេសក្រៅណាមួយនោះ
- ប្រាក់ពន្ធលើប្រាក់ចំណូលសរុបពីគ្រប់ប្រភព x (ប្រាក់ចំណូលនៅប្រទេសក្រៅនោះ)/(ប្រាក់ចំណូលសរុបពីគ្រប់ប្រភព)

**ខ.ការលើកលែងពន្ធលើប្រាក់ចំណូល**

យោងតាមច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ ស្តីពី វិនិយោគកម្ពុជាលេខ រស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ៈ

- រាជរដ្ឋាភិបាលបានលើកទឹកចិត្តចំពោះគម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការវិនិយោគនៅកម្ពុជា ដោយបានលើកលែងពន្ធលើប្រាក់ចំណូលក្នុងរយៈអនុគ្រោះពន្ធ។
- រយៈពេលលើកលែងពន្ធលើប្រាក់ចំណូល = រយៈពេលគន្លឹះ + រយៈពេល៣ឆ្នាំ + រយៈពេលអាទិភាព។

១. រយៈពេលគន្លឹះគឺចាប់ផ្តើមចេញពីថ្ងៃចេញវិញ្ញាណបនបត្រចុះបញ្ជីស្ថាពរ និងនៅថ្ងៃចុងក្រោយនៃឆ្នាំសារពើពន្ធណាមួយដែលឆាប់ជាងៈ

- មានប្រាក់ចំណេញដំបូង
- មានប្រាក់ចំណូល (ផលរបរ) ៣ឆ្នាំ គិតចាប់ពីមានប្រាក់ចំណូលដំបូង

២. រយៈពេល ៣ ឆ្នាំគឺគិតចាប់ពីឆ្នាំគន្លឹះ និង ២ ឆ្នាំបន្តបន្ទាប់

៣, រយៈពេលអទិភាពគឺ គិតបន្តចាប់ពីរយៈពេល ៣ ឆ្នាំ[30]

**តារាងទី៦៖ តារាងឧទាហរណ៍ការកំណត់រយៈពេលលើកលែងពន្ធ**

<table>
<tr><th>ករណី</th><th>២០០៨</th><th>២០០៩</th><th>២០១០</th><th>២០១១</th><th>២០១២</th><th>២០១៣</th><th>២០១៤</th><th>២០១៥</th><th>២០១៦</th></tr>
<tr><td>១</td><td>ចេញវិញ្ញាន បនប័ត្រជា ស្ថាពរ</td><td>គ្មានផលរបរ</td><td>មានផលរបរ (ចំណេញ)</td><td>មានផលរបរ (ខាត)</td><td>មានផលរបរ (ចំណេញ)</td><td>មានផលរបរ (ខាត)</td><td>មានផលរបរ (ចំណេញ)</td><td>មានផលរបរ (ចំណេញ)</td><td>មានផលរបរ (ចំណេញ)</td></tr>
<tr><td></td><td colspan="2">រយៈពេលគន្លឹះ</td><td colspan="3">រយៈពេលលើកលែងពន្ធ ៣ឆ្នាំ</td><td colspan="3">រយៈពេលអទិភាព</td><td></td></tr>
<tr><td>២</td><td>ចេញវិញ្ញាន បនប័ត្រជា ស្ថាពរ</td><td>គ្មានផលរបរ</td><td>មានផលរបរ (ខាត)</td><td>មានផលរបរ (ខាត)</td><td>មានផលរបរ (ខាត)</td><td>មានផលរបរ (ខាត)</td><td>មានផលរបរ (ចំណេញ)</td><td>មានផលរបរ (ចំណេញ)</td><td>មានផលរបរ (ចំណេញ)</td></tr>
<tr><td></td><td colspan="5">រយៈពេលគន្លឹះ</td><td colspan="3">រយៈពេលលើកលែងពន្ធ ៣ឆ្នាំ</td><td>រយៈពេល អទិភាព</td></tr>
<tr><td>៣</td><td>ចេញវិញ្ញាន បនប័ត្រជា ស្ថាពរ</td><td>គ្មានផលរបរ</td><td>មានផលរបរ (ខាត)</td><td>មានផលរបរ (ខាត)</td><td>មានផលរបរ (ចំណេញ)</td><td>មានផលរបរ (ចំណេញ)</td><td>មានផលរបរ (ខាត)</td><td>មានផលរបរ (ខាត)</td><td>មានផលរបរ (ចំណេញ)</td></tr>
<tr><td></td><td colspan="4">រយៈពេលគន្លឹះ</td><td colspan="3">រយៈពេលលើកលែងពន្ធ ៣ឆ្នាំ</td><td colspan="2">រយៈពេលអទិភាព</td></tr>
</table>

### ១.៨.១៦.ពន្ធប៉ាតង់

#### ក.និយមន័យ

កំណត់នូវវិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់ លើសកម្មភាពអាជីកម្មរបស់អ្នកជាប់ពន្ធ។

ពន្ធប៉ាតង់គឺជាពន្ធប្រចាំឆ្នាំ ដែលត្រូវបានកំណត់លើសកម្មភាពអាជីវកម្ម ដោយផ្អែកលើប្រភេទអ្នកជាប់ពន្ធ និងកម្រិតផលរបរ។

#### ខ.បែបបទនៃការបង់ពន្ធប៉ាតង់

បែបបទនៃការបង់ពន្ធប៉ាតង់ត្រូវបានកំណត់ដូចខាងក្រោម៖

- អ្នកជាប់ពន្ធដែលមានសកម្មភាពអាជីវកម្មច្រើន ត្រូវបង់ពន្ធប៉ាតង់ផ្សេងគ្នាទៅតាមសកម្មភាពអាជីវកម្មនីមួយៗ។ ឧទាហរណ៍ អ្នកជាប់ពន្ធដែលមានសកម្មភាព អាជីវកម្មនីហារ៍ណ អាហារណ៍ ដឹកជញ្ជូន និង សណ្ឋាគារ ត្រូវបង់ពន្ធប៉ាតង់សម្រាប់ ៣ សកម្មភាពអាជីវកម្មផ្សេងគ្នា។
- សកម្មភាពជាឧបម្ព័ន្ធនានានៃសកម្មភាពអាជីវកម្មត្រូវបានចាត់ទុកថា ជាសកម្មអាជីវកម្មតែមួយ។ ឧទាហរណ៍៖ សណ្ឋាគារមួយដែលមានក្លឹបកំសាន្ត ភោជនីយដ្ឋាន កន្លែងម៉ាស្សា

[30] ប្រកាសស្តីពីពន្ធលើប្រាក់ចំណេញ, ១២ ធ្នូ ២០០៣

ក្លឹបហាត់ប្រាណ ឬសកម្មភាពដទៃដែលជាឧបសម្ព័ន្ធនៃសកម្មភាពសណ្ឋាគារដែលស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់អ្នកជាប់ពន្ធតែមួយនិងស្ថិតក្នុងទីតាំងរួមជាមួយសណ្ឋាគារត្រូវបង់ពន្ធប៉ាតង់តែមួយ។

- អ្នកជាប់ពន្ធដលមានសាខា ឃ្លាំង រោងចក្រ រោងជាង សម្រាប់សកម្មភាពអាជីវកម្មតែមួយនៅក្នុងរាជធានី ខេត្តតែមួយ ត្រូវបង់ពន្ធប៉ាតង់តែមួយ។
- អ្នកជាប់ពន្ធដែលមានសកម្មភាពអាជីវកម្មនៅក្នុងរាជធានី ខេត្តផ្សេងគ្នាត្រូវបង់ពន្ធប៉ាតង់ទៅតាមរាជធានី ខេត្តដែលអាជីវកម្មនោះស្ថិតនៅ។

**គ.កម្រិតប្រាក់ពន្ធប៉ាតង់ត្រូវបង់**

ប្រាក់ពន្ធប៉ាតង់ត្រូវបានកំណត់ដូចខាងក្រោម៖

១. អ្នកជាប់ពន្ធតូច ត្រូវបង់ពន្ធប៉ាតង់ប្រចាំឆ្នាំចំនួន ៤ ០០ ០០០រៀល

២. អ្នកជាប់ពន្ធមធ្យម ត្រូវបង់ពន្ធប៉ាតង់ប្រចាំឆ្នាំចំនួន ១ ២០០ ០០០រៀល

៣. អ្នកជាប់ពន្ធធំដែលមានផលរបរ៖

ក. លើសពី ២ ០០០ លានរៀល ដល់ ១០ ០០០ លានរៀល ត្រូវបង់ពន្ធប៉ាតង់ប្រចាំឆ្នាំចំនួន ៣ ០០០ ០០០ រៀល

ខ. លើសពី ១០ ០០០ លានរៀល ត្រូវបង់ពន្ធប៉ាតង់ចំនួន ៥ ០០០ ០០០រៀល។

អ្នកជាប់ពន្ធដែលមានសាខា ឃ្លាំង រោងចក្រ រោងជាង សម្រាប់អាជីវកម្មតែមួយដែលស្ថិតនៅតាមរាជធានី ខេត្តផ្សេងគ្នា ត្រូវបង់ពន្ធប៉ាតង់ចំនួន ៣ ០០០ ០០០ រៀល នៅតាមរាជធានី ខេត្តដែលអាជីវកម្មនោះស្ថិតនៅ។

**ឃ.កាលបរិច្ឆេទបង់ពន្ធ**

ពន្ធប៉ាតង់ត្រូវបង់នៅពេលចាប់ផ្តើមប្រកបអាជីវកម្ម និងក្នុងអំឡុងពេលចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា ជារៀងរាល់ឆ្នាំ សម្រាប់ឆ្នាំបន្តបន្ទាប់។ ពន្ធប៉ាតង់ត្រូវបង់នៅរដ្ឋបាលសារពើពន្ធដែលអ្នកជាប់ពន្ធមានទីកន្លែងប្រកបអាជីវកម្មពិតប្រាកដ។

អ្នកជាប់ពន្ធដែលចាប់ផ្តើមប្រកបអាជីវកម្មក្នុងរយៈពេល ៦ខែដើមឆ្នាំ ត្រូវបង់ប្រាក់ពន្ធប៉ាតង់ពេញមួយឆ្នាំ ប៉ុន្តែប្រសិនបើចាប់ផ្តើមប្រកបអាជីវកម្មក្នុងរយៈពេល ៦ខែចុងឆ្នាំ អ្នកជាប់ពន្ធត្រូវបង់ប្រាក់ពន្ធប៉ាតង់ពាក់កណ្តាល។[31]

[31] ប្រកាសស្តីពីវិធាននីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់, លេខ១៨២១សហវ/ប្រក, ២៥ ធ្នូ ២០១៥។

# ជំពូកទី ២

# ស្ថានភាពទូទៅរបស់សាខា

# ពន្ធដារខណ្ឌចំការមន

# ជំពូកទី២
# ស្ថានភាពទូទៅរបស់សាខាពន្ធដារខណ្ឌចំការមន

## ២.១.សញ្ញាសម្គាល់

ខាងក្រោមនេះគឺជាសញ្ញាសម្គាល់របស់អគ្គនាយកដ្ឋានពន្ធដារ។

រូបភាពទី១ៈ សញ្ញាសម្គាល់

## ២.២.ប្រវត្តិ ទីតាំងភូមិសាស្ត្រ

យោងតាមមាត្រា ១៩នៃអនុក្រឹតលេខ ១៣៩ អនក្រ/បក ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងនាយកដ្ឋានពន្ធដារ ឲ្យទៅជាអគ្គនាយកដ្ឋានពន្ធដារ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅរាជធានីភ្នំពេញ ត្រូវបានបង្កើតសាខាពន្ធដារ ខណ្ឌនីមួយៗ ស្ថិតនៅក្រោមចំណុះផ្ទាល់របស់អគ្គនាយកដ្ឋានពន្ធដារ មានឋានៈស្មើសាខាពន្ធដារ-ខេត្តក្រុង។

សាខាពន្ធដារខណ្ឌចំការមនមានទីតាំងនៅ អាគារលេខ២៨, ផ្លូវលេខ៤៨៨, សង្កាត់ផ្សារដើមថ្កូវ, ខណ្ឌចំការមន, រាជធានីភ្នំពេញ។

ទូរស័ព្ទ: (855) 23 214 319 / 023 214 324

សារអេឡិចត្រូនិក: chamkarmorn@tax.gov.kh




**រូបភាពទី២ ៖ សាខាពន្ធដារខណ្ឌចំការមន**

## ២.៣.បេសកកម្ម

អគ្គនាយកដ្ឋានពន្ធដារ មានបេសកកម្មជារួមជាមួយសាខាពន្ធដាខណ្ឌដោយធ្វើឱ្យសម្រេចការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារតាមការៈ

- ផ្តល់សេវាដល់អ្នកជាប់ពន្ធរួមមាន ការផ្តល់ព័ត៌មាន អប់រំ ពន្យល់ណែនាំ ដើម្បីឱ្យអ្នកជាប់ពន្ធប្រតិបត្តិត្រឹមត្រូវ តាមច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ
- អនុវត្តកម្មវិធីចាប់បង្ខំ ដោយការធ្វើសវនកម្ម ការអនុវត្តវិធានការតឹងទារ និងអនុវត្តទោសទណ្ឌតាមការកំណត់ នៃបទប្បញ្ញត្តិស្តីពីពន្ធដារចំពោះអ្នកជាប់ពន្ធដែលមិនបានប្រតិបត្តិត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិនានា ស្តីពីពន្ធដារ
- ប្រមូលចំណូលពន្ធ តាមការអនុវត្តត្រឹមត្រូវនូវច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ និងបង់គ្រប់គ្រាន់ចូល ថវិកាជាតិ
- ផ្តល់សេវា និងការអប់រំអ្នកជាប់ពន្ធ ដើម្បីធានាឱ្យច្បាប់នានាស្តីពីពន្ធដារត្រូវបានគោរព និងអនុវត្តត្រឹមត្រូវ
- អនុវត្តកម្មវិធីចាប់បង្ខំប្រកបដោយប្រសិទ្ធភាព មានការទទួលខុសត្រូវខ្ពស់ និងស្មើភាពគ្នាចំពោះអ្នកជាប់ពន្ធ ដែលមិនគោរពច្បាប់ និងបទញ្ញត្តិស្តីពីសារពើពន្ធ

- អនុវត្តគោលការណ៍យុត្តិធម៌ក្នុងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ ដើម្បីបង្កើនការជឿទុកចិត្ត ចំពោះរដ្ឋបាលសារពើពន្ធ
- បន្ថយការចំណាយរបស់រដ្ឋបាលសារពើពន្ធ ក្នុងការរៀបចំកម្មវិធី និងកិច្ចដំណើរការរបស់ខ្លួនធ្វើឱ្យមានភាព សាមញ្ញចំពោះតម្រូវការផ្សេងៗ និងបន្ថយការចំណាយរបស់អ្នកជាប់ពន្ធ
- បង្កើនសមត្ថភាព ចំណេះដឹងដល់មន្ត្រីពន្ធដារជាប្រចាំ ដើម្បីបំពេញការងារឱ្យមានប្រសិទ្ធភាព
- បង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងតាមរយៈគោលនយោបាយ កិច្ចដំណើរការការងារ និងប្រព័ន្ធការងារដែល មានភាពច្បាស់លាស់ ទំនើប និងមានការទទួលខុសត្រូវខ្ពស់ចំពោះការងាររបស់ខ្លួន

## ២.៤.ចក្ខុវិស័យ និងគោលដៅនាពេលអនាគត

➢ ចក្ខុវិស័យ

ចក្ខុវិស័យរបស់សាខាពន្ធដារ គឺធ្វើឲ្យមានការទទួលស្គាល់ និងគោរពពីសំណាក់អ្នកជាប់ពន្ធ។

➢ គោលដៅនាពេលអនាគត

គោលដៅនាពេលអនាគតរបស់សាខាពន្ធដារខណ្ឌចំការមនគឺស្ថិតនៅក្រោមការដឹកនាំរបស់អគ្គនាយកដ្ឋាន គឺធ្វើយ៉ាងណាដើម្បីឲ្យប្រមូលពន្ធគ្រប់ផែនការ ឬលើសផែនការ ឬធ្វើការប្រមូលពន្ធឲ្យអស់លទ្ធភាព។

## ២.៥.រចនាសម្ព័ន្ធ

តារាងទី៧៖ រចនាសម្ព័ន្ធរបស់សាខាពន្ធដារខណ្ឌចំការមន



## ២.៦.តួនាទី និងភារកិច្ចរួម

សាខាពន្ធដារខេត្ត-ខណ្ឌមានភារកិច្ចដូចតទៅៈ

- គ្រប់គ្រងនិងប្រមូលពន្ធពីអ្នកជាប់តូចនិងមធ្យម
- ផ្តល់សេវាដល់អ្នកជាប់ពន្ធដើម្បីពង្រឹងការគោរពបទប្បញ្ញត្តិស្តីពីពន្ធដារ
- គ្រប់គ្រង និងចាត់ចែងការដាក់លិខិតប្រកាសសារពើពន្ធរបស់អ្នកជាប់ពន្ធតូចនិងមធ្យម
- រៀបចំ និងអនុវត្តកម្មវិធីសវនកម្មលើឯកសារ និងសវនកម្មមានកម្រិត និងសវនកម្មបង្វិលសង
- រៀបចំផែនការ និងអនុវត្តការទារបំណុលពន្ធ
- ចុះបញ្ជីអ្នកជាប់ពន្ធ ចេញប័ណ្ណប៉ាតង់ កាន់កាប់ថែរក្សាបញ្ជីអ្នកជាប់ពន្ធ ចុះបញ្ជីពន្ធអចលនទ្រព្យ និងចេញវិញ្ញាបនបត្រចុះបញ្ជីតាមប្រភេទពន្ធនានា ដែលតម្រូវដោយច្បាប់ និងកត់ត្រាទិន្នន័យបច្ចុប្បន្នភាពអ្នកជាប់ពន្ធក្នុងប្រព័ន្ធកុំព្យូទ័រ
- ទទួលបន្ទុកក្នុងការប្រមូលពន្ធ មានជាអាគ៌ ពន្ធប្រថាប់ត្រាលើកិច្ចសន្យាផ្គត់ផ្គង់ទំនិញឬសេវាដែលប្រើប្រាស់ថវិការរដ្ឋនិងលើការផ្ទេរភាគហ៊ុនពាក់ព័ន្ធពន្ធតូចនិងមធ្យម ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ ពន្ធលើអចលនទ្រព្យ ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ពន្ធលើអចលនទ្រព្យ ពន្ធលើឈ្នួលផ្ទះនិងដី និងពន្ធតែមប្រ៍
- សហការ និងចូលរួមចំណែកក្នុងការងារនានាពាក់ព័ន្ធនឹងពន្ធដារ។
- បណ្តុះបណ្តាល និងអភិវឌ្ឍសមត្ថភាពមន្ត្រីក្នុងសាខា
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលការងារ ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ជូនទីចាត់ការពន្ធដាររាជធានីភ្នំពេញសម្រាប់សាខាពន្ធដារខេណ្ឌ និងជូនអគ្គនាយកគ្រប់គ្រងអ្នកជាប់ពន្ធតូច និងមធ្យម សម្រាប់សាខាពន្ធដារខេត្ត ខណ្ឌ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការកំណត់របស់អគ្គនាយកដ្ឋាននៃអគ្គនាយកដ្ឋានពន្ធដារ

## ២.៧.តួនាទី និងភារកិច្ចការិយាល័យនីមួយៗ

### ២.៧.១.ការិយាល័យរដ្ឋបាល

ការិយាល័យរដ្ឋបាលមានភារកិច្ចដូចតទៅៈ

- រៀបចំផែនការយុទ្ធសាស្ត្រ និងគោលដៅនានាពាក់ព័ន្ធសវនកម្មពន្ធដាររបស់សាខាពន្ធដារ

- ស្រាវជ្រាវ និងកំណត់ហានិភ័យតាមវិស័យ និងតាមអ្នកជាប់ពន្ធនីមួយៗដើម្បីរៀបចំកម្មវិធីសវនកម្ម
- ប្រមូលទិន្នន័យ និងពត៌មានរបស់អ្នកជាប់ពន្ធពីអង្គភាពពន្ធដារនានា ដើម្បីកសាងកម្មវិធីសវនកម្ម
- រៀបចំកម្មវិធីសវនកម្មរបស់សាខាពន្ធដារ ប្រចាំត្រីមាស ប្រចាំត្រីមាស និងប្រចាំឆ្នាំ ដោយផ្អែកលើការកំណត់ហានិភ័យ
- តាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីសវនកម្ម
- ថែរក្សាសំណុំឯកសារមន្ត្រីពន្ធដាររបស់សាខាពន្ធដារ
- ពិនិត្យ និងតាមដានការប្រតិបត្តិការងាររបស់បន្ត្រី
- រៀបចំសំណើរជូនថ្នាក់ដឹកនាំស្តីពីការជ្រើសរើស តែងតាំង ផ្លាស់ប្តូរ និងលើកទឹកចិត្តដល់មន្ត្រីក្នុងសាខាពន្ធដារ
- រៀបចំផែនការ និងលើកសំណើរបណ្តុះបណ្តាលឬអភិវឌ្ឍសមត្ថភាពមន្ត្រីក្នុងសាខាពន្ធដារ
- គ្រប់គ្រងនិងសម្របសម្រួលការងាររដ្ឋបាលរបស់សាខាពន្ធដារ
- គ្រប់គ្រង និងបែងចែកឯកសារលិខិតស្នាមចេញ ចូលរបស់សាខាពន្ធដារ
- គ្រប់គ្រងថែរក្សាការពារនិងស្នើសុំជួសជុលសម្ភារៈបរិក្ខារការិយាល័យរបស់សាខាពន្ធដារ
- ស្នើសុំ និងបើកផ្តល់ថវិការសម្រាប់ផ្គត់ផ្គង់រាល់មធ្យោបាយ និងសម្ភារៈបរិក្ខារចាំបាច់សម្រាប់បំពេញការងារដល់គ្រប់ការិយាល័យរបស់សាខាពន្ធដារ
- រៀបចំគម្រោងចំណាយ និងសម្ភារៈបរិក្ខារសម្រាប់សំណើរការការងាររបស់សាខាពន្ធដារ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ការិយាល័យ ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ជូនប្រធានសាខា
- បំពេញភារកិច្ចផ្សេងៗទៀតតាមការកំណត់របស់ប្រធានសាខាពន្ធដារ។

### ២.៧.២.ការិយាល័យសេវាអ្នកជាប់ពន្ធ

- អនុវត្តយន្តការផ្តល់សេវាដល់អ្នកជាប់ពន្ធ ប្រកបដោយគុណភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព
- ផ្តល់សេវាពាក់ព័ន្ធកាតព្វកិច្ចពន្ធដារ ជូនអ្នកជាប់ពន្ធជាអាទិ៍ ការផ្តល់ប្រឹក្សា និងការផ្តល់ព័ត៌មាន និងឯកសារពាក់ព័ន្ធនឹងពន្ធដារ

- សហការរៀបចំសិក្ខាសាលា ការបណ្តុះបណ្តាលនិងផ្សព្វផ្សាយជូនអ្នកជាប់ពន្ធ អំពីបទប្បញ្ញត្តិស្តីពីពន្ធដារ
- រៀបចំក្រុមពិភាក្សាជាមួយអ្នកជាប់ពន្ធតាមវិស័យសំខាន់ៗ ដើម្បីទទួលបាននូវសំណូមពរនិងសេចក្តីត្រូវការរបស់អ្នកជាប់ពន្ធ
- ចុះបញ្ជីអ្នកជាប់ពន្ធ ចេញប័ណ្ណប៉ាតង់ កាន់កាប់ថែរក្សាបញ្ជីអ្នកជាប់ពន្ធ ចុះបញ្ជីពន្ធអចលនទ្រព្យ និងចេញវិញ្ញាបនបត្រចុះបញ្ជីតាមប្រភេទពន្ធនានា ដែលតម្រូវដោយច្បាប់និងកត់ត្រាទន្នន័យបច្ចុប្បន្នភាពអ្នកជាប់ពន្ធក្នុងប្រព័ន្ធកុំព្យូទ័រ
- បញ្ចូលទិន្នន័យរបស់អ្នកជាប់ពន្ធ ទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ
- រៀបចំស្ថិតិអ្នកជាប់ពន្ធ និងវាស់ស្ទង់មតិអ្នកជាប់ពន្ធទាក់ទិននឹងគុណភាពសេវាដែលបានផ្តល់ឲ្យ
- ទទួលបន្ទុកក្នុងការប្រមូលពន្ធ មានជាអាទិ៍ ពន្ធប្រថាប់ត្រាលើកិច្ចសន្យាផ្គត់ផ្គង់ទំនិញឬសេវាដែលប្រើប្រាស់ថវិការរដ្ឋនិងលើការផ្ទេរភាគហ៊ុនពាក់ព័ន្ធអ្នកជាប់ពន្ធតូចនិងមធ្យមពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ ពន្ធលើអចលនទ្រព្យ ពន្ធលើឈ្នួលផ្ទះនិងដី និងពន្ធតែមប្រ៊ី។ ដោយឡែក ចំពោះសាខាពន្ធដារខេត្ត ត្រូវបានបន្ថែមភារកិច្ចឲ្យប្រមូលពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធឬសិទ្ធកាន់កាប់អចលនទ្រព្យនិងអចលនទ្រព្យ និងពន្ធលើដីធ្លីមិនបានប្រើប្រាស់
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ការិយាល័យ ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ជូនប្រធានសាខា
- បំពេញភារកិច្ចផ្សេងៗទៀតតាមការកំណត់របស់ប្រធានសាខា

**២.៧.៣.ការិយាល័យចាត់ចែងលិខិតប្រកាស**

ការិយាល័យចាត់ចែងលិខិតប្រកាសមានភារកិច្ចដូចតទៅ

- រៀបចំ និងអនុវត្តទទួលលិខិតប្រកាសសារពើពន្ធ ឲ្យមានប្រសិទ្ធភាព
- ទទួល និងពិនិត្យផ្ទៀងផ្ទាត់លិខិតប្រកាសសារពើពន្ធពីអ្នកជាប់ពន្ធ ដើម្បីធានាថាលិខិតប្រកាសសារពើពន្ធត្រូវបានបំពេញគ្រប់ខ្ទង់ គ្រប់និទ្ទេស និងគណនាបានត្រឹមត្រូវ
- រៀបចំ និងរក្សាទុកសំណុំឯកសារលិខិតប្រកាសសារពើពន្ធរបស់អ្នកជាប់ពន្ធ និងផ្តល់សំណុំឯកសារនេះឲ្យអង្គភាពពាក់ព័ន្ធ

- ពិនិត្យលើភាពមិនប្រក្រតីនៃលិខិតប្រកាសសារពើពន្ធ ដើម្បីធ្វើសវនកម្ម ឬលើកសំណើរធ្វើសវនកម្ម
- ផ្ទៀងផ្ទាត់ការបង់ប្រាក់ពន្ធជាមួយនឹងប្រកាសឥណទាន ប្រកាសឥណទាន និងរបាយការណ៍សមតុល្យគណនីដែលទទួលបានពីធនាគារ
- បញ្ចូលទិន្នន័យនៃការប្រមូលចំណូលសារពើពន្ធ ទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ ដើម្បីធ្វើគណនេយ្យកម្មចំណូលសារពើពន្ធ ដោយរៀបចំនិងផ្ញើសលាកបត្របង់ប្រាក់ចូលថវិការដ្ឋ និងរបាយការណ៍ពាក់ព័ន្ធចំណូលសារពើពន្ធជូនប្រធានសាខា និងអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ
- រៀបចំបញ្ជីឈ្មោះអ្នកជាប់ពន្ធ ដែលស្នើសុំបង្វិលសងអាករលើតម្លៃបន្ថែម ដាក់លិខិតប្រកាសយឺតយ៉ាវ ឬដាក់លិខិតប្រកាសដោយពុំបង់ប្រាក់ពន្ធ និងមិនដាក់លិខិតប្រកាសពន្ធ ដើម្បីអនុវត្តតាមមុខងារ
- ធ្វើចំណាត់ថ្នាក់និងការវាយតម្លៃឥរិយាបថរបស់អ្នកជាប់ពន្ធ ដើម្បីផ្តល់សេវាអប់រំអំពីបទប្បញ្ញត្តិស្តីពីពន្ធដារឬអនុវត្តវិធានការចាប់បង្ខំ ឬស្នើសុំការផ្តល់ការលើកតឹកចិត្តចំពោះអ្នកជាប់ពន្ធដែលគោរពច្បាប់បានល្អ
- កំណាត់មុខសញ្ញាអ្នកជាប់ពន្ធ ដើម្បីអនុវត្តនីតិវិធីលុបចេញពីបញ្ជី ឬដកវិញ្ញាបនបត្រអាករលើតម្លៃបន្ថែម
- ធ្វើរបារការណ៍ស្តីពីសកម្មភាពការងាររបស់ការិយាល័យ ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំជូនប្រធានសាខា
- បំពេញភារកិច្ចផ្សេងៗទៀតតាមការកំណាទ់របស់ប្រធានសាខាពន្ធដារ។

### ២.៧.៤.ការិយាល័យសវនកម្មពន្ធ

- ការិយាល័យសវនកម្មពន្ធមានភារកិច្ចដូចតទៅ
- អនុវត្តផែនការយុទ្ធសាស្ត្រ និងគោលដៅនានាពាក់ព័ន្ធសវនកម្មពន្ធដារ
- ចូលរួមរៀបចំ និងអនុវត្តកម្មវិធីសវនកម្មលើឯកសារនិងសវនកម្មមានកម្រិត ដើម្បីឲ្យអ្នកជាប់ពន្ធគោរពប្រតិបត្តិតាមច្បាប់ស្តីពីសារពើពន្ធ
- រៀបចំផែនការសវនកម្មលើសំណុំឯកសារនីមួយៗ និងពិនិត្យសំណុំឯកសារឡើងវិញដើម្បីរកឲ្យឃើញនូវហានិភ័យដែលពាក់ព័ន្ធនឹងសំណុំឯកសារទាំងនោះ

- ធ្វើសវនកម្មលើឯកសារនិងសវនកម្មមានកម្រិតលើអ្នកជាប់ពន្ធឲ្យបានទាន់ពេលវេលា ប្រកបដោយប្រសិទ្ធិភាព ស្របតាមផែនការយុទ្ធសាស្ត្ររបស់អគ្គនាយកដ្ឋានពន្ធដារ និងដោយអនុលោមតាមនីតិវិធីសវនកម្មជាធរមាន
- ជូនដំណឹងលម្អិតដល់អ្នកជាប់ពន្ធស្តីពីលទ្ធផល ឬការផ្លាស់ប្តូរលទ្ធផលសវនកម្ម
- ធ្វើរបាយការណ៍បញ្ចប់លទ្ធផលសវនកម្មលើអ្នកជាប់ពន្ធនីមួយៗ និងបញ្ជូលសំណុំឯកសារសវនកម្មទៅក្រុមពិនិត្យការងារសវនកម្មឡើងវិញ ដែលក្រុមនេះមានភារកិច្ចពិនិត្យឡើងវិញរាល់ការងារសវនកម្ម ដើម្បីធានានូវអនុលោមភាពជាមួយនីតិវិធីសវនកម្មនិងផែនការយុទ្ធសាស្ត្រ និងសុក្រឹតភាពនៃការកំណត់ពន្ធឡើងវិញ ព្រមទាំងវាយតម្លៃលទ្ធផលការងាររបស់មន្ត្រីសវនកម្ម និងរៀបចំតម្រូវការបណ្តុះបណ្តាលមន្ត្រីសវនកម្ម
- ផ្តល់លទ្ធផលនៃការកំណត់ពន្ធឡើងវិញ ឬការកំណត់ពន្ធជាឯកតោភាគី ចំពោះអ្នកជាប់ពន្ធទៅការិយាល័យចាត់ចែងលិខិតប្រាកាស និងការិយាល័យបំណុល
- គ្រប់គ្រងពត៌មាន តាមដាន និងត្រួតពិនិត្យការងាររបស់មន្ត្រីសវនកម្មនីមួយៗ
- កំណត់បញ្ហា ដើម្បីកែលម្អយុទ្ធសាស្ត្រ ផែនការ កម្មវិធីសបនកម្ម និងនីតិវិធីនៃការជ្រើសរើសអ្នកជាប់ពន្ធ
- កំណត់បញ្ហាប្រឈមក្នុងការធ្វើសវនកម្ម ដើម្បីរកដំណោះស្រាយឲ្យបានទាន់ពេល
- កំណត់តម្រូវការបណ្តុះបណ្តាល ដើម្បីអភិវឌ្ឍសមត្ថភាពជំនាញរបស់មន្ត្រីសវនកម្ម
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ការិយាល័យ ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំជូនប្រធានសាខា
- បំពេញភារកិច្ចផ្សេងៗទៀតតាមការកំណត់របស់ប្រធានសាខាពន្ធដារ។

### ២.៧.៥.ការិយាល័យបំណុល

- ការិយាល័យបំណុលពន្ធមាភារកិច្ចដូចតទៅ
- អនុវត្តផែនការយុទ្ធសាស្ត្រពាក់ពន្ធនឹងការប្រមូលបំណុលពន្ធ
- អនុវត្តវិធានការទារបំណុលពន្ធ អនុលោមតាមបទប្បញ្ញត្តិជាធរមាន
- រៀបចំបញ្ជីឈ្មោះអ្នកជំពាក់បំណុលពន្ធ តាមប្រព័ន្ធគ្រប់គ្រងទិន្នន័យ ដោយមានការផ្ទៀងផ្ទាត់ជាមួយការិយាល័យចាត់ចែងលិខិតប្រកាសនិងការិយាល័យសវនកម្មពាក់ព័ន្ធ

- រៀបចំសំណុំឯកសាររបស់អ្នកជាប់ពន្ធដែលជំពាក់បំណុលពន្ធ និងបញ្ជូនមកនាយកដ្ឋានគ្រប់គ្រងសាខាពន្ធដារខេត្ត ខណ្ឌ
- រៀបចំ និងអនុវត្តផែនការសកម្មភាពប្រមូលបំណុលពន្ធ និងដាក់ចេញនូវវិធានការប្រមូលបំណុលពន្ធប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ
- រៀបចំ និងផ្ញើលិខិតទារបំណុលពន្ធ និងលិខិតរំលឹកការទារបំណុលទៅឲ្យអ្នកជាប់ពន្ធអនុលោមតាមបទប្បញ្ញត្តិជាធរមាន
- ជ្រើសរើសអ្នកជំពាក់បំណុលពន្ធដើម្បីអនុវត្តបិធានការទារបំណុលពន្ធដោយផ្អែកលើហានិភ័យ
- ប្រមូលពត៌មានពីអ្នកជំពាក់បំណុលពន្ធតាមរយៈអ្នកជំពាក់បំណុលពន្ធផ្ទាល់ និងតាមមធ្យោបាយផ្សេងៗ
- ពិនិត្យ និងតាមដានវឌ្ឍនភាពនៃស្ថានភាពបំណុលពន្ធរបស់អ្នកជំពាក់បំណុលពន្ធ និងសំណុំឯកសាររបស់អ្នកជំពាក់បំណុលពន្ធ ដើម្បីជាមូលដ្ឋានក្នុងការចាត់វិធានការទារបំណុលពន្ធ
- ចុះជួប និងជូនដំណឹងដល់អ្នកជាប់បំណុលពន្ធអំពីវិធានការទារបំណុលពន្ធដែលនឹងត្រូវអនុវត្ត
- កត់ត្រានិងតាមដានការវិវឌ្ឍនៃការអនុវត្តវិធានការទារបំណុលពន្ធ និងរក្សាទុកក្នុងសំណុំឯកសាររបស់អ្នកជំពាក់បំណុលពន្ធ
- ស្វែងរក និងទទួលព័ត៌មានហិរញ្ញវត្ថុថ្មីៗពីអង្គភាពពាក់ព័ន្ធនានា អ្នកជាប់ពន្ធ និងតតិយជនដើម្បីវិភាគអំពីលទ្ធភាពរបស់អ្នកជាប់ពន្ធក្នុងការទូទាត់បំណុលពន្ធ
- រៀបចំលិខិតសម្រាប់ផ្ញើជូនក្រសួងស្ថាប័នរដ្ឋនិងឯកជនដែលពាក់ពន្ធ ដើម្បីស្នើសុំកិច្ចសហការក្នុងការអនុវត្តវិធានការតឹងទារបំណុលពន្ធ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ការិយាល័យ ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំជូនប្រធានសាខា
- បំពេញភារកិច្ចផ្សេងៗទៀតតាមការកំណត់របស់ប្រធានសាខាពន្ធដារ។

# ជំពូកទី៣
# ដំណើរការនៃការប្រមូលពន្ធរបស់សាខាពន្ធដារខណ្ឌចំការមន

# ជំពូកទី៣

# ដំណើរការនៃការប្រមូលពន្ធរបស់សាខាពន្ធដារខណ្ឌចំការមន

ការប្រមូលពន្ធរបស់សាខាពន្ធដារខណ្ឌចំការមនជាការប្រមូលពន្ធសំរាប់ថវិការថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ។ ទាក់ទងទៅនិងការប្រមូលពន្ធ ប្រភេទពន្ធទាំងអស់មាន ១៥ ទៅ ១៦ ប្រភេទ ពន្ធ ប៉ុន្តែសាខាពន្ធដារខណ្ឌមិនបានធ្វើការប្រមូលពន្ធទៅលើគ្រប់ប្រភេទពន្ធទាំងអស់នោះទេ ពីព្រោះប្រភេទពន្ធខ្លះត្រូវបានប្រមូលដោយអគ្គនាយកដ្ឋានពន្ធដារឬ ទីចាត់ការអ្នកប្រមូលពន្ធ។ សាខាពន្ធដារខណ្ឌចំការមនធ្វើការប្រមូលពន្ធទៅលើអ្នកជាប់ពន្ធតូច និង ពន្ធមធ្យមសំរាប់សហគ្រាសរូបវន្តបុគ្គលឬនីតិបុគ្គលដែលប្រកបអាជីវកម្មនៅសាខាពន្ធដារខណ្ឌចំការមន។ ការប្រមូលពន្ធរបស់សាខាពន្ធដារខណ្ឌចំការមនធ្វើការប្រព្រឹត្តទៅតាមការិយាល័យនីមួយៗ។ ប៉ុន្តែទន្ទឹម និងការប្រមូលពន្ធបានគឺពាក់ព័ន្ធជាមួយនិងធនធានមនុស្សនិងការផ្តល់សេវា ដោយធនធានមនុស្សដែលនៅក្នុងឆ្នាំ២០១៨ មានចំនួនតែ ៥៥ ទៅ ៥៦នាក់ដែលគួបផ្សំទៅនិងនីតិវិធីនៃការប្រមូលពន្ធរបស់ការិយាល័យនីមួយៗ។

## ៣.១.ការិយាល័យសេវាអ្នកជាប់ពន្ធនិងចុះបញ្ជី

ការិយាល័យសេវាអ្នកជាប់ពន្ធ និងចុះបញ្ជីធ្វើការចុះបញ្ជី និងផ្តល់សេវាជូនអ្នកជាប់ពន្ធ។ ប្រមូលពន្ធទៅលើប្រភេទពន្ធចំនួន ៤ គឺ ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ ពន្ធប្រថាប់ត្រាឯកសារគតិយុត្តិ (មិនប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិទេ ផ្ទេរកម្មសិទ្ធិក៏ប្រថាប់ត្រាដែរប៉ុន្តែអគ្គនាយកដ្ឋានពន្ធដារជាអ្នកទទួលខុសត្រូវ) ពន្ធលើអចលនទ្រព្យ និង ពន្ធលើឈ្នួលផ្ទះ និងដី។

### ៣.១.១.នីតិវិធីនៃការចុះបញ្ជី

ចំពោះសហគ្រាសដែលទើបតែករកើតថ្មី សហគ្រាសនោះមានកាតួកិច្ចមកធ្វើការចុះបញ្ជីនៅការិយាល័យសេវាអ្នកជាប់ពន្ធនិងចុះបញ្ជី។

- **ចំពោះអ្នកជាប់ពន្ធតូច**
  - ❖ ត្រូវភ្ជាប់មកនូវជាមួយឯកសារដូចជា៖
    - លិខិតបញ្ជាក់ការចុះបញ្ជីដែលចេញដោយក្រសួងពាណិជ្ជកម្ម ឬក្រសួង ស្ថាប័នពាក់ព័ន្ធ(ប្រសិនបើមាន)
    - អត្តសញ្ញាណប័ណ្ណសញ្ញាត្តិខ្មែរ ឬ លិខិតឆ្លងដែន
    - រូបថតបច្ចុប្បន្នរបស់ម្ចាស់សហគ្រាស

- លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យ
- អាជ្ញាប័ណ្ណដែលចេញដោយក្រសួង ស្ថាប័ន មានសមត្ថកិច្ច

❖ រយៈពេលកំណត់នៃការចុះបញ្ជីនេះ គឺគិតចាប់ពីពេលដែលឯកសារមានគ្រប់ (មានន័យថាឯកសារដែលបានយកមកដាក់នៅសាខាខណ្ឌពន្ធដារគឺត្រឹមត្រូវ)រយៈពេលមួយសប្តាហ៍

– **ចំពោះអ្នកជាប់ពន្ធមធ្យម**

❖ ឯកសារភ្ជាប់រួមមាន

- លិខិតបញ្ជាក់ការចុះបញ្ជីដែលចេញដោយក្រសួងពាណិជ្ជកម្ម ឬក្រសួង ស្ថាប័នពាក់ព័ន្ធ
- លក្ខន្តិកៈក្រុមហ៊ុន (សហគ្រាសនីតិបុគ្គល)
- លិខិតបញ្ជាក់ការតម្កល់ដើមទុនចុះបញ្ជីនៅធនាគារ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ លិខិតឆ្លងដែន
- សៀវភៅគ្រួសារ ឬ សៀវភៅស្នាក់នៅ
- លិខិតបញ្ជាក់ការស្នាក់នៅ ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច (សម្រាប់ជនបរទេស)
- រូបថតបច្ចុប្បន្ន
- ប័ណ្ណកម្មសិទ្ធិកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំងប្រកបអាជីវកម្ម
- លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធលើអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យ
- វិញ្ញាបនបត្រចុះបញ្ជីរបស់គណៈកម្មាធិការវិនិយោគកម្ពុជា ឬគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ឬអនុកម្មធិការវិនិយោគរាជធានី-ខេត្ត
- អាជ្ញាប័ណ្ណដែលចេញដោយក្រសួង ស្ថាប័ន មានសមត្ថកិច្ច

❖ ចំពោះសហគ្រាសដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មហើយ ត្រូវយកឯកសារមកដាក់ឲ្យបានមុនរយៈពេល ១៥ថ្ងៃនៃថ្ងៃធ្វើការ

**តារាងទី៨៖ ដំណើរការនៃការចុះបញ្ជីរបស់សហគ្រាស**




### ៣.១.២.ការប្រមូលពន្ធការិយាល័យសេវាអ្នកជាប់ពន្ធនិងចុះបញ្ជី

ការិយាល័យសេវាអ្នកជាប់ពន្ធនិងចុះបញ្ជី ប្រមូលពន្ធទៅលើប្រភេទពន្ធចំនួន ៤ ប្រភេទ។ ហើយប្រភេទពន្ធទាំងនោះរួមមាន៖

#### ៣.១.២.១.ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ

នីតិវិធីនៃការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទចំពោះ មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទដែលទើបមកប្រកាសជាលើកដំបូង៖

**តារាងទី៩៖ ដំណើរការនៃការដាក់លិខិតប្រកាសពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ**




❖ ឯកសារភ្ជាប់

- ប័ណ្ណសម្គាល់យានយន្ត ឬវិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តដែលចេញដោយក្រសួងសាធារណៈការនិងដឹកជញ្ជូន ឬបង្កាន់ដៃបង់ពន្ធនាំចូល
- លិខិតបញ្ជាក់ការប្រើប្រាស់យានយន្តចេញដោយឃុំ សង្កាត់ ចំពោះយានយន្តកែឆ្នៃក្នុងស្រុក
- អត្តសញ្ញាណប័ណ្ណសម្គាល់ខ្លួនរបស់ម្ចាស់មធ្យោបាយដឹកជញ្ជូននិងយានជំនិះ ឬលិខិតឆ្លងដែន ឬលិខិតបញ្ជាក់សំបុត្រកំណើតចេញដោយមន្ត្រីអត្រានុកូលដ្ឋាន

- ម្ចាស់យានជំនិះអាចស្នើសុំធ្វើប័ណ្ណសម្គាល់ការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទដោយគ្រាន់តែគូសក្នុងប្រអបដែលមានបង្ហាញក្នុងលិខិតប្រកាសបង់ពន្ធមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទប្រចាំឆ្នាំ។ ការស្នើសុំធ្វើប័ណ្ណនេះត្រូវបង់ថ្លៃសេវាចំនួន ៥ ០០០រៀល។
- ចំពោះម្ចាស់យានជំនិះដែលមានប័ណ្ណសម្គាល់ការបង់ពន្ធមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ មិនតម្រូវឲ្យដាក់លិខិតប្រកាសទេ ម្ចាស់យានជំនិះគ្រាន់តែធ្វើការកាន់ប័ណ្ណសម្គាល់នេះទៅបង់ប្រាក់ពន្ធនៅធនាគារ។
- កាលបរិច្ឆេទបង់ពន្ធ ចាប់ពីថ្ងៃទី០១ ខែមិថុនា រហូតដល់ថ្ងៃទី៣០ខែវិច្ឆិកា នៃឆ្នាំនីមួយៗ។

**៣.១.២.២.ពន្ធលើអចលនទ្រព្យ**

នីតិវិធីនៃការប្រមូលពន្ធលើអចលនទ្រព្យសំរាប់អចលនទ្រព្យដែលមិនធ្លាប់បង់ពន្ធនិងដាក់លិខិតប្រកាស៖

**តារាងទី១០៖ ដំណើរការនៃការដាក់លិខិតប្រកាសពន្ធលើអចលនទ្រព្យ**



❖ ឯកសារភ្ជាប់

- អត្តសញ្ញាណបណ្ណសញ្ញាតិខ្មែរ ឬសំបុត្របញ្ជាក់កំណើត ឬលិខិតឆ្លងដែនសម្រាប់ជនបរទេស។
- សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ទីលំនៅ។
- ប័ណ្ណសម្គាល់កម្មសិទ្ធ ឬបណ្ណសម្គាល់សិទ្ធកាន់កាប់អចលនវត្ថុ ឬវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុដែលចេញដោយរដ្ឋបាលសុរិយោដី ឬឯកសារពាក់ព័ន្ធនឹងការកាន់កាប់អចលនទ្រព្យ ដែលបញ្ជាក់ដោយអាជ្ញាធរឃុំ ឬសង្កាត់ឡើងទៅ។ ក្នុងករណីដែលអចលនទ្រព្យត្រូវបានទិញបង់រំលស់ ម្ចាស់អចលនទ្រព្យត្រូវភ្ជាប់មកជាមួយនូវឯកសារកិច្ចសន្យារវាងអ្នកទិញ និងអ្នកលក់។

❖ កាលបរិច្ឆេទបង់ប្រាក់ពន្ធ និងដាក់លិខិតប្រកាសពន្ធ ចាប់ពីថ្ងៃទី០១ ខែមករាដល់ថ្ងៃទី៣០ ខែកញ្ញា នៃឆ្នាំជាប់ពន្ធនីមួយៗ។

**៣.១.២.៣.ពន្ធលើឈ្នួលផ្ទះ និងដី**

អ្នកជាប់ពន្ធត្រូវបង់ពន្ធលើឈ្នួលផ្ទះនិងដីប្រចាំខែជារៀងរាល់ខែ គិតចាប់ពីថ្ងៃដែលបានចុះកិច្ចសន្យា ឬបានព្រមព្រៀង។នៅពេលដែលអ្នកជាប់ពន្ធមកធ្វើការបង់ប្រាក់ពន្ធជាលើកដំបូង អ្នកជាប់ពន្ធត្រូវមកធ្វើការចុះបញ្ជីនៅការិយាល័យសេវាអ្នកជាប់ពន្ធ និង ចុះបញ្ជី ដែលមាននីតិវិធីដូចខាងក្រោម៖

**តារាងទី១១៖ ដំណើរការនៃការដាក់លិខិតប្រកាសពន្ធលើឈ្នួលផ្ទះ និងដី**

ឯកសារភ្ជាប់

↓

ពាក្យស្នើសុំចុះបញ្ជី

↓

មន្ត្រីបញ្ចូលព័ត៌មានក្នុងប្រពន្ធ

↓

បង់ប្រាក់ពន្ធ

↓

ទទួលបង្កាន់ដៃបង់ប្រាក់ពន្ធ

❖ ឯកសារភ្ជាប់មានដូចជាៈ
  - កិច្ចសន្យាជួល
  - អត្តសញ្ញាណបណ្ណខ្មែររបស់ម្ចាស់ផ្ទះ ឬ ដី
  - អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬសំបុត្របញ្ជាក់កំណើត ឬលិខិតឆ្លងដែនសម្រាប់ជនបរទេស។

❖ សម្រាប់អ្នកជាប់ពន្ធដែលបានចុះបញ្ជីហើយអាចធ្វើការបង់ប្រាក់ពន្ធនៅធនាគារបាន។

**៣.១.២.៤.ពន្ធប្រថាប់ត្រា**

ពន្ធប្រថាប់ត្រា កាលណាមានប្រែប្រួលព័ត៌មាន អ្នកជាប់ពន្ធត្រូវប្រថាប់គឺប្រថាប់មិនរើសពេលវេលាទេ។ ដោយឡែកសាខាពន្ធដារខណ្ឌចំការមន ធ្វើការប្រថាប់ត្រាតែលើឯកសារមួយចំនួនប៉ុណ្ណោះដូចជា លិខិតមានលក្ខណៈគតិយុត្ត(លិខិតស្តីពីការបង្កើតក្រុមហ៊ុន បិទក្រុមហ៊ុន និងរំលាយក្រុមហ៊ុនបញ្ចូលគ្នា) ឯកសាផ្ទេរភាគហ៊ុន និងកិច្ចសន្យាផ្គត់ផ្គង់ទំនិញឬសេវា ដែលប្រើប្រាស់ថវិការរដ្ឋ។

**តារាងទី១២៖ ដំណើរការនៃការដាក់លិខិតប្រកាសពន្ធប្រថាប់ត្រា**



## ៣.២.ការិយាល័យចាត់ចែងលិខិតប្រកាស

ការិយាល័យចាត់ចែងលិខិតប្រកាសមិនបានចុះទៅប្រមូលពន្ធដោយផ្ទាល់ទេ គឺទទួលតែលិខិតប្រកាសតាមរបបស្វ័យប្រកាស។ ការិយាល័យចាត់ចែងលិខិតប្រកាស ទទួលតែលិខិតប្រកាសពន្ធប្រចាំខែ និងប្រចាំឆ្នាំ។ ការិយាល័យចាត់ចែងលិខិតប្រកាសប្រមូលពន្ធទៅលើគ្រប់សហគ្រាសដែលមានចំណាត់ថ្នាក់អ្នកជាប់ពន្ធទាំងពីរប្រភេទគឺសហគ្រាសធុនតូច និងសហគ្រាសធុនមធ្យម។

### ៣.២.១.ការប្រកាសពន្ធប្រចាំខែ

អ្នកជាប់ពន្ធត្រូវដាក់លិខិតប្រកាពន្ធជារាងរាល់ខែដែលច្បាប់បានចែងថា គ្រប់ក្រុមហ៊ុនទាំងអស់ត្រូវបំពេញទៅលើទម្រង់ប្រកាសពន្ធចំនួន ៥ (ក្នុងករណីសហគ្រាសដែរមានអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋ ក្រុមហ៊ុនត្រូវមានលិខិតប្រកាសអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋ) ប៉ុន្តែដោយឡែកជាទូទៅក្រុមហ៊ុនធម្មតាធ្វើការប្រកាសពន្ធលើលិខិតប្រកាសចំនួន៤ទម្រង់តែប៉ុណ្ណោះ។

- លិខិតប្រកាសពន្ធប្រចាំខែដែលត្រូវដាក់មកការិយាល័យលិខិតប្រកាសរួមមាន
  - លិខិតប្រកាសពន្ធលើប្រាក់បៀវត្ស
  - លិខិតប្រកាសពន្ធកាត់ទុក
  - លិខិតប្រាកាសពន្ធអាករលើតម្លៃបន្ថែម
  - លិខិតប្រកាសពន្ធអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋ
  - លិខិតប្រកាសប្រាក់រំដោះពន្ធលើប្រាក់ចំណូល អាករពិសេសលើទំនិញនិងសេវា អាករបំភ្លឺសាធារណៈ អាករលើការស្នាក់នៅ
- ឯកសារដែលតម្រូវឲ្យភ្ជាប់មកជាមួយលិខិតប្រកាសពន្ធប្រចាំខែរួមមាន៖
  - បង្កាន់ដៃបង់ប្រាក់ពន្ធពីធនាគារ
  - ទិន្នានុប្បវត្តិទិញ និង លក់
  - វិក្កយបត្រអាករលើតម្លៃបន្ថែម
  - ប្រតិវេទន៍គយន៍នាំចូល
  - តារាងបៀវត្សបុគ្គលិក
  - តារាងពន្ធកាត់ទុក

### ៣.២.២.ការប្រកាសពន្ធប្រចាំឆ្នាំ

នៅចុងឆ្នាំបន្ទាប់ពី ១២ ខែបានបញ្ចប់ សហគ្រាសទាំងអស់មានកាតួកិច្ចមួយ គឺមកធ្វើការប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ដោយច្បាប់បានអនុញ្ញាតរយៈពេលចំនួន ៣ ខែនៃដើមឆ្នាំបន្ទាប់(ខែ មករា ដល់ ខែមីនានៃឆ្នាំបន្ទាប់ពីឆ្នាំជាប់ពន្ធ)សំរាប់ធ្វើការបិទបញ្ជីប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ។

- លិខិតប្រកាសពន្ធប្រចាំឆ្នាំដែលត្រូវដាក់មកការិយាល័យលិខិតប្រកាសរួមមាន៖
  - ពន្ធលើប្រាក់ចំណូល
  - ពន្ធប៉ាតង់
- ឯកសារភ្ជាប់សំរាប់ការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំមាន៖
  - ទម្រង់លិខិតប្រកាសពន្ធ ពបច ០១

### ៣.២.៣.ដំណើរការនៃការប្រកាសពន្ធ

អ្នកជាប់ពន្ធត្រូវរៀបចំលិខិតប្រកាសពន្ធដោយខ្លួនឯង។ ក្រោយពីរៀបចំលិខិតប្រកាសពន្ធអ្នកជាប់ពន្ធត្រូវទៅបង់ប្រាក់ពន្ធនៅធនាគារ។ នៅពេលដែលអ្នកជាប់ពន្ធទទួលបានបង្កាន់ដៃបង់ប្រាក់ពីធនាគារ អ្នកជាប់ពន្ធត្រូវភ្ជាប់បង្កាន់ដៃបង់ប្រាក់ពន្ធជាមួយនឹងលិខិតប្រកាសពន្ធចំនួនបីច្បាប់មកកាន់ការិយាល័យលិខិតប្រកាស។ ប្រសិនបើអ្នកជាប់ពន្ធយកឯកសារមកដាក់ប្រកាសមុនថ្ងៃទី២០(ចំពោះលិខិតប្រកាសពន្ធប្រចាំខែ) និង មុនថ្ងៃទី៣១ ខែមីនា(ចំពោះលិខិតប្រកាសពន្ធប្រចាំឆ្នាំ)នៅពេលដែលមិនសូវមានអតិថិជនច្រើន នោះមន្ត្រីពន្ធនិងធ្វើការត្រួតពិនិត្យទៅលើលិខិតប្រកាសពន្ធរបស់អ្នកជាប់ពន្ធថា តើទិន្នន័យនិងការគណនាប្រាក់ពន្ធរបស់អ្នកជាប់ពន្ធធ្វើការបំពេញបានត្រឹមត្រូវឬទេ។ បន្ទាប់មកមន្ត្រីនឹងធ្វើការបញ្ចូលព័ត៌មានទៅក្នុងប្រព័ន្ធ។ បន្ទាប់ពីមន្ត្រីបានបញ្ចូលព័ត៌មានទៅក្នុងប្រព័ន្ធរួច អ្នកជាប់ពន្ធត្រូវចាំទទួលលិខិតបញ្ជាក់ការបង់ពន្ធ។

**តារាងទី១៣៖ នីតិវិធីនៃការប្រមូលពន្ធ**




## ៣.៣.ការិយាល័យសវនកម្ម

សវនកម្មពន្ធដារ គឺជាវិធានការដ៏សំខាន់ក្នុងការគ្រប់គ្រង និងប្រមូលពន្ធឲ្យមានតម្លាភាព និងប្រសិទ្ធភាព ដើម្បីធានាសមធម៌ក្នុងការបង់ពន្ធ។ ដោយឡែកនៅក្នុងសាខាពន្ធដារខណ្ឌចំការមនធ្វើតែសវនកម្មលើលិខិតស្នាម និង សវនកម្មមានកម្រិតតែប៉ុណ្ណោះ។

### ៣.៣.១.សវនកម្មលើលិខិតស្នាម

សវនកម្មលើលិខិតស្នាមត្រូវបានធ្វើឡើងនៅទីកន្លែងរដ្ឋបាលសារពើពន្ធ។ ការធ្វើសវនកម្មលើលិខិតស្នាម គឺជាការពិនិត្យវិនិច្ឆ័យលើលិខិតប្រកាសសារពើពន្ធដែលមានមិនប្រក្រតី ឬភាពមិនស៊ីសង្វាក់គ្នារវាងលិខិតប្រកាសសារពើពន្ធដើម្បីធានាបាននូវភាពត្រឹមត្រូវក្នុងការប្រកាសពន្ធរបស់អ្នកជាប់ពន្ធ។ ជាទូទៅសវនកម្មនេះត្រូវផ្តោតសំខាន់ទៅលើចំណុចមិនប្រក្រតីច្បាស់លាស់ និងងាយស្រួលដោះស្រាយដែលបានរកឃើញលើលិខិតប្រកាសសារពើពន្ធ ដូចជាការផ្ទៀងផ្ទាត់

លិខិតប្រកាសពន្ធជាមួយនឹងព័ត៌មានដែលរដ្ឋបាលសារពើពន្ធទទួលបានពីប្រភពផ្សេងៗជាដើម។ ក្នុងនោះរដ្ឋបាលសារពើពន្ធអាចអញ្ជើញអ្នកជាប់ពន្ធមកបំភ្លឺ និងបង្ហាញឯកសារទាក់ទិននឹងភាពមិនប្រក្រតីដែលបានរកឃើញលើលិខិតប្រកាសសារពើពន្ធ។ ក្នុងករណីដែលហានិភ័យទាំងឡាយដែលរកឃើញមានលក្ខណៈស្មុគស្មាញជាប្រពន្ធ័ ឬមានហានិភ័យខ្ពស់ ការធ្វើសវនកម្មលើលិខិតស្នាមត្រូវបានបញ្ឈប់ និងផ្ទេរទៅជាការធ្វើសវនកម្មដល់ទីកន្លែងវិញ។ សវនកម្មប្រភេទនេះ ត្រូវធ្វើក្នុងកំឡុងពេល ១២ខែក្រោយថ្ងៃដាក់លិខិតប្រកាសសារពើពន្ធ។

### ៣.៣.២.សវនកម្មដល់ទីកន្លែង

សវនកម្មដល់ទីកន្លែង គឺជាការចុះធ្វើសវនកម្មដល់ទីតាំងប្រកបអាជីវកម្មរបស់សហគ្រាសដែលជាកម្មវត្ថុនៃការធ្វើសវនកម្ម ដើម្បីពិនិត្យស្ថានភាពអាជីវកម្មជាក់ស្តែង បញ្ជីគណនេយ្យ លិខិតយុត្តិការ និងឯកសារផ្សេងៗ។ សវនកម្មនេះរួមមានសវនកម្មមានកម្រិត និង សវនកម្មពេញលេញ។ ដោយឡែកសាខាពន្ធដារខណ្ឌចំការមនធ្វើតែសវនកម្មមានកម្រិតតែប៉ុណ្ណោះ។

#### ក.សវនកម្មមានកម្រិត

សវនកម្មមានកម្រិត គឺជាការធ្វើសវនកម្មរយៈពេលខ្លីនិងឆាប់ៗទៅលើប្រភេទពន្ធអាករមួយចំនួនជាអាទិ៍មាន អាករពិសេសលើទំនេញនិងសេវាមួយចំនួន អាករសំរាប់បំភ្លឺសាធារណៈ អាករលើតម្លៃបន្ថែមរួមមានទាំងការបង្វិលសងនិងពន្ធអាករផ្សេងទៀតៗ វៀរលែងតែពន្ធលើប្រាក់ចំណូល ដោយពិនិត្យទៅលើចំណុចដែលជាហានិភ័យទាំងឡាយក្នុងបញ្ជីគណនេយ្យ និងឯកសារពាក់ព័ន្ធ។ សវនកម្មនេះធ្វើឡើងចំពោះតែរយៈពេលជាប់ពន្ធក្នុងឆ្នាំជាប់ពន្ធចរន្ត(N) និងឆ្នាំជាប់ពន្ធមុនឆ្នាំជាប់ពន្ធចរន្ត(N-1)។

### ៣.៣.៣.ការជ្រើសរើសសហគ្រាសធ្វើសវនកម្ម

ការជ្រើសរើសសហគ្រាសធ្វើសវនកម្មត្រូវធ្វើឡើងដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

- ការវិភាគហានិភ័យ
- លទ្ធផលបានមកពីការផ្ទៀងផ្ទាត់ផ្គូផ្គងព័ត៌មាន (Crosscheck)
- ព័ត៌មានទទួលបានពីតតិយជន
- ព័ត៌មានអំពីប្រភេទពន្ធឬវិស័យជាក់លាក់ណាមួយ
- ព័ត៌មានរបស់ក្រុមអ្នកជាប់ពន្ធណាមួយ
- ទីតាំងរបស់សហគ្រាស។ល។

### ៣.៣.៤.ដំណើរការនៃការធ្វើសវនកម្ម

រាល់ការធ្វើសវនកម្មទាំងឡាយ ត្រូវបានទទួលប្រភពព័ត៌មានមកពីការិយាល័យចាត់ចែងលិខិតប្រកាស ដែលបានរកឃើញនៅកំហុសឆ្គងរបស់សហគ្រាស បានធ្វើជាកម្មវិធីឬជាព័ត៌មានបញ្ជូនមកការិយាល័យសវនកម្មធ្វើជាកម្មវិធីដើម្បីស្នើសុំទៅអគ្គនាយកដ្ឋាន បន្ទាប់ពីអគ្គនាយកដ្ឋានបានឯកភាពពីកម្មវិធីហើយការិយាល័យសវនកម្មអាចមានសិទ្ធធ្វើសវនកម្មទៅលើសហគ្រាសនីមួយៗ។ មុនពេលចុះធ្វើសវនកម្មមន្ត្រីពន្ធត្រូវធ្វើលិខិតជូនដំណឹងស្តីពីការធ្វើសវនកម្មទៅឲ្យសហគ្រាស។ នៅពេលដែលអ្នកជាប់ពន្ធបានទទួលលិខិតជូនដំណឹងស្តីពីការធ្វើសវនកម្ម អ្នកជាប់ពន្ធអាចស្នើសុំពន្យារពេលចុះធ្វើសវនកម្មដោយផ្អែកលើមូលហេតុសមស្រប (ដោយមិនលើសពី ៣០ថ្ងៃ ក្រោយថ្ងៃត្រូវចុះធ្វើសវនកម្មដែលមានចែងក្នុងលិខិតជូនដំណឹងស្តីពីការធ្វើសវនកម្មឡើយ)។ ក្នុងករណីអ្នកជាប់ពន្ធស្នើសុំពន្យាពេលចាប់ពី ១០ ថ្ងៃ ដល់ ៣០ ថ្ងៃ អ្នកជាប់ពន្ធត្រូវធ្វើការស្នើសុំជាលាយលាក់អក្សរមក ប្រធានសាខាពន្ធដារ។ រាល់ការកំណត់ពន្ធគឺមានតាមដំណាក់កាល។ ក្នុងកំឡុងពេលធ្វើសវនកម្មនៅពេលដែលមន្ត្រីពន្ធរកឃើញប្រាក់ពន្ធ មន្ត្រីពន្ធត្រូវធ្វើរបាយការណ៍ដាក់ជូនទៅអគ្គនាយកដ្ឋាន។ បន្ទាប់ពីមានការឯកភាពទៅលើការកំណត់ពន្ធ ការិយាល័យសវនកម្មមានកាតព្វកិច្ចមួយគឺ ធ្វើសេចក្តីជូនដំណឹងទៅដល់អ្នកជាប់ពន្ធនូវអ្វីដែលមន្ត្រីពន្ធបានកំណត់។ រាល់ការកំណត់ពន្ធរបស់សវនករ គឺត្រូវបានទុករយៈពេល ៣០ថ្ងៃដើម្បីឲ្យអ្នកជាប់ពន្ធធ្វើការតវ៉ា។ ក្នុងករណីអ្នកជាប់ពន្ធយល់ស្របទៅលើការកំណត់ពន្ធរបស់សវនករ គឺអ្នកជាប់ពន្ធត្រូវបង់ប្រាក់ពន្ធទៅតាមការកំណត់។ ដោយឡែកចំពោះករណីដែលអ្នកជាប់ពន្ធមិនឯកភាពទៅលើការកំណត់ពន្ធរបស់សវនករ អ្នកជាប់ពន្ធមានសិទ្ធដាក់ពាក្យតវ៉ាទៅលើការកំណត់ពន្ធ។ បន្ទាប់ពីរយៈពេល៣០ថ្ងៃ ប្រសិនបើសហគ្រាសមិនបានដាក់ពាក្យធ្វើការតវ៉ាហើយមិនបានបង់ពន្ធទេនោះការិយាល័យសវនកម្មមានកាតួកិច្ចមួយគឺ បញ្ជូនសំណុំឯកសារទៅខាងការិយាល័យបំណុល។

ការធ្វើសវនកម្មនេះគឺចង់ជំរុញឲ្យសហគ្រាសគោរពច្បាប់ និង ឲ្យអ្នកជាប់ពន្ធដែលបានគេចពន្ធត្រូវបង់ពន្ធឡើងវិញ។ ការបង់ពន្ធឡើងវិញគឺត្រូវមានពិន័យនិងការប្រាក់។ ការកំណត់ពន្ធខ្លះមិនមែនមានន័យថាទាល់តែសហគ្រាសផ្តល់ឯកសារឲ្យទើបអាចកំណត់ពន្ធបាននោះទេ ប្រសិនបើសហគ្រាសមិនព្រមសហការ ការិយាល័យពន្ធដារមានសិទ្ធកំណត់ពន្ធជាឯកតោភាគី(កំណត់ពន្ធ៥០%)។

## ៣.៤.ការិយាល័យបំណុល

### ៣.៤.១.នីតិវិធីនៃការប្រមូលបំណុលពន្ធ

ជំហានដំបូង មន្ត្រីពន្ធដារមាននីតិសម្បទាត្រូវប្រគល់ លិខិតជូនដំណឹងទារបំណុលពន្ធទៅអ្នកជាប់ពន្ធ ហើយកត់ត្រាប្រវត្តិការងារប្រមូលបំណុលពន្ធ ចំពោះករណីបំណុលពន្ធនីមួយៗ ដោយមានចុះកាលបរិច្ឆេទច្បាស់លាស់។

ប្រសិនបើមានការទូទាត់ក្នុងរយៈពេល៣០ថ្ងៃ ក្រោយពីប្រគល់លិខិតជូនដំណឹងទារបំណុល ជំហានបន្ទាប់ មន្ត្រីពន្ធដារមាននីតិសម្បទាត្រូវប្រគល់លិខិតជូនដំណឹងរំលឹកការទារបំណុលពន្ធ ដោយផ្ទាល់ដៃ ឬផ្ញើតាមប៉ុស្តិ៍ប្រៃសណីយ៍ជាលិខិតអនុសិដ្ឋ ។នៅដំណាក់កាលនេះនឹងមានការកំណត់ពន្ធបន្ថែមចំនួន ១០% នៃទឹកប្រាក់ពន្ធបង់យឺត បូកនឹង ការប្រាក់ ១.៥% ក្នុងមួយខែ នៃទឹកប្រាក់ពន្ធបង់យឺតសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលចំនួនប្រាក់ពន្ធនោះនៅមិនទាន់បានបង់។ហើយការប្រាក់នេះនឹងត្រូវគណនាបូកបន្តរហូតដល់មានការទូទាត់។ លិខិតជូនដំណឹងរំលឹកការទារបំណុលពន្ធនេះ ទុកពេលឲ្យអ្នកជាប់ពន្ធរយៈពេល១៥ថ្ងៃ ដើម្បីទូទាត់បំណុលពន្ធដែលដល់កំណត់ត្រូវបង់។ បើសិនជាអ្នកជំពាក់បំណុលពន្ធមិនបានបង់ក្នុងរយៈពេល១៥ថ្ងៃក្រោយពីបានទទួលលិខិតជូនដំណឹងរំលឹកការទារបំណុលពន្ធទេ ពន្ធបន្ថែមត្រូវកំណត់តាមអត្រា ២៥% នៃទឹកប្រាក់ បូកនឹងការប្រាក់ ១.៥% នៃទឹកប្រាក់ពន្ធបង់យឺតសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលចំនួនប្រាក់ពន្ធនោះនៅមិនទាន់បានបង់។

សាខាពន្ធដារខណ្ឌអាចចុះដល់ទីតាំងអាជីវកម្ម ប្រសិនបើមិនមានការទូទាត់បំណុលពន្ធក្រោយពីការចេញលិខិតជូនដំណឹងរំលឹកការទារបំណុលពន្ធ។ នៅពេលទៅដល់ទីតាំងអាជីវកម្មរបស់អ្នកជាប់ពន្ធ មន្ត្រីពន្ធ ត្រូវសាកសួរពីមូលហេតុដែលមិនទាន់ទូទាត់បំណុលពន្ធ និងពន្យល់អ្នកជាប់ពន្ធអំពីផលវិបាកនៃការមិនទូទាត់បំណុលពន្ធនិងវិធានការតឹងទារបំណុលពន្ធ។

ប្រសិនបើអ្នកជាប់ពន្ធនៅតែមិនព្រមធ្វើការទូទាត់បំណុលពន្ធក្រោយពេលបានទទួលលិខិតជូនដំណឹងរំលឹកការទារបំណុលពន្ធរួច ត្រូវមានវិធានការណ៍៖

- មិនអនុញ្ញាតអោយចុះបញ្ជីពន្ធដារ និងធ្វើបច្ចុប្បន្នភាព
- មិនអនុញ្ញាតអោយចូលរួមដេញថ្លៃកិច្ចសន្យា
- មិនអនុញ្ញាតអោយផ្ទេរកម្មសិទ្ធអចលនទ្រព្យ
- មិនអនុញ្ញាតអោយស្នើសុំលើកលែងពន្ធនៅ CDC
- ទុកជាមោឃៈនូវលិខិតអនុញ្ញាត ឬអាជ្ញាប័ណ្ណ

- បញ្ឈប់ការនាំចូលនាំចេញ
- ជូនដំណឹងទៅធនាគារជាតិ
- ចុះផ្សាយក្នុងទំព័រពតិមាន
- ឃាត់ទុកគណនីក្នុងធនាគារ
- ដាក់ពាក្យបណ្តឹងអ្នកជាប់ពន្ធទៅតុលាការ
- រឹបអូសទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធ

## ៣.៥.របាយការណ៍ចំណូលរបស់សាខាពន្ធដារខណ្ឌចំការមន

### ៣.៥.១.ទិន្នន័យចំណូលសរុបប្រចាំឆ្នាំ

ខាងក្រោមនេះគឺជារបាយការណ៍ចំណូលសរុបប្រចាំឆ្នាំ និងផែនការប្រមូលចំណូលដែលបានដាក់ឲ្យអនុវត្តនៅក្នុងឆ្នាំនីមួយៗ រយៈពេល ៣ឆ្នាំ ដោយគិតចាប់ពីឆ្នាំ២០១៦ ដល់ ឆ្នាំ ២០១៨។

**តារាងទី១៨៖ ទិន្នន័យចំណូលសរុប និងផែនការអនុវត្តក្នុងឆ្នាំនីមួយៗ**

| ឆ្នាំ | ផែនការអនុវត្តក្នុងឆ្នាំ | ទិន្នន័យចំណូលសរុបក្នុងឆ្នាំ |
|---|---|---|
| ២០១៦ | ២៦៨,៣០០ លានរៀល | ៣២៩,៧៩១ លានរៀល |
| ២០១៧ | ៣៧៨,៦៨២ លានរៀល | ៣៦០,៣០៣ លានរៀល |
| ២០១៨ | ៣៦៦,៧០០ លានរៀល | ៤១៤,៧៩៧ លានរៀល |

### ៣.៥.២.ក្រាហ្វិកចំណូលប្រចាំឆ្នាំ

ខាងក្រោមនេះគឺជាក្រាហ្វិកចំណូលប្រចាំឆ្នាំ និងការកើនឡើងនៃចំណូលរបស់សាខាពន្ធដារខណ្ឌចំការមនដែលគិតជាភាគរយ ធៀបទៅនឹងឆ្នាំ ២០១៦។

**រូបភាពទី៣៖ ក្រាហ្វិកចំណូលប្រចាំឆ្នាំ**



តាមរយៈក្រាហ្វិកខាងលើ សាខាពន្ធដារខណ្ឌចំការមនធ្វើការប្រមូលចំណូលនៅក្នុងឆ្នាំ ២០១៦ បានចំនួន ៣២៩,៧៩១ លានរៀល។ រីឯឆ្នាំ ២០១៧ សាខាពន្ធដារធ្វើការប្រមូលចំណូលពន្ធបានចំនួន ៣៦០,៣០៣ លារៀល។ បើធៀបការប្រមូលចំណូលរវាងឆ្នាំ ២០១៧ ធៀបទៅនឹងឆ្នាំ ២០១៦ សាខាពន្ធដារខណ្ឌចំការមនធ្វើការប្រមូលចំណូលកើនឡើងបានចំនួន ៩.២៥%។ ចំណែកឯឆ្នាំ២០១៨ វិញសាខាពន្ធដារខណ្ឌចំការមនធ្វើការប្រមូលចំណូលបានចំនួន ៤១៤,៧៩៧ លានរៀល ដោយមានការកើនឡើងនៃចំណូលពន្ធដារចំនួន ២៥.៧៨% ដោយធៀបចំណូលពន្ធដារឆ្នាំ ២០១៨ ធៀបទៅនឹងឆ្នាំ ២០១៦។

### ៣.៥.៣.ក្រាហ្វិកចំណូលប្រចាំឆ្នាំរវាងផែនការកំណត់ និងការអនុវត្តក្នុងឆ្នាំ

ខាងក្រោមនេះគឺជាក្រាបប្រៀបធៀបរវាងផែនការប្រមូលចំណូលដែលអគ្គនាយកដ្ឋានពន្ធដារបានកំណត់ និងការអនុវត្តការប្រមូលចំណូលក្នុងឆ្នាំ ដែលគិតចាប់ពីឆ្នាំ ២០១៦ ដល់ឆ្នាំ ២០១៨ ដើម្បីប្រៀបធៀបពីលទ្ធផលដែលសាខាពន្ធដារខណ្ឌចំការមនសម្រេចបាន។

**រូបភាពទី៤៖ ក្រាបនៃចំណូលប្រចាំឆ្នាំរវាងផែនការកំណត់ និងការអនុវត្តក្នុងឆ្នាំ**




| | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|
| ផែនការអនុវត្ត | 268,300 | 374,682 | 366,700 |
| អនុវត្តក្នុងឆ្នាំ | 329,791 | 360,303 | 414,797 |
| អត្រាកំណើនគិតជា% | 122.92% | 96.16% | 113.12% |

យោងតាមក្រាបខាងលើនេះ យើងសង្កេតឃើញថានៅ ឆ្នាំ២០១៦ ផែនការប្រមូលចំណូលដែលអគ្គនាយកដ្ឋានពន្ធដារបានកំណត់មានចំនួន ២៦៨,៣០០ លានរៀល ប៉ុន្តែដោយឡែកការអនុវត្តជាក់ស្តែងនៅក្នុងឆ្នាំ ២០១៦ សាខាពន្ធដារខណ្ឌចំការមនធ្វើការប្រមូលចំណូលបានរហូតដល់ ៣២៩,៧៩១ លានរៀល ដែលស្មើនឹង ១២២.៩២% ដែលលើសពីផែនការកំណត់ចំនួន ២២.៩២%។

ក្នុងឆ្នាំ ២០១៧ ផែនការប្រមូលចំណូលដែលអគ្គនាយកដ្ឋានពន្ធដារបានកំណត់ឲ្យសាខាពន្ធដារខណ្ឌចំការមនអនុវត្តមានចំនួន ៣៧៤,៦៨២ លានរៀល ដោយការអនុវត្តជាក់ស្តែងនៅក្នុង ឆ្នាំ២០១៧ សាខាពន្ធដារខណ្ឌចំការមន ធ្វើការប្រមូលចំណូលបាន ៣៦០,៣០៣ លានរៀល ដែលស្មើនឹង ៩៦.១៦% ដែលជិតគ្រប់ផែនការកំណត់ ដោយខ្វះត្រឹមតែចំនួន ៣.៨៤% នៃចំនួនដែលអគ្គនាយកដ្ឋានពន្ធដារបានដាក់ឲ្យអនុវត្ត។

នៅ ឆ្នាំ២០១៨ ផែនការប្រមូលចំណូលដែលបានកំណត់មានចំនួន ៣៦៦,៧០០ លានរៀល ប៉ុន្តែដោយឡែកការអនុវត្តជាក់ស្តែងនៅក្នុងឆ្នាំ ២០១៨ សាខាពន្ធដារខណ្ឌចំការមនធ្វើការប្រមូលចំណូលបានរហូតដល់ ៤១៤,៧៩៧ លានរៀល ដែលស្មើនឹង ១១៣.១២% ដែលលើសពីផែនការកំណត់ចំនួន ១៣.១២%។

តាមរយៈការវិភាគខាងលើនេះ យើងអាចធ្វើការសន្និដ្ឋានបានថាសាខាពន្ធដារខណ្ឌចំការមនធ្វើការប្រមូលចំណូលរយៈពេលបីឆ្នាំចុងក្រោយនេះ ដោយគិតចាប់ពីឆ្នាំ ២០១៦ ដល់ឆ្នាំ ២០១៨ មានការកើនឡើងនៃចំណូលពន្ធដារគួរឲ្យកត់សម្គាល់។ ចំណោកឯផែនការប្រមូលពន្ធដែលកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារវិញ សាខាពន្ធដារខណ្ឌចំការមនបានប្រមូលលើសពីផែនការកំណត់នៅក្នុងឆ្នាំ ២០១៦ និង ឆ្នាំ២០១៨។ ដោយឡែកនៅឆ្នាំ ២០១៧ សាខាពន្ធដារធ្វើការប្រមូលពន្ធជិតគ្រប់ចំនួនដែលផែនការបានកំណត់។ ការប្រមូលពន្ធមិនគ្រប់ផែនការកំណត់នេះគឺបណ្តាលមកពីចំនួននៃតួលេខដែលផែនការបានកំណត់មានចំនួនច្រើន។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ការប្រមូលពន្ធរបស់សាខាពន្ធដារខណ្ឌចំការមនមានលក្ខណៈល្អប្រសើរពីមួយឆ្នាំទៅមួយឆ្នាំ។

# សេចក្តីសន្និដ្ឋាន និង
# ការផ្តល់អនុសាសន៍

## ១.សេចក្តីសន្និដ្ឋាន

យោងតាមការវិភាគ និងការសិក្សាស្រាវជ្រាវទៅលើប្រធានបទ បរិបទនៃការប្រមូលពន្ធរបស់សាខាពន្ធដារខណ្ឌចំការមន តាមរយៈច្បាប់សារពើពន្ធ និងការចុះកម្មសិក្សា នាងខ្ញុំសង្កេតឃើញថាវិស័យពន្ធនៃព្រះរាជាណាចក្រកម្ពុជាមានការធ្វើវិសោធនកម្ម និងមានភាពល្អប្រសើរដោយរបបកំណតពន្ធនៅប្រទេសកម្ពុជាបានបង្រួមឲ្យនៅសល់តែមួយរបបតែប៉ុណ្ណោះ ដែលជាហេតុធ្វើឲ្យមានការងាយស្រួលចំពោះអ្នកជាប់ពន្ធនៅក្នុងការបង់ពន្ធ។ នៅក្នុងការបង់ប្រាក់ពន្ធក៏ដូចជាការចាំទទួលលិខិតប្រកាសពន្ធ អ្នកជាប់ពន្ធមានភាពងាយស្រួលជាងមុនគួរឲ្យកត់សម្គាល់ដោយអ្នកជាប់ពន្ធ អាចចាំទទួលលិខិតប្រកាសពន្ធប្រចាំខែ និង លិខិតប្រកាសពន្ធប្រចាំឆ្នាំក្នុងថ្ងៃដែលដាក់លិខិតប្រកាសពន្ធជាមួយគ្នាបាន។ ម្យ៉ាងវិញទៀត រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់នៅក្នុងការគៀងគងចំណូលពីមួយឆ្នាំទៅមួយឆ្នាំដែលជាហេតុធ្វើឲ្យចំណូលរបស់ពន្ធដារបានកើនឡើង។ ជាក់ស្តែង ទិន្នន័យប្រមូលចំណូលសរុបក្នុងមួយឆ្នាំៗ នៅសាខាពន្ធដារខណ្ឌចំការមនមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ រីឯការអនុវត្តប្រមូលចំណូលសរុបធៀបទៅនឹងផែនការកំណត់ក៏មានភាពល្អប្រសើរដែរ បើទោះបីជានៅឆ្នាំ២០១៧ សាខាពន្ធដារធ្វើការប្រមូលចំណូលខ្វះចំនួន ៣.៨៥%នៃចំនួនផែនការកំណត់ ប៉ុន្តែការប្រមូលចំណូលនេះគឺជិតគ្រប់ចំនួនដែលផែនការកំណត់។ លទ្ធផលគួរឲ្យកត់សម្គាល់នេះគឺបានមកពីការខិតខំប្រឹងប្រែងរបស់មន្ត្រីគ្រប់ជាន់ថ្នាក់ទាំងអស់ ដែលខិតខំប្រឹងប្រែងអស់ពីសម្ថភាពក្នុងការផ្តល់សេវាជូនអ្នកជាប់ពន្ធ ក៏ដូចជាការឆ្លើយសំនួរចំពោះរាល់ចម្ងល់ដែលអ្នកជាប់ពន្ធមាន។ ការខិតខំប្រឹងប្រែងក្នុងការធ្វើជាសិក្ខាសិលាផ្សព្វផ្សាយជូនអ្នកជាប់ពន្ធ ដើម្បីឲ្យគាត់បានយល់ដឹងពីសារៈសំខាន់នៃការបង់ពន្ធ ក៏ដូចជាទោសទណ្ឌនៅក្នុងការប្រព្រឹត្តបទល្មើសពន្ធដារ។ ប៉ុន្តែបើទោះបីជាមានការខិតខំប្រឹងប្រែងយ៉ាងណាក៏ដោយ ក៏វិសាលភាពនៃការផ្សព្វផ្សាយឲ្យប្រជាពលរដ្ឋបាលយល់ដឹងពីការបង់ពន្ធនៅមានកម្រិត ដូច្នេះហើយទើបនៅតែមានការប្រព្រឹត្តបទល្មើសពន្ធ ដូចជាអ្នកជាប់ពន្ធមិនព្រមបង់ពន្ធមានការគេចវេសពន្ធ សហគ្រាសមួយចំនួនមានការយឺតយាវនៅក្នុងការដាក់លិខិតប្រកាសពន្ធ។

## ២.អនុសាសន៍

តាមរយៈសេចក្តីសន្និដ្ឋានខាងលើស្តីអំពីលទ្ធផលនៃការស្រាវជ្រាវរបស់ក្រុមនាងខ្ញុំទៅលើប្រធានបទ " បរិបទនៃការប្រមូលពន្ធរបស់សាខាពន្ធដារខណ្ឌចំការមន" នាងខ្ញុំបានរកឃើញនូវចំនុចអវិជ្ជមានមួយចំនួន។ នាងខ្ញុំសូមធ្វើការបញ្ចេញយោបល់ផ្ទាល់ខ្លួន ក្នុងគោលបំណងរិះគន់ក្នុងន័យស្ថាបនាដល់សាខាពន្ធដារខណ្ឌចំការមន។ មតិយោបលរបស់នាងខ្ញុំរួមមាន៖

- បិទប្រកាស ឬជូនដំណឹងផ្សព្វផ្សាយពីព័ត៌មានថ្មីៗដែលទាក់ទងទៅនឹងពន្ធដារនៅតាមបញ្ញោរផ្សព្វផ្សាយពន្ធដារ
- ស្នើរសុំឲ្យមានចំនួនការរៀបចំសិក្ខាសាលាឲ្យបានញឹកញាប់ទៅកាន់អ្នកជាប់ពន្ធ
- បន្ថែមចំនួនមន្ត្រី (ចំនួនមន្ត្រីនៅមានការខ្វះខាត)
- បន្តផ្តល់បច្ចុប្បន្នភាពនៃការបណ្តុះបណ្តាលដល់មន្ត្រី ស្តីពីច្បាប់ អនុក្រឹត្យ ប្រកាស សារាចរណ៍ និងសេចក្តីជូនដំណឹងថ្មីៗ
- ការធ្វើផែនការគួរកំណត់តាមមូលដ្ឋានកំណើនភាគរយប្រមូលពន្ធពីឆ្នាំចាស់ ដែលធ្វើឲ្យកំណើននៃការប្រមូលពន្ធសមស្របតាមផែនការ

# ឯកសារយោង

# ឯកសារយោង

១. ច្បាប់ស្តីពីសារពើពន្ធឆ្នាំ១៩៩៧

២. ច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ១៩៩៤

៣. ច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ២០១៦

៤. ច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ២០១៧

៥. ច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ២០១៨

៦. អនុក្រឹត្យស្តីពីអាករលើតម្លៃបន្ថែម, លេខ១១៤ អនក្រ/បក, ២៤ ធ្នូ ១៩៩៩

៧. អនុក្រឹត្យស្តីពីការកែសម្រួលតារាងពន្ធតែមប្រើសារពើពន្ធ, លេខ៤០អនក្រ/បក, ៣១ មីនា ២០១៥

៨. ប្រកាសស្តីពីពន្ធលើប្រាក់ចំណេញ, ១២ ធ្នូ ២០០៣

៩. ប្រកាសស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់,លេខ ២២៤ ប្រក.សហវ.ពដ ចុះថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ១៩៩៦

១០. ប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងនិងប្រមូលអាករសម្រាប់បំភ្លឺសាធារណៈ, លេខ ១៧៥សហវ/ពដ/ប្រក, ២២ មករា ២០០២

១១. ប្រកាសស្តីពីពន្ធលើប្រាក់បៀវត្ស, លេខ១១៧៣សហវ/ពដ/ប្រក, ៣១ ធ្នូ ២០០៣

១២. ប្រកាសស្តីពីការអនុវត្តអាករលើការស្នាក់នៅ, លេខ៣៨០សហវ/ពដ, ១៤ កក្កដា ២០០៥

១៣. ប្រកាសស្តីពីការប្រមូលពន្ធអចលនទ្រព្យ, លេខ៤៩៣សហវ/ប្រក, ១៩ កក្កដា ២០១០

១៤. ប្រកាសស្តីពីតម្លៃគិតពន្ធអចលនទ្រព្យ, លេខ៣៧១សហវ/ប្រក, ០៥ ឧសភា ២០១១

១៥. ប្រកាសស្តីពីវិធាននីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់, លេខ១៨២១សហវ/ប្រក, ២៥ ធ្នូ ២០១៥

១៦. ប្រកាសស្តីពីការកែសម្រួលកាលបរិច្ឆេទដាក់លិខិតប្រកាសពន្ធប្រចាំខែ, លេខ១៥៣៩ សហវ/ប្រ.ក, ២៣ ធ្នូ ២០១៦

១៧. ប្រកាសស្តីពីការប្រមូលពន្ធប្រថាប់ត្រា,លេខ ៥០៧ សហវ/ប្រក ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ២០១៧

១៨. ប្រកាសស្តីពីការណែនាំអនុវត្តអាករលើតម្លៃបន្ថែមចំពោះការផ្គត់ផ្គង់មិនជាប់អាករ, លេខ ៥៥៩ សហវ/ប្រក, ២៥ ឧសភា ២០១៧

១៩. ប្រកាសស្តីពីការកំណត់មូលដ្ឋានគិតអាករសម្រាប់បំភ្លឺសាធារណៈ, លេខ៩៧៦សហវ/ប្រក, ០៩ តុលា ២០១៧

២០. ប្រកាសស្តីពីការកែសម្រួលចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស,លេខ ០២៥ សហប្រ.កអពដ ចុះថ្ងៃទី ២៥ ខែមីនា ឆ្នាំ ២០១៨

២១. ប្រកាសស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទប្រចាំឆ្នាំ, លេខ៥៣២សហវ/ប្រក, ៣០ ឧសភា ២០១៨

២២. ប្រកាសស្តីពីការព្យួរទុកការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូលរបស់សហគ្រាសប្រកបអាជីវកម្មក្នុងវិស័យកសិកម្ម, លេខ១០០/សហវ/ប្រក, ២៩ មករា ២០១៩

២៣. ប្រកាសស្តីពីការកំណត់មូលដ្ឋានគិតពន្ធប្រថាប់ត្រាចំពោះការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ,លេខ ៣៨៣ សហវ/ប្រក ចុះថ្ងៃទី ២២ ខែមីនា ឆ្នាំ២០១៩

២៤. ប្រកាសស្តីពីការកែសម្រួលការណែនាំអនុវត្តពន្ធកាត់ទុកលើការបែងចែកភាគលាភ, លេខ៣៧២សហវ/ប្រក, ០៥ មេសា ២០១៩

២៥. សារាចរស្តីពីការអនុវត្តកាតព្វកិច្ចកាត់ទុកពន្ធលើអត្ថប្រយោជន៍បន្ថែម, លេខ០១១សហវ, ០៦ តុលា ២០១៦

២៦. សេចក្តីជូនដំណឹងស្តីពីការកែសម្រួលមូលដ្ឋានគិតអាករពិសេសលើមុខទំនិញមួយចំនួនដែលផលិតក្នុងស្រុកក្រៅពីបារីនិងស្រា, លេខ០០៥សហវ, ១៩ មករា ២០១៥

២៧. សេចក្តីជូនដំណឹងស្តីពីការអនុវត្តការកែសម្រួលអត្រាអាករពិសេសលើមុខទំនិញមួយចំនួនដែលផលិតក្នុងស្រុក, លេខ២២២៧អពដ, ២២ មីនា ២០១៦

២៨. សេចក្តីណែនាំស្តីពីការអនុវត្តអត្រាពន្ធលើប្រាក់បៀវត្សថ្មី,លេខ ០០២ សហវ/អពដ, ១៥ មករា ២០១៨

២៩. សេចក្តីប្រកាសព័ត៌មាន, ២៩ ឧសភា ឆ្នាំ២០១៩

៣០. ការធ្វើបទសម្ភាសន៍ផ្ទាល់មាត់ ជាមួយប្រធានការិយាល័យរដ្ឋបាល ថ្ងៃទី១៣ ខែមីនា ឆ្នាំ ២០១៩

៣១. ការធ្វើបទសម្ភាសន៍ផ្ទាល់មាត់ ជាមួយអនុប្រធានសាខាការិយាល័យបំណុល ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៩
៣២. ការធ្វើបទសម្ភាសន៍ផ្ទាល់មាត់ ជាមួយប្រធានការិយាល័យរដ្ឋបាល ថ្ងៃទី២០ ខែមីនា ឆ្នាំ ២០១៩
៣៣. ការធ្វើបទសម្ភាសន៍ផ្ទាល់មាត់ ជាមួយអនុប្រធានសាខាការិយាល័យសេវាអ្នកជាប់ពន្ធ និងចុះបញ្ជី ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩
៣៤. ការធ្វើបទសម្ភាសន៍ផ្ទាល់មាត់ ជាមួយអនុប្រធានសាខាការិយាល័យចាត់ចែងលិខិតប្រកាស
៣៥. ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩
៣៦. ការធ្វើបទសម្ភាសន៍ផ្ទាល់មាត់ ជាមួយប្រធានការិយាល័យបំណុល ថ្ងៃទី២៥ ខែមេសា ឆ្នាំ ២០១៩
៣៧. ការធ្វើបទសម្ភាសន៍ផ្ទាល់មាត់ ជាមួយអនុប្រធានសាខាការិយាល័យសវនកម្ម ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩
៣៨. http://www.tax.gov.kh/taxtypes.php

# ឧបសម្ព័ន្ធ